# ទស្សនាវដ្ដី

# វិទ្យាស្ថានភាសាជាតិ
## នៃរាជបណ្ឌិត្យសភាកម្ពុជា

Journal of National Language Institute
of Royal Academy of Cambodia



សាត្រាភំជ័ដួង ខ្សែ៧

ឆ្នាំទី៩
Year 9th
ព.ស. ២៥៦១

លេខ១០
No.10

ខែសីហា
August, 2017
គ.ស. ២០១៧

ភ្នំពេញ
Phnom Penh

# មាតិកា

ទំព័រ

## ១- ផ្នែកគ្រប់គ្រង

១.១- សមាសភាពនៃគណៈគ្រប់គ្រង : .......................................................... i
១.២- អារម្ភកថា : .......................................................................... ii

## ២- ផ្នែកអត្ថបទ

២.១- អំពីអវិជ្ជមានបទ *ឥត* នៅក្នុងល្បះ
ដោយបណ្ឌិត ជួរ គារី : ........................................................................ ១

២.២- ក្របខណ្ឌទ្រឹស្តីនៃអន្តរកម្មនិយមនៅក្នុងការសិក្សាអន្តេបទ/-ម-/និង/-ន-/នៅក្នុងភាសាខ្មែរ
ដោយបណ្ឌិត វង្ស មេង : .................................................................... ១៥

២.៣- ការសិក្សាប្រៀបធៀបព្យញ្ជនៈធនិតក្នុងភាសាខ្មែរ និង ថៃ
ដោយបណ្ឌិត ជុំ ស៊ុនណាង : ............................................................... ៣៣

២.៤- ទ្រឹស្តីអន្តរកម្មនិយមនិងការអនុវត្តនៅក្នុងក្របខណ្ឌនៃការស្រាវជ្រាវនិក្ខេបបទ
ដោយលោក ឃឹម វិច្ចិកា : .................................................................... ៥១

២.៥- **Ethnic Minority Groups in Ancient Cambodia**
ដោយលោក កែវ លីណែត : ................................................................ ៥៩

២.៦- មុខងារកិរិយាវិសេសន៍នៅក្នុងភាសាខ្មែរ ដោយ លោក គុយ រិន .................. ៦៧

២.៧- សាស្ត្រា រ៉ាំង ជួន ........................................................................ ៧៥

២.៨- **Metalinguistic Corrective Feedback and Students' Response to Feedback in L2 Writing** ដោយ Pilar S. Caparas ....................... ៩៥

**ទីប្រឹក្សាបច្ចេកទេស**

បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់

បណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ　　បណ្ឌិតសភាចារ្យ ខ្លូត ធីតា

បណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន　　បណ្ឌិតសភាចារ្យ សោម សុមុនី

**ទីប្រឹក្សារដ្ឋបាល**

ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច

ឯកឧត្តមបណ្ឌិត យ៉ង់ ពៅ ឯកឧត្តម លី សុធីរ័ត្ន ឯកឧត្តមបណ្ឌិត ជូ ច័ន្ទដារី

**និពន្ធនាយក**

បណ្ឌិត ជួរ គារី

**និពន្ធនាយករង**

បណ្ឌិត សន ពៅ　　បណ្ឌិត វង្ស មេង

**ក្រុមការងារ**

មន្ត្រីវិទ្យាស្ថានភាសាជាតិ

**ទំនាក់ទំនងទូទៅ**

លោក ផង់ ភិរុណ លោកស្រីបណ្ឌិត ភាជ ណាង លោក កែវ លីណែត

លោកស្រី អ៊ឹង ម៉ាល័យ

ចេញផ្សាយដោយ　វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា

អាសយដ្ឋាន　ក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២

ផ្លូវសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អ៊ីមែល　inlrac.languages@gmail.com

ទូរសព្ទ　០១២ ៨៣៦ ៤៧៦, ០៩២ ៨៩២ ៣៤៣, ០១២ ៩០៦ ៥៨៥, ០១២ ២៥២ ៤៧៣

**២០១៧**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវនិងការបោះពុម្ពផ្សាយ ជាកត្តាមួយសំខាន់ក្នុងការបង្ហាញនូវគំនិតទស្សនវិជ្ជារបស់មនុស្សក្នុងសម័យកាលនីមួយៗ ហើយ រាល់គំនិតទាំងឡាយដែលបានរកឃើញថ្មីសុទ្ធតែមានសារៈសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសង្គមជាតិ។ អាស្រ័យហេតុនេះ វិទ្យាស្ថានភាសាជាតិ (វ.ភ.ជ.) នៃរាជបណ្ឌិត្យ-សភាកម្ពុជាបានខិតខំសិក្សាស្រាវជ្រាវ វិភាគ ប្រមូលចងក្រងបានជាឯកសារមួយចំនួនដែលបានចុះផ្សាយតាមទស្សនាវដ្ដីរបស់ខ្លួនចំនួន០៨លេខនិងលេខពិសេសចំនួន០១លេខកន្លងមកហើយ។ ចំពោះទស្សនាវដ្ដីលេខ៩នេះ ក៏ដូចលេខមុនៗដែរ គឺជាអត្ថបទសិក្សាស្រាវជ្រាវ វិភាគ ទាក់ទងទៅនឹងភាសា ខ្លឹមសារនៃមរតកវប្បធម៌ខ្មែរ និងវប្បធម៌ជនជាតិដើមភាគតិចផងដែរ។

គណៈកម្មការទស្សនាវដ្ដី វ.ភ.ជ. នៃរាជបណ្ឌិត្យសភាកម្ពុជា នឹងទទួលចុះផ្សាយនូវរាល់អត្ថបទរបស់អ្នកស្រាវជ្រាវទាំងឡាយដែលមានគោលបំណងអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ ដើម្បីធ្វើយ៉ាងណាឱ្យភាសា អក្សរសាស្ត្រជាតិរបស់យើងមានឯកភាពនិងរីកចម្រើនជឿនលឿនដូចអរិយភាសាក្នុងលោកដែរ។

ក្នុងឱកាសនេះផងដែរ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាជាកូនចៅ ចៅទួត ជាថ្នាក់ដឹកនាំ មន្ត្រី វ.ភ.ជ. នៃរាជបណ្ឌិត្យសភាកម្ពុជា សូមក្រាបថ្វាយបង្គំឧទ្ទិសស្នាដៃនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធ **ព្រះបរមរតនកោដ្ឋ**។

យើងខ្ញុំទាំងអស់គ្នាដែលជា មិត្តភក្តិ ថ្នាក់ដឹកនាំ និង មន្ត្រី វ.ភ.ជ. ទាំងអស់ក៏សូមឧទ្ទិសទស្សនាវដ្ដីលេខ៩នេះ ជូនចំពោះវិញ្ញាណក្ខន្ធឯកឧត្តមបណ្ឌិតសភាចារ្យ **ឡុង សៀម** និង ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** ក៏ដូចជាវរជនអក្សរសាស្ត្រជាតិដទៃទៀត ដែលមានគុណបំណាច់ក្នុងការលើកស្ទួយវប្បធម៌ជាតិខ្មែរឱ្យគង់វង្សជាអមតៈ។

សូមឱ្យព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ** និង វិញ្ញាណក្ខន្ធ លោក អ្នក ទាំងអស់ បានសោយសុខក្នុងសុគតិភព។

**ប្រធានវិទ្យាស្ថានភាសាជាតិ**
បណ្ឌិត **ជួរ គារី**

# អំពីអវិជ្ជមានបទ *ឥត* នៅក្នុងល្បះ

**បណ្ឌិត ជួរ គារី**
ប្រធានវិទ្យាស្ថានភាសាជាតិ

## ១- សេចក្ដីផ្ដើម

តើអ្វីទៅជាអន្តរកម្មនិយម?

អន្តរកម្មនិយម គឺជាទ្រឹស្ដីមួយក្នុងការវិភាគភាសាវិទ្យា។ នៅក្នុងក្របខណ្ឌនេះ*«ន័យរបស់ឯកតាភាសាមួយ(ក្នុងន័យទូលាយ)កើតឡើងតាមរយៈអន្តរកម្ម រវាងឯកតាភាសានោះជាមួយសហបទរបស់វា នៅក្នុងបរិបទមួយកំណត់ច្បាស់លាស់»*[១]។ អន្តរកម្មនិយមជាលក្ខណៈចម្បងដែលកើតចេញអំពីការប្រើប្រាស់ភាសាហើយត្រូវបានប្រើនៅក្នុងចរន្តស្ថាបនិកនិយម។

តាមទ្រឹស្ដីអន្តរកម្មនិយមដែលមានលក្ខណៈបែបស្ថាបនិកនិយម គេមិនអាចសន្និដ្ឋានថា *«មានន័យដែលកើតមុនឬឋិតនៅក្រៅឯកតាភាសានោះទេ»*។ ន័យ គឺកើតមានព្រមគ្នានឹងពេលគេប្រើប្រាស់ភាសា។ យ៉ាងណាមិញ គេអាចយល់ពីអវិជ្ជមានន័យបានតែតាមរយៈអវិជ្ជមានបទឬអវិជ្ជមានសព្ទ ដែលជាធាតុចាំបាច់នៃអន្តរកម្ម ហើយអន្តរកម្មនោះឯងដែលជាយន្តការនៃការស្ថាបនាន័យ។ គោលការណ៍ជាសារវន្តនៃការវិភាគក្នុងអត្ថបទនេះ គឺផ្អែកលើន័យសត្យានុម័តដែលជាន័យស្ដែងឡើងតាមរយៈភាសា តែមិនមែនជាន័យដែលកើតឡើងតាមរយៈនៃការបកស្រាយឬការយល់ដឹងរបស់បុគ្គលណាម្នាក់នោះទេ។

*អវិជ្ជមានន័យ* គឺជាន័យដែលកើតចេញពីអន្តរកម្មរបស់ឯកតាភាសាដែលអាចជាអវិជ្ជមានបទ និងអវិជ្ជមានសព្ទ។ ចំណែកឯន័យបដិសេធ គឺជាន័យដែលកើតចេញពីប្រតិកម្មពីចេតនារបស់មនុស្ស ដែលត្រូវបានស្ដែងចេញតាមរយៈឃ្លាឬវាទរូប។ ឧទាហរណ៍*គាត់មិនយល់ ខ្ញុំមិនយល់* ស្ដែងពីអវិជ្ជមានន័យ ហើយអវិជ្ជមានន័យនេះកើតឡើងពីអន្តរកម្មរវាងអវិជ្ជមានបទ*(មិន)* និង សហបទរបស់វា ពោលគឺ*(យល់)* ។ ដូចគ្នាដែរ គេនិយាយថា*ខ្ញុំមិនខ្វីធ្វើយល់ ខ្ញុំមិនព្រមថាយល់ ខ្ញុំមិនធ្វើ ខ្ញុំមិនក្រោក ខ្ញុំមិនឱ្យ* គឺជាឃ្លាដែលមានន័យបដិសេធដែលចេញពីប្រតិកម្មមនុស្ស ពីព្រោះ មនុស្សនេះមានចេតនាមិន ចង់ធ្វើកិច្ចការដែលគេតម្រូវឱ្យខ្លួនធ្វើ។ តែប្រសិនបើគេនិយាយថា *ការងារនេះធ្វើមិនទាន់ហើយ, ថ្ងៃនេះបើខ្ញុំធ្វើការងារមិនហើយ អ្នកពិន័យខ្ញុំចុះ, បើតែយ៉ាងហ្នឹង វាមិនស្លាប់ហើយ...។ល។* ឃ្លាទាំងនេះមានអវិជ្ជមានបទ *មិន* ចូលរួម តែឃ្លាទាំងនេះ វាមិនមែនបញ្ជាក់ពីការបដិសេធន៍របស់វាទករនោះទេ។

*បដិសេធន៍* ស្ដែងពីទំនាក់ទំនងអន្តរប្រធានដែលអាចជាកម្រៅភាសា[២]។ គួរកត់សម្គាល់ថា ការបដិសេធអាចនាំឱ្យគូសន្ទនាយល់ពីអវិជ្ជមានន័យដែលវាទករ(អ្នកនិយាយ)ចង់ប្រាប់ឱ្យដឹង។

---

[១] ច័ន្ទ សំណព្វ ***ទ្រឹស្ដីអន្តរកម្មនិយម*** ដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ភ្នំពេញ ឆ្នាំ២០០៥ ឯកសារប្រើប្រាស់ផ្ទៃក្នុង។

[២] បច្ចេកសព្ទប្រើនៅដេប៉ាតឺម៉ង់ភាសាវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីស្ដែងពីអ្វីដែលភាសាបារាំងហៅថា extra-linguistique។ ក្នុងន័យនេះ បដិសេធន៍ឬការបដិសេធសំដៅយកប្រតិកម្មមួយដែលស្ដែងចេញពីចេតនារបស់

ឧទាហរណ៍ តាមរយៈវាទរូប*គួរឱ្យស្ដាយណាស់ ខ្ញុំមានគូដណ្ដឹងទៅហើយ* គូសន្ទនាយល់ឃើញថា វាទករបដិសេធខ្លួនរួចទៅហើយ។ ម្យ៉ាងទៀត ការបដិសេធជាតម្លៃអវិជ្ជមានចំពោះគូសន្ទនា តែវាជាតម្លៃវិជ្ជមានរបស់វាទករទៅវិញ។

អវិជ្ជមានន័យដែលយើងខ្ញុំលើកមកសិក្សានេះមានលក្ខណៈជាសត្យានុម័ត។ ហេតុនេះ វាមិនប្រែប្រួលទៅតាមបុគ្គលទេ។ ឧទាហរណ៍ យើងអាចនិយាយថា *ជំងឺអេដស៍ជាជំងឺធ្ងន់ដ៏កាចសាហាវបំផុត គេមិនអាចព្យាបាលវាបានទេ* ។ ទាំងវាទករ ទាំងសហវាទករក៏យល់ថា ជំងឺនេះមិនអាចព្យាបាលជាបានទេ។ ការប្រើប្រាស់អវិជ្ជមានសព្ទ ពេលខ្លះធ្វើឱ្យគូសន្ទនាមានភាពច្របូកច្របល់ក្នុងគំនិត ព្រោះមិនយល់ន័យឬអាចធ្វើរឿងល្អឱ្យក្លាយជាអាក្រក់បានឬអាចធ្វើរឿងអាក្រក់ឱ្យក្លាយជាល្អវិញក៏បានដែរ។

## ២- អវិជ្ជមានបទ

និយមន័យដំបូងដែលបានផ្ដល់ដល់អវិជ្ជមានបទ ធ្វើឡើងតាមរយៈទ្រឹស្ដីអន្តរកម្មនិយម គឺ ផ្ដោតលើតួនាទីផ្នែកសម្ព័ន្ធនៃធាតុវេយ្យាករណ៍នេះ នៅក្នុងយន្តការនៃការស្ថាបនាអវិជ្ជមានន័យឬវិជ្ជមានន័យដោយអនុលោមទៅនឹងអន្តរកម្មរបស់វាជាមួយសហបទដែលសុទ្ធតែជាចលករនៃន័យកម្ម[៣]។ ក្នុងក្របខណ្ឌនេះ សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានកំណត់និយមន័យថា៖

*«អវិជ្ជមានបទ ជាឯកតាភាសាមួយដែលមានលក្ខណៈជារូបសព្ទឬជាវចនសព្ទដែលប្រើសម្រាប់ស្ថាបនាអវិជ្ជមានន័យឬគ្រាន់តែបង្កើតជាទម្រង់អវិជ្ជមានតែប៉ុណ្ណោះ។ អវិជ្ជមានបទ មានជាអាទិ៍ អត់ ឥត មិន ពុំ កុំ គ្មាន ទេ »*[៤] ។

ការកំណត់និយមន័យបែបនេះ គឺបានគិតគូរនិងព្យាករជាមុននូវគ្រប់ចំណុច ដែលអាចកើតមានជាយថាហេតុនៅក្នុងការប្រើប្រាស់អវិជ្ជមានបទក្នុងភាសាខ្មែរ ហើយអាចចៀសផុតពីទិដ្ឋភាពវេយ្យាករណ៍ដែលមានលក្ខណៈងាប់ក្រឡានិងដែលអាចនាំឱ្យគេយល់ច្រឡំថា អវិជ្ជមានបទជាធាតុដែលបង្កើត តែអវិជ្ជមានន័យ។

សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានលើកឡើងថា *«ក្នុងវេយ្យាករណ៍អន្តរកម្មនិយម ឃ្លាទាំងឡាយណាដែលមានអវិជ្ជមានបទ ជាឃ្លាដែលមានទម្រង់អវិជ្ជមាន»*[៥]។ ក្នុងករណីនេះ*អវិជ្ជមាន* គឺសំដៅលើទម្រង់ឃ្លាតែប៉ុណ្ណោះ ដោយមិនគិតពីផ្នែកន័យឡើយ ហើយគួរកុំច្រឡំរវាង *ទម្រង់អវិជ្ជមាន* និង *អវិជ្ជមានន័យ* ។ លោកបានកត់សម្គាល់ថានៅក្នុងវេយ្យាករណ៍ប្រពៃណី គេតែងហៅឃ្លាទាំងឡាយ ណា

---

វាទករ(អ្នកពោលហើយអះអាងថា សារដែលខ្លួនបានបញ្ចេញមកពិត)តាមរយៈកាយវិការ(កម្រៅភាសា) ឬ តាមរយៈពាក្យសម្ដី។ល។

[៣]ច័ន្ទ សំណព្វ មេរៀនន័យវិទ្យា សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត(១៩៩៩-២០១០)។

[៤]ច័ន្ទ សំណព្វ : *បង្កើតពាក្យ កម្លីពាក្យ បម្រើបម្រាស់ពាក្យ* , ដ.ឯ.ម. ទំព័រ៦៩។

[៥]ច័ន្ទ សំណព្វ : *បង្កើតពាក្យ កម្លីពាក្យ បម្រើបម្រាស់ពាក្យ* , ដ.ឯ.ម. ទំព័រ៦៩។

ដែលមានទម្រង់អវិជ្ជមានជា*ឃ្លាបដិសេធ*។ ផ្ទុយពីវេយ្យាករណ៍ប្រពៃណី លោកកំណត់ន័យនៅក្នុងវេយ្យាករណ៍អន្តរកម្មនិយមថា ឃ្លាបដិសេធមិនមែនសុទ្ធតែមានទម្រង់អវិជ្ជមាននោះទេ ព្រោះវាទករ អាចបដិសេធតាមរយៈឃ្លាដែលមានទម្រង់វិជ្ជមានផងដែរ។

## ៣- ការសិក្សាអំពី ឥត

ការសិក្សាអំពី*ឥត* នៅទីនេះ គឺផ្ដោតទៅលើសំណុំពាក្យដែលមានរចនាសម្ព័ន្ធទូទៅដែលតាងដោយ(ឥត+គុ.កិ.+កិ.+ន.) (ឥត+កិ.) និង(ឥត+គុ.កិ.)[៦]ដោយធ្វើការសិក្សាវិភាគទៅលើវិសាលកម្មនៃអវិជ្ជមានបទនេះក្នុងការស្ថាបនាន័យជាមួយនឹងធាតុដែលជាសហបទ កន្សោមពាក្យ ឬ វាទកម្មរបស់វា។ ការសិក្សានេះក៏ផ្ដោតផងដែរទៅលើទិដ្ឋភាពនៃអន្តរកម្មនិយម ដោយបានចោទជាសំណួរថា តើក្នុងសំណង់ឃ្លា *ឥត* មានប្រភេទពាក្យតែមួយគត់ឬយ៉ាងណា? ហើយក៏មានចំណោទចោទសួរផង ដែរទៅលើតួនាទីឬមុខងាររបស់ពាក្យដទៃទៀតដែលឋិតនៅក្នុងបរិបទនៃការប្រើប្រាស់ពាក្យ*ឥត* ដោយ ហេតុថានៅក្នុងរចនាសម្ព័ន្ធឃ្លា បើមានធាតុមួយប្រែប្រួលធាតុដទៃទៀតក៏អាចប្រែប្រួលផងដែរ។ ការសិក្សានឹងឆ្លុះបញ្ចាំងឱ្យឃើញដែរថាការប្រែប្រួលមានលក្ខណៈជាប្រព័ន្ធដែរឬទេ ហើយលក្ខណៈសម្ព័ន្ធមានលក្ខណៈរឹងមាំដែលកំណត់ពីន័យរបស់ឃ្លាដែរឬទេ ឬមួយក៏គ្រាន់តែជាវេយ្យាករណ៍នៃពាក្យ ដែលតម្រូវឱ្យមាននិយាមភាសាមួយមានលក្ខណៈឯកភាពគ្នាក្នុងការប្រើប្រាស់ តែន័យសេចក្ដី ដែលអាចស្ដែងឡើងតាមរយៈតួនាទីរបស់ពាក្យដែលមានឥទ្ធិពលដោយផ្ទាល់ឬដោយប្រយោលទៅលើសំណង់ឃ្លា និងទៅក្នុងយន្តការនៃការស្ថាបនាន័យ។

ជាមួយនេះ ការសិក្សានឹងលើកយក«សំណុំពាក្យ»[៧]មកសិក្សាផងដែរ ពីព្រោះ ការលើកយកឃ្លាឬវាទរូបមកសិក្សាពេលខ្លះ មិនមាននៅក្នុងសំណេរណាមួយឡើយ។ ការលើកយកសំណុំពាក្យនេះ យើងអាចស៊ើបសួរតាមរយៈចាស់ទុំឬអ្នកដទៃផ្សេងទៀត ដែលពាក្យនេះមានប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ថាតើពាក្យណាមួយដែលយើងលើកយកមកសិក្សានេះ អាចនិយាយបាន ឬមិនបានជាដើម។ ប៉ុន្តែជាទូទៅ សំណុំពាក្យដែលយើងលើកយកមកសិក្សានេះ គឺពិតជាមានគុណវិបត្តិខាង «ការឯកភាពខាងទិន្នន័យ» ថាតើទិន្នន័យនេះអាចយកជាការបានដែរឬទេ ក្រោយពីការសាកសួរឬស្វែងយល់ពីអ្នក

---

[៦]ការប្រើប្រភេទពាក្យ តាមបែបវេយ្យាករណ៍ប្រពៃណី ដូចជា *ន. កិ. គុ. គុ.កិ.* ជាដើម មិនមានឥទ្ធិពលទៅលើខ្លឹមសារនៃការវិភាគរបស់ខ្ញុំទេ តែផ្ទុយទៅវិញ វាអាចធ្វើឱ្យភាសាវិទូមួយចំនួនរិះគន់បាន។ តែទោះជាយ៉ាងណាក្នុងការរិះគន់នេះ មិនមានទំនាក់ទំនងដោយផ្ទាល់លើការសិក្សារបស់យើងខ្ញុំទេ ដោយហេតុថា ប្រភេទពាក្យនេះ គ្រាន់តែចម្លងយកតាមវេយ្យាករណ៍ប្រពៃណីតែប៉ុណ្ណោះ ដោយខ្ញុំយកមកប្រើដើម្បីជៀសវាងបង្កើតបច្ចេកសព្ទថ្មីសម្រាប់ហៅដែលនាំឱ្យមានភាពចម្លែកកាន់តែច្រើនឡើង។

[៧]បណ្ឌិត ច័ន្ទ សំណព្វ បានឱ្យនិយមន័យថា«*សំណុំពាក្យ គឺជាពាក្យទាំងឡាយដែលបានចងសម្ព័ន្ធនឹងគ្នាជាបន្តបន្ទាប់ មិនទាន់ត្រឹមត្រូវទាំងស្រុងតាមវេយ្យាករណ៍ ហើយមិនទាន់មានស្ថិរភាពផ្នែកន័យ។ សំណុំពាក្យមិនជាប់ទាក់ទងទៅនឹងមុខងារសម្ព័ន្ធក្នុងល្បះទេ។ ផលប្រយោជន៍ក្នុងការសិក្សាពីសំណុំពាក្យនេះ គឺអនុញ្ញាតឱ្យយើងសិក្សាដោយផ្ដោតទៅលើយន្តការនៃឥត។ ម្យ៉ាងទៀត វាអាចឱ្យយើងស្វែងយល់ពីបរិបទដែលសំណុំពាក្យនឹងត្រូវបានប្រើប្រាស់ ដោយចៀសវាងបាននូវការច្រឡំរវាងយន្តការនៃឥតនិងតម្លៃនៃបរិបទ*»។

ដទៃទៀតមក? ពីព្រោះពេលខ្លះ គេអាចទទួលយកបានដែរ តែហាក់ដូចជាមិនតាមធម្មជាតិនោះទេ ដូចជា *«ឥតលុយ»* ធៀបទៅនឹង *«គ្មានលុយ»*។ ម្យ៉ាងទៀត ការសិក្សាពីសំណុំពាក្យនេះមានផលវិបាកមួយ ដោយវាត្រូវបានកាត់ផ្តាច់ពីបរិបទដែលអាចនាំឱ្យមានការរិះគន់ពីសំណាក់អ្នកសិក្សាផ្នែកភាសាវិទ្យាមួយចំនួន ដែលលោកឱ្យតម្លៃខ្លាំងទៅខាងតួនាទីរបស់បរិបទនោះ។ ម្យ៉ាងវិញទៀត ការសិក្សាពីសំណុំពាក្យនេះ គ្មានឯកសារច្បាស់លាស់ ប៉ុន្តែការសិក្សាសំណុំពាក្យអាចមានផលប្រយោជន៍ដល់ការវិភាគស៊ីជម្រៅក្នុងការបកស្រាយដូចតទៅៈ

១- ការសិក្សាពីសំណុំពាក្យនេះនាំឱ្យយើងចៀសផុតពីភាពឆ្លងគ្នានៃធាតុដែលបានប្រើប្រាស់ក្នុងឃ្លានិងពីការបំភាន់នៃបរិបទ។ ការមានពាក្យកាន់តែច្រើន វាពិតជាងាយស្រួលក្នុងការស្ថាបនាន័យមែន ក៏ប៉ុន្តែ វាងាយស្រួលធ្វើឱ្យយើងធ្លាក់ចូលទៅក្នុងភាពភាន់ច្រឡំ ដោយយកគុណតម្លៃនិងអត្ថន័យ ដែលកើតចេញអំពីពាក្យផ្សេងៗទៀតឬទំនាក់ទំនងនៃពាក្យផ្សេងៗទៀតយកមកធ្វើជាពាក្យរបស់ឃ្លា។

២- ការសិក្សាសំណុំពាក្យនេះនាំឱ្យយើងងាយស្រួលទៅវិញ ប្រសិនបើវាមានក្របខណ្ឌទ្រឹស្តីច្បាស់លាស់ ខ្ញុំមានគំនិតប្រាកដនិយម ជំហរច្បាស់លាស់ក្នុងការវិភាគនេះ ជាពិសេស វាជាលទ្ធផលនៃការសិក្សាពីពាក្យតាមបែបភាសាវិទ្យា ដែលមានទ្រឹស្តីអន្តរកម្មនិយមជាប្រទីប។

៣- ការសិក្សាសំណុំពាក្យនាំឱ្យយើងមិនប្រថុយប្រថានទៅនឹងគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្តាលមកពីភាពឆ្លងនៃបរិបទ ហើយអនុញ្ញាតឱ្យសិក្សាទៅលើពាក្យឬជាសំណុំពាក្យណាមួយដោយផ្ទាល់។

ដូចនេះ ការសិក្សារបស់យើងគឺផ្អែកលើសំណុំពាក្យដើម្បីស្វែងយល់ពីសំណុំពាក្យនេះថាតើវាមានអត្ថន័យយ៉ាងណា ហើយវាមានជាប់ទាក់ទងទៅនឹងបរិបទអ្វីខ្លះ? យើងស្វែងយល់ពីតួនាទីរបស់បរិបទ យើងអាចដកបរិបទចេញដើម្បីចូលជ្រៅទៅក្នុងយន្តការនៃការស្ថាបនាន័យតាមរយៈឯកតាភាសា។ ក្នុងន័យនេះ បរិបទគ្រាន់តែជានិយតករនៃន័យ តែមិនមែនជាចលករនៃការស្ថាបនាន័យនោះទេ[៨]។ ជាមួយនេះដែរ យើងអាចចោទសួរបានថា តើជាទូទៅគេអាចនិយាយថា*ខ្ញុំឥតលុយ ខ្ញុំអត់ លុយខ្ញុំ គ្មាន លុយ*[៩] បានដែរឬទេ? ហើយតើ *ឥត* នៅពេលនេះ(ក្នុងសម្ព័ន្ធ) វាអាចដើរតួនាទីជា កិរិយាសព្ទ បានដែរឬទេ?

ជាទូទៅ យើងមិនអាចនិយាយថា **ខ្ញុំមិនលុយ* បានទេ ហើយ *?ខ្ញុំឥតលុយ*[១០] ក៏គេមិននិយមប្រើដែរ ប៉ុន្តែ គេអាចនិយាយថា *ខ្ញុំអត់លុយ ខ្ញុំគ្មានលុយ* ។ បើយើងពិនិត្យខាងផ្នែកសម្ព័ន្ធឃើញថា វាមានលក្ខណៈខុសគ្នារវាង*មិន អត់ ឥត* និង*គ្មាន* ។ ប្រសិនបើយើងសិក្សាវិភាគទៅលើន័យវិញនោះ យើងឃើញថា ធាតុដែលជាអវិជ្ជមានបទទាំងនេះមានលក្ខណៈខុសៗគ្នាក្នុងការស្ថាបនាន័យ។

**ខ្ញុំមិនលុយ* មិនឃើញមានប្រើទេឬបើនិយាយក៏ស្តាប់មិនបាន។ ហេតុនេះ *មិន* នៅទីនេះ មិនអាចមានតួនាទីជាកិរិយាសព្ទបានឡើយ ពីព្រោះវាគ្មានគុណតម្លៃទាំងឃ្លាទាំងអត្ថន័យ។

---

[៨]តាមមេរៀនន័យវិទ្យារបស់សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ។

[៩]ឃ្លានេះយើងខ្ញុំតែងឡើងដោយខ្លួនឯង ដោយមិនឱ្យប្រាសចាកពីការនិយាយទូទៅរបស់មនុស្សទូទៅឡើយ។

[១០]ឃ្លាដែលមានសញ្ញា ( ? ) នេះនៅពីខាងឆ្វេង សម្គាល់ថា ឃ្លានេះគេអាចនិយាយបានដែរ តែវាមិនទូទៅទេ។

?*ខ្ញុំឥតលុយ*។ ថ្វីត្បិតពេលខ្លះ គេមិនសូវដែលប្រើ*ឥត* ជាមួយនឹងឃ្លាបែបនេះ ប៉ុន្តែវាអាចមានតួនាទីជាកិរិយាសព្ទ ដែលក្នុងបរិបទខ្លះគេអាចយល់ថា*ឥត* ហាក់បីដូចជា*អត់(ខ្ញុំអត់លុយ)*។ តែ *មិន* មិនអាចដូច*អត់* បានទេ ទោះបីនៅក្នុងបរិបទខ្លះ*ខ្ញុំមិនទៅ ខ្ញុំអត់ទៅ* ហាក់ដូចជំនួសគ្នាបានក៏ដោយ។ តែតាមពិតទៅ*មិន* និង*អត់* មិនដូចគ្នាទេ តើវាខុសគ្នាយ៉ាងដូចម្ដេច ? ចំពោះពាក្យ*ឥត* ដូច*អត់* ទាំង*ឥត* ទាំង*អត់* មានមុខងារជាកិរិយាសព្ទស្នូលនៃល្បះបាន តែផ្ទុយទៅវិញ*មិន* មិនអាចជាកិរិយាសព្ទស្នូលនៃល្បះបានទេ។ ក៏ប៉ុន្តែ ទោះបី*មិន* ជាមួយនឹង*អត់* ខុសគ្នានៅក្នុងប្រភេទពាក្យនៅពេលដែល *ឥត* ឬ *អត់* មានមុខងារជាកិរិយាសព្ទដូចនេះក៏ដោយ ក៏យើងអាចសន្និដ្ឋានបានតាមបែបលក្ខណៈសម្ព័ន្ធថា*ឥត* និង *អត់* មានលក្ខណៈខុសពី*មិន*។

## ៤- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធនៅមានទម្រង់ ឥត+គុ.កិ.+កិ.+ន.

ការសិក្សាពីសំណុំពាក្យដែលមាន*រចនាសម្ព័ន្ធ ឥត*+គុ.កិ+កិ.+*ន.* យើងមិនផ្ដោតទៅលើប្រភេទពាក្យនោះទេ គឺ យើងសិក្សាពីតួនាទីនិងយន្តការរបស់*ឥត* ដែលស្ដែងឡើងតាមរយៈអន្តរកម្មរបស់ពាក្យនេះនៅក្នុងរចនាសម្ព័ន្ធ ដែលជាទូទៅយើងបានកំណត់ជាទម្រង់និយមបែបនេះ។ ការដែលរៀបជាទម្រង់ខាងលើនេះ វាគ្រាន់តែបង្ហាញពីមុខងាររបស់ពាក្យនៅក្នុងសម្ព័ន្ធឃ្លាតាមបែបវេយ្យាករណ៍ប្រពៃណីតែប៉ុណ្ណោះ។ ការសិក្សារបស់យើងនាពេលនេះ គឺផ្ដោតទៅលើវិសាលភាពនិងតួនាទីរបស់ *ឥត* ដែលនឹងស្ដែងឱ្យឃើញពីយន្តការរបស់ពាក្យនេះ។

ដើម្បីសិក្សាពី ឥត នៅក្នុង*សំណង់ឃ្លាដែលមានរចនាសម្ព័ន្ធ(ឥត*+គុ.កិ.+កិ.+*ន.)* យើងសូមលើកឃ្លាមួយចំនួន ដូចខាងក្រោមមកធ្វើការសិក្សាវិភាគដូចតទៅៈ

ឃ្លា(៣៣)«*នាងរៀបការយូរហើយ ឥតទាន់មានកូន មួយគ្រាប់*»[១១]។

ឃ្លា(៣៣) គឺជាការនិយាយរបស់វាទករក្នុងន័យអាណិតអាសូរចំពោះនាងឥតកូននោះ។ *ឥត* មានអន្តរកម្មជាមួយនឹង *ទាន់* និង*មាន* បង្កើតបានជាគោលអវិជ្ជមានមួយ គឺ*ឥតទាន់មាន* ហើយ គោលអវិជ្ជមាននេះមានអន្តរកម្មជាមួយនាមសព្ទ*កូន* បញ្ជាក់ពីអវិជ្ជមាននៃ*កូន* ដែលមិនទាន់ប្រាកដថា នាងគ្មានកូនរហូតនោះទេ។

ករណីនេះ បើទោះបីជាគ្មាន*ទាន់* និង*មាន* ក៏*ឥត* នៅតែមានអន្តរកម្មជាមួយនឹង*កូន* ដដែល។ សូមមើល(៣៣ក)«*នាងរៀបការយូរហើយ ឥតកូនមួយគ្រាប់*»។ ក្នុងន័យនេះ«*ឥតកូនមួយគ្រាប់*» មានន័យផ្សេងពី«*ឥតទាន់មានកូន*» បានសេចក្ដីថា នាងពិតជាគ្មានកូនម្នាក់មែន តាំងពីពេលនាងរៀបការរហូតមកនិងទៅថ្ងៃក្រោយទៀតក៏នាងនៅតែគ្មានកូនដដែល។ នៅក្នុងករណីនៃឃ្លា (៣៣ក) នេះ ហើយដែលធ្វើឱ្យយើងយល់ឃើញថា*ឥត* អាចមានសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅ (ឥត+ន.) បាន ឧទាហរណ៍ «*នាងឥតកូនមួយគ្រាប់*» «*ខ្ញុំឥតលុយ*»។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក្ដី តើយើងអាចយកអវិជ្ជមានបទ*មិន* មកជំនួស*ឥត* ក្នុងករណីឃ្លា(៣៣) (៣៣ក) និង ឧទាហរណ៍ខាងលើបានដែរឬទេ ?

---

[១១]ឃ្លានេះយើងខ្ញុំតែងឡើងដោយខ្លួនឯង ដោយមិនឱ្យប្រាសចាកពីការនិយាយទូទៅរបស់មនុស្សទូទៅឡើយ។

ហើយបើយើងយកមកជំនួស តើវាមានលក្ខណៈសម្ព័ន្ធនិងមានន័យដូចគ្នាឬខុសគ្នាក្នុងកម្រិតណាដែរ។ សូមមើលឃ្លា(៣៣') ដូចតទៅៈ

*(៣៣') «នាងរៀបការយូរហើយ មិនទាន់មានកូនមួយគ្រាប់»*។

យើងឃើញថា រវាងឃ្លា(៣៣)និង(៣៣') គេអាចនិយាយឃ្លា(៣៣')ជាករណីទូទៅច្រើនជាងឃ្លា(៣៣)។ ប៉ុន្តែ ចំពោះឃ្លា **(៣៣ក')* ដូចខាងក្រោមនេះ គេមិនដែលនិយាយឡើយ

*(៣៣ក') *«នាងរៀបការយូរហើយ មិនកូនមួយគ្រាប់»* ។

ហេតុដូច្នេះហើយ យើងអាចនិយាយបានថា អវិជ្ជមានបទ*មិន* ជាទូទៅ គេមិនអាចប្រើនៅក្នុងសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅ(មិន+ន.) បានទេ ខុសពីអវិជ្ជមានបទ*ឥត* ដែលគេអាចប្រើវាបានដូចក្នុងឃ្លា(៣៣ក)ខាងលើ។

សូមមើលឃ្លា(៣៤) ដូចខាងក្រោមៈ

*(៣៤) «ពួកខ្មាំងឥតបះរបើងឡើងដៃដូចពីមុនទេ»* [១២]។

ឃ្លា(៣៤)នេះ វាទករបានរាយការណ៍ថា ពួកខ្មាំងមិនងើបប្រឆាំងបះបោរឡើងចាងទៀតទេ។ ដូចករណីឃ្លា(៣៣)ដែរ *ឥត* មានអន្តរកម្មជាមួយនឹង (*បះរបើង* និង*ឡើង*) បង្កើតបានជាគោលអវិជ្ជមានមួយ គឺ*ឥតបះរបើងឡើង* ហើយគោលអវិជ្ជមាននេះមានអន្តរកម្មជាមួយនាមសព្ទ *ដៃ* បញ្ជាក់ពីអវិជ្ជមាននៃ*ដៃ* ដែលមិនទាន់ប្រាកដថាពួកខ្មាំងមិនងើបឡើងបះបោររហូតនោះទេ។

ករណីនេះ បើគ្មាន *បះរបើងឡើង* ក៏*ឥត*នៅតែមានអន្តរកម្មជាមួយនឹង *ដៃ* ដែលអាចនាំឱ្យមានឃ្លា(៣៤ក)ដូច្នេះ «*ពួកខ្មាំងឥតដៃដូចពីមុនទេ*»។ ក្នុងន័យនេះ «*ឥតដៃដូចពីមុនទេ*» មានន័យផ្សេងពី «*ឥតបះរបើងឡើងដៃដូចពីមុនទេ*» ដែលមានន័យថា ឥឡូវពួកខ្មាំងសត្រូវមិនហ៊ានងើប ប្រឆាំងឬធ្វើសកម្មភាពខ្លាំងក្លាដូចពីមុនទេ ហើយក៏មានន័យខុសពីឥឡូវពួកខ្មាំងវាពិការដៃដែរ។ ក្នុងន័យឃ្លា(៣៤ក) នេះហើយ ដែលធ្វើឱ្យយើងយល់ឃើញថា*ឥត* អាចមានលទ្ធភាពសង់សំណង់ឃ្លា ដែលមានរចនាសម្ព័ន្ធទូទៅ(ឥត+ន.)បាន ក្នុងករណីដូចឧទាហរណ៍ «*នាងឥតកូនមួយគ្រាប់*» «*ខ្ញុំឥតលុយ*» ជាដើម។

យើងសង្កេតឃើញថា រវាងឃ្លា(៣៣ក) និង (៣៤) ទំនាក់ទំនងនៃអវិជ្ជមានបទ*ឥត* ជាមួយនឹងនាមសព្ទ(*កូន* និង *ដៃ* ) ដូចគ្នា ពីព្រោះគេអាចមានលទ្ធភាពថា«*ឥតកូន*» «*ឥតដៃ*» បាន ដោយគ្មានខុសទាស់នឹងក្បួនវេយ្យាករឡើយ។ ប៉ុន្តែនៅក្នុងការប្រើប្រាស់ទូទៅ ចំពោះអវិជ្ជមានបទ*ឥត* នេះ គេមិនសូវដែលនិយាយឬគេមិននិយាយជាទូទៅឡើយ ប្រសិនបើគេនិយាយ ក៏គេប្រឹងនិយាយទាំងឆ្គងនេះ

បើតាមការធ្វើសម្ភាសន៍ជាមួយមនុស្ស[១៣] ជាច្រើននាក់នៅវិទ្យាស្ថានភាសាជាតិ ដែលពួកគេបានឆ្លើយនឹងសំណួរដែលបានសួរថាៈ

*«អ្នកមានលុយទេ ?» «រឹឡាមួយតម្លៃ៤០ម៉ឺនដុល្លារ តើលោកត្រូវចង់ទិញវាទេ ? »*

---

[១២]វាទរូបនេះខ្ញុំតែងឡើងដោយខ្លួនឯង ដោយមិនឱ្យប្រាសចាកពីការនិយាយទូទៅរបស់មនុស្សទូទៅឡើយ។

[១៣]ខ្ញុំបានចោទជាសំណួរ សួរទៅមន្ត្រីវិទ្យាស្ថានភាសាជាតិចំនួន៨នាក់និងបណ្ឌិតសភាចារ្យ អ៊ុំ ច័ន ដែលកាលណោះលោកនៅជាប្រធានវិទ្យាស្ថានភាសាជាតិផងដែរ។

ចម្លើយ គឺពួកគេទាំងអស់គ្នាឆ្លើយថា «*ខ្ញុំអត់មានលុយ*» ឬ «*ខ្ញុំគ្មានលុយ*»។

តាមការសិក្សា យើងអាចសន្និដ្ឋានបានថា អវិជ្ជមានបទ*ឥត* អាចមានលទ្ធភាពបង្កើតសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅ(*ឥត*+ន.)បាន សមស្របតាមក្បួនវេយ្យាករ ប៉ុន្តែលទ្ធភាពក្នុងការប្រើប្រាស់ទូទៅ គេមិនសូវនិយមប្រើអវិជ្ជមានបទបែបនេះឡើយ។

## ៥-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កិ. + ឥត + ឈ្នាក់

នៅក្នុងចំណុច១ខាងលើ យើងធ្វើការសន្និដ្ឋានតាមបែបលក្ខណៈសម្ព័ន្ធថា *ឥត* និង *អត់* មានលក្ខណៈខុសពី*មិន* ពីព្រោះអវិជ្ជមានបទ*មិន* ជាទូទៅ គេមិនអាចប្រើនៅក្នុងសំណង់ឃ្លាដែលមាន រចនាសម្ព័ន្ធទូទៅ (មិន+ ន.) បានទេ តែអវិជ្ជមានបទ*ឥត* គេអាចប្រើវានៅក្នុងសំណង់ឃ្លាដែលមានរចនា-សម្ព័ន្ធទូទៅ (ឥត+ន.)បាន។

ប៉ុន្តែនៅមានការប្រើប្រាស់នៅក្នុងបរិបទផ្សេងទៀតដែល *ឥត* និង *អត់* គេអាចយកវាទៅប្រើជាឈ្នាក់វេយ្យាករ(marque gramaticale)នៅក្នុងបរិបទនេះហើយដែលនាំឱ្យអ្នកសិក្សាផ្នែកសម្ព័ន្ធខ្លះ យល់ឃើញថា*ឥត* និង*អត់* មានលក្ខណៈដូច*មិន* ទៅវិញ តែវាដូចគ្នាខាងការចងសម្ព័ន្ធឃ្លា។ រីឯ តួនាទីរបស់ *ឥត* និង *អត់* បើប្រៀបធៀបជាមួយនឹង*មិន* មិនដូចគ្នាទេ។ ភាពខុសគ្នាទាំងនេះស្ដែងពីស្ថានភាពនៃវាទកម្មដែលជាបញ្ហាប្រឈមរវាងវាទករនិងសហវាទករ។

តាមការសិក្សា អវិជ្ជមានបទមានអន្តរកម្មជាមួយនឹងឈ្នាក់ដែលជាឯកតាភាសាស្ថិតនៅខាងស្ដាំរបស់វា ដោយរំលេចចេញជាបំណកស្រាយមួយដែលមានលក្ខណៈជាតម្លៃអវិជ្ជមាន គឺក្នុងន័យនេះហើយដែលយើងចង់សិក្សាពីតួនាទីនៃអវិជ្ជមានបទ ដើម្បីស្វែងយល់ពីអវិជ្ជមានន័យ។

តទៅនេះ ខ្ញុំសូមសិក្សាអំពីសំណុំពាក្យខ្លះដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កិ.+ឥត+ឈ្នាក់ ហើយដែលឈ្នាក់មានទិដ្ឋភាពផ្សេងៗគ្នា៖

### ៥.១- កិ + ឥត +ឈ្នាក់បំពេញ

តទៅនេះ យើងខ្ញុំសូមលើកយកឃ្លាមួយចំនួនមកសិក្សាដូចតទៅ៖

ឃ្លា(៣៥) *គាត់ស៊ីឥតកើត គាត់គិតឥតទាន់ គាត់រកឥតសល់*[១៤]។

ជាទូទៅនៅក្នុងឃ្លាបែបនេះ គេអាចនិយាយបានដោយមិនបាច់មានកិរិយាសព្ទដែលស្ថិតនៅខាងឆ្វេង*ឥត* ក៏បាន តែគេត្រូវការនូវឈ្នាក់ដែលជាសហបទស្ថិតនៅខាងស្ដាំ*ឥត* ជានិច្ច ដើម្បីចូលរួមស្ថាបនាន័យ។ សូមមើលឃ្លានេះ៖ (៣៥ក)*គាត់ឥតកើត..., គាត់ឥតទាន់..., គាត់ឥតសល់...* , ឃ្លាទាំងនេះ គេត្រូវការឃ្លា(ជាសហបទ)បន្តទៀតដើម្បីយល់ន័យ។

---

[១៤]ឃ្លាទាំងនេះ យើងខ្ញុំតែងឡើងដោយខ្លួនឯង ដោយមិនឱ្យប្រាសចាកពីការនិយាយទូទៅរបស់មនុស្សទូទៅឡើយ។

គេមិនដែលនិយាយថា **គាត់ស៊ីឥតØ *គាត់គិតឥតØ *គាត់រកឥតØ* ឡើយ។ នេះសបញ្ជាក់ថា អវិជ្ជមានបទ*ឥត* មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងឃ្នាក់ដែលជាកិរិយាសព្ទ*(កើត ទាន់ សល់)* ដែលជាឃ្នាក់បំណែបបញ្ជាក់ពីបែបបទនៃឃ្លាទាំងនេះ ថាតើ *«គាត់ស៊ី គាត់គិត គាត់រក»* នោះដោយបែបណា? ឬយ៉ាងដូចម្ដេច? ចម្លើយគឺ៖ *«គាត់ស៊ីឥតកើត» «គាត់គិតឥតទាន់» «គាត់រកឥតសល់»*។
គេអាចជំនួសឃ្នាក់ដែលជាកិរិយាសព្ទខាងស្ដាំនៃឃ្លា(៣៥)នេះ ដោយ៖ «គាត់ស៊ី*ឥតទាន់*» «គាត់ស៊ី*ឥតសល់*» «គាត់ស៊ី*ឥតគិត*» «គាត់ស៊ី*ឥតចូល*»..., «គាត់គិត*ឥតកើត*» «គាត់គិត*ឥតត្រូវ*» «គាត់គិត*ឥតហើស*» «គាត់គិត*ឥតបន្លោះ*» «គាត់គិត*ឥតខ្វះ*» «គាត់គិត*ឥតឃើញ*» «គាត់គិត *ឥតព្រាង*» ..., «គាត់រក*ឥតឃើញ*» «គាត់រក*ឥតកើត*» «គាត់រក*ឥតគិត*»...។

**៥.២- កិ + ឥត + ឃ្នាក់កាល**

ឃ្នាក់កាលជាឃ្នាក់មួយបែបផ្សេងទៀត ដែលបញ្ជាក់ពីវេលារយៈពេលនៅក្នុងឃ្លាមួយ។ សូមមើលឃ្លា(៣៦)ដូចខាងក្រោមនេះ៖

ឃ្លា*(៣៦) វាទៅឥតធាប់ទេ!* និង *(៣៧) វាមកលេងឥតយូរទេ!*[១៥]។

ឃ្លា(៣៦)និង(៣៧) វាទករចង់បញ្ជាក់ថា បើវាទៅហើយមិនងាយនឹងមកវិញទេ និង បើវាមក លេងប្រាកដជាឆាប់ត្រឡប់ទៅវិញ។ នៅក្នុងឃ្លា(៣៦)និង(៣៧) ប្រសិនបើយើងដកយកឯកតាភាសា ដែលជាធាតុមួយស្ថិតនៅខាងស្ដាំ*ឥត* ចេញ យើងនឹងបានឃ្លា(៣៦ក)និង(៣៧ក) ដូចនេះ៖

*(៣៦ក) *វាទៅឥតØ*

(៣៧ក) **វាមកលេងឥតØ*

តាមរយៈឃ្លាខាងលើនេះ យើងឃើញថា យន្តការរបស់អវិជ្ជមានបទ*ឥត* មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងឃ្នាក់ជាគុណកិរិយាដែលស្ថិតនៅខាងស្ដាំវា។ នៅពេលគ្មានឃ្នាក់កាលនេះ ឃ្លាទាំងពីរមានភាពផ្ដាំផ្ដងទាំងទិដ្ឋភាពសម្ព័ន្ធនិងទាំងទិដ្ឋភាពន័យ។

នៅក្នុងឃ្លា(៣៦)និង(៣៧)នេះដែរ ប្រសិនបើយើងដកយកធាតុដែលស្ថិតនៅខាងឆ្វេងជាប់នឹង*ឥត* ចេញ យើងនឹងបានឃ្លាដូច្នេះ៖ ឃ្លា*(៣៦ខ) វាØឥតធាប់ទេ!* និង*(៣៧ខ)វាØឥតយូរទេ!*។ តាមរយៈឃ្លា(៣៦ខ)និង(៣៧ខ) យើងអាចយល់បានថា អវិជ្ជមានបទ*ឥត* មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងឯកតាភាសាទាំងឡាយដែលជាធាតុជាសហបទរបស់វា ដូចក្នុងករណីនៃឃ្លា(៣៦ខ) និង(៣៧ខ) នេះ វាពិតជាឃ្លាតចាកពីទិដ្ឋភាពន័យនៃឃ្លា(៣៦)និង(៣៧)ប្រាកដណាស់ ថ្វីបើទិដ្ឋភាពសម្ព័ន្ធមិនមាន ខុសទាស់អ្វីក៏ដោយក៏វានៅតែត្រូវការឱ្យមានឃ្លាជាបន្តទៀត ដើម្បីបំពេញន័យឱ្យឃ្លាបែបនេះ។

ក្នុងករណីនេះដែរ គេអាចនិយាយថា៖

ក- *ទៅឥតយូរ*

ខ- *ទៅឥតហើស*

គ- *មកឥតយឺត*

---

[១៥] ឃ្លាទាំងនេះ យើងខ្ញុំតែងឡើងដោយខ្លួនឯង ដ.ឯ.ម.។

ឃ- *មកឥតលឿន*

ឃ្លា(ក) (ខ) (គ) (ឃ) មានន័យពេញលេញអាចយល់បានថា នរណាម្នាក់ទៅណាមានសភាពដូចម្ដេច(យូរឬរហ័ស)? នរណាម្នាក់មកកន្លែងណាមួយទាន់ពេលឬមិនទាន់ពេល(យឺតឬលឿន)?។

ប្រសិនបើ គេនិយាយដោយគ្មានឯកតាភាសាដែលស្ថិតនៅខាងឆ្វេង *ឥត* នោះឃ្លាខាងលើ នឹងមានទម្រង់ដូចខាងក្រោមនេះ៖

ក១- *Øឥតយូរ*

ខ១- *Øឥតរហ័ស*

គ១- *Øឥតយឺត*

ឃ១- *Øឥតលឿន*

ឃ្លានេះមិនមានខុសទាស់នឹងផ្នែកសម្ព័ន្ធទេ ប៉ុន្តែ នៅផ្នែកទិដ្ឋភាពន័យ វាអាចមានន័យផ្សេង ពីឃ្លា(ក) (ខ) (គ) (ឃ) ហើយទាល់តែមានសហបទចូលរួមជាមួយឃ្លាទាំងនេះ ទើបគេអាចដឹងពីន័យ នៃឃ្លានីមួយៗបាន។

គេអាចនិយាយបានថា៖

ក១.០ - *ឥតយូរទេ ប្រសិនបើវាមានពេលសរសេរទាំងថ្ងៃទាំងយប់*

ខ១.០ - *ឥតរហ័សសោះ គោមួយនឹមនេះ ព្រោះវាដើរយឺតពេក*

គ១-០ - *ឥតយឺតទេ ប្រសិនបើឡាននេះរត់លើផ្លូវថ្នល់ល្អ*

ឃ១-០ - *ឥតលឿនបានទេ ព្រោះឡានរត់នៅលើផ្លូវថ្នល់មិនទាន់ក្រាលកៅស៊ូ។*

ឃ្លាដដែលនេះ ប្រសិនបើគេនិយាយត្រឹមតែ៖

ក២- **ទៅឥតØ*

ខ២- **ចូលឥតØ*

គ២- **មកឥតØ*

ឃ២- **ចេញឥតØ*

ឃ្លាទាំងនេះមានភាពផ្ទុំឆ្គងទាំងទិដ្ឋភាពសម្ព័ន្ធនិងទិដ្ឋភាពន័យ ហើយជាទូទៅ គេមិនដែលនិយាយដូចនេះឡើយ។

តាមការសិក្សាខាងលើនេះ យើងឃើញថាយន្តការរបស់អវិជ្ជមានបទ *ឥត* មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងឈ្នាក់ដែលស្ថិតនៅខាងស្ដាំវា។ នៅពេលគ្មានឈ្នាក់ទាំងនេះទេ ធ្វើឱ្យឃ្លាទាំងនោះមានភាពផ្ទុំឆ្គងទាំងទិដ្ឋភាពសម្ព័ន្ធនិងទាំងទិដ្ឋភាពន័យ។

**៦- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ឥត+កិ.**

*យើងសិក្សាលើសំណុំពាក្យដែលមានរចនាសម្ព័ន្ធទូទៅមានទម្រង់* ឥត+កិ. ក្នុងករណីនេះ អវិជ្ជមានបទ*ឥត* មានទំនាក់ទំនងផ្ទាល់ទៅនឹងកិរិយាសព្ទ ហើយអន្តរកម្មរវាងធាតុទាំងពីរ (អវិជ្ជមាន-បទនិងកិរិយាសព្ទ)ស្ដែងពីគោលអវិជ្ជមាននៃកិរិយាសព្ទដោយវាបញ្ជាក់ពីហេតុភេទ(ព្រឹត្តិការណ៍

សកម្មភាព ស្ថានភាព ។ល។) ដែលស្តែងតាមរយៈកិរិយាសព្ទនោះ ហើយមិនទាន់ចារឹកនៅ «ក្នុងកាលៈទេសៈ»បានឡើយ។ ក្នុងន័យនេះ គេអាចនិយាយបានថា សំណង់ ឥត+កិ. រំលេចចេញនូវតម្លៃ អវត្តមាននៃហេតុភេទដែលស្តែងឡើងតាមរយៈកិរិយាសព្ទនោះ។

សូមមើលឃ្លាដូចខាងក្រោម៖

*(៣៨)«...នាងបានរត់គេចមកឱ្យឆ្ងាយ នាងប្រឹងកាត់ផ្តាច់ស្នេហាដ៏ល្អមួយ...ដែលរហូតដល់ ថ្ងៃនេះ នាងឥតដឹងសោះថា តើគេមានសុខទុក្ខយ៉ាងណា ?... »  ។*

*ឃ្លានេះ ប្រើនៅក្នុងបរិបទមួយដែលស្ត្រីម្នាក់បានតាមសម្លឹងកូនប្រុសរបស់ខ្លួនមិនឱ្យគេដឹង ខ្លួន ហើយបាននឹកតូចចិត្តខ្លួនឯងដែលខ្លួនកំព្រាមិនស្គាល់ឪពុក មកដល់កូន កូនមិនស្គាល់ឪពុក ដូច ខ្លួនដែរ ហើយនាងថែមទាំងនឹងភ្នកទៅដល់បុរសដែលជាឪពុករបស់កូន មិនដឹងជាគេបានសុខទុក្ខ យ៉ាងណា ពីព្រោះនាងរត់គេចពីគេមកជាយូរហើយ។*

*ឥត* នៅទីនេះ មានទំនាក់ទំនងជាមួយនឹងកិរិយាសព្ទ *ដឹង* ដែលបញ្ជាក់ពីសកម្មភាពរបស់ប្រធាន ពោលគឺ នាង ។ *ឥត* បង្ហាញពីគោលអវិជ្ជមាននៃ *ដឹង* មានន័យថា ចំពោះគេ (បុរសដែលជាឪពុករបស់កូន) *ដឹង* មិនអាចប្រព្រឹត្តទៅបានទេ ដោយសារតែគាត់ បានផ្តាច់ទំនាក់ទំនងនឹងគ្នាជាយូរមកហើយ។ ដើម្បីវិភាគពីយន្តការនៃ ឥត នៅក្នុងឃ្លានេះ យើងខ្ញុំសូមតាង ប០ ជានាង (ស្ត្រីម្នាក់)និង ប'០ ជាគាត់ (បុរសដែលជាឪពុករបស់កូន)។ បើផ្អែកទៅលើទ្រឹស្តីវាទកម្ម យើងអាចធ្វើការបកស្រាយ ដូចតទៅ៖

តាមការសិក្សាជាប្រព័ន្ធតាមបែបវាទកម្មអាចឱ្យយើងយល់បានថាប'០ តម្រូវឱ្យហេតុភេទ (ដឹង)ប្រព្រឹត្តឡើងដោយប០។ ប្រការនេះបញ្ជាក់ថា (ដឹង)អាចនឹងកើតមានឡើង ប្រសិនបើប'០ បង្ហាញខ្លួន។ ផ្ទុយទៅវិញ ប០ មិនបានធ្វើឱ្យហេតុភេទ(ដឹង )កើតឡើងទេ។ អត្ថន័យនេះបានរំលេចចេញតាមរយៈការប្រើអវិជ្ជមានបទទៅលើកិរិយាសព្ទដឹង ។ ក្នុងន័យនេះឥតដឹង បញ្ជាក់ថា ចំពោះ ប០ ហេតុភេទដែលស្តែងដោយកិរិយាសព្ទដឹង គ្មានសុពលភាព ហើយវាចារឹកនៅក្នុងគោលអវិជ្ជមាន។ អតិកថានេះ មានបំណងបញ្ជាក់ពីតួនាទីរបស់អវិជ្ជមានបទឥត ផងនិងពីតម្លៃវាទកម្មដែលបានមកពីការនឹកគិតរបស់មនុស្សម្នាក់ទៅរកមនុស្សម្នាក់ទៀតដែលមិនដឹងនៅកន្លែងណា។ បញ្ហានេះបង្កើតឱ្យ មានការប្រឈមគ្នារវាង ប០ ជាអ្នកនឹកគិត និង ប'០ អ្នកដែលគេនឹកគិតទៅដល់ ហើយមិនដឹងនៅទីណា។

**៧- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធនៅមានទម្រង់ ឥត+គុ.កិ.**

សំណង់ឃ្លាដែលមានរចនាសម្ព័ន្ធ ឥត+គុ.កិ. អវិជ្ជមានបទឥត មានទំនាក់ទំនងដោយផ្ទាល់ ទៅនឹងគុ.កិ. ដែលនៅជាប់នឹងវា ហើយអន្តរកម្មរវាងធាតុទាំងពីរ(អវិជ្ជមានបទនិងគុណកិរិយា) ស្តែងពីគោលអវិជ្ជមាននៃគុណកិរិយាដោយវាបញ្ជាក់ពីអវត្តមាននៃគុណកិរិយាទាំងនោះ។ សូមមើលឃ្លាខាងក្រោម៖

(៣៩)«...ប៉ុន្តែការចោទដើម្បីហេតុផលដាក់កំហុសទៅលើមនុស្សនាំយកទៅសម្លាប់ នៅតែ មាន***ឥត*** ស្រាកស្រាន្ត ទាំងស្រីទាំងប្រុសទាំងចាស់ទាំងក្មេង... » [១៦] ។

---

[១៦]ហែម គ្រឹស្នា : *ទោសអស់ជីវិត* ជ.ឯ.ម. ២០០០ ទំព័រ២៥។

ឃ្លានេះ វាទករបានពណ៌នាអំពីការចោទប្រកាន់របស់ពួកខ្មែរក្រហមមកលើប្រជាជនស្លូត ត្រង់ ដើម្បីយកទៅសម្លាប់យ៉ាងសកម្មដដែល។ ឃ្លានេះ ប្រសិនបើយើងយក***ឥត*** ចេញ យើងនឹងបានឃ្លា *(៣៩ក) ដូច្នេះ : «...ប៉ុន្តែការចោទដើម្បីហេតុផលដាក់កំហុសទៅលើមនុស្សនាំយកទៅសម្លាប់ នៅតែមាន*Ø*ស្រាកស្រាន្ត ទាំងស្រីទាំងប្រុសទាំងចាស់ទាំងក្មេង»។ ដូចឧទាហរណ៍មុនៗដែរ នៅពេល គ្មាន***ឥត*** នាំឱ្យ*ឃ្លានេះមានភាពផ្ទាំផ្គងទាំងនៅក្នុងទិដ្ឋភាពសម្ព័ន្ធនិងទាំងទិដ្ឋភាពអត្ថន័យ។*

*គួរកត់សម្គាល់ផងដែរថា អវិជ្ជមានបទ**ឥត** នៅក្នុងសំណង់ឃ្លាអាចមានរចនាសម្ព័ន្ធទូទៅ ដែលមានទម្រង់ (ឥត+កិ.) (ឥត+ន.) និង(ឥត+គុ.កិ.)* តែនៅក្នុងការប្រើប្រាស់ភាសាខ្មែរ***ឥត*** គេមិនសូវមានប្រើជាទូទៅនូវ*រចនាសម្ព័ន្ធទូទៅដែលមានទម្រង់(ឥត+គុ.)*នោះទេ។ ក្នុងករណីនេះ យើងអាចសាកល្បងសង់សំណង់ឃ្លាដែលមាន*រចនាសម្ព័ន្ធទូទៅដែលមានទម្រង់(ឥត+គុ.)* ដូចតទៅ៖

(៤០*ក)* ?គោក្របីរបស់គាត់***ឥត***តូច***ឥត***ធំ ហើយក៏***ឥត***កាចនិង***ឥត***ខ្ជិលដែរ [១៧]។
ជាទូទៅ នៅក្នុងភាសាខ្មែរគេមិនសូវប្រើសំណង់ឃ្លាបែបនេះឡើយ ប្រសិនបើ គេចង់ប្រើក្នុង ន័យដូចឃ្លា(៤០ក)នេះ គេអាចប្រើអវិជ្ជមានបទមិន ជំនួសឱ្យអវិជ្ជមានបទ***ឥត*** នេះវិញ។ យើងអាច ធ្វើឃ្លា(៤០) ដូច្នេះ៖

(៤០) គោក្របីរបស់គាត់មិនតូចមិនធំ ហើយក៏មិនកាចនិងមិនខ្ជិលដែរ ។

ឃ្លា(៤០)នេះ គេអាចប្រើជាទូទៅ ដែលត្រឹមត្រូវទាំងទិដ្ឋភាពសម្ព័ន្ធនិងន័យសេចក្តី។

យើងខ្ញុំសាកល្បងតែងឃ្លា?(៤១) តាមការលើកឡើងរបស់សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ដូចខាងក្រោមនេះ៖

(៤១) ?*របស់ឥតល្អ លក់មិនដាច់ទេ* [១៨]។

ឃ្លា(៤១)នេះ ក្នុងការប្រាស្រ័យទាក់ទងគ្នាជាទូទៅ គេមិនសូវនិយមប្រើវាឡើយ គេអាចប្រើដូចឃ្លា(៤២)ដូចនេះ៖ (៤២) *របស់មិនល្អ លក់មិនដាច់ទេ* ឬ គេអាចប្រើឃ្លាដូចនេះ *របស់មិនល្អ លក់ឥតដាច់ទេ* ក៏បាន។ ឃ្លាទាំងនេះ គេអាចប្រើជាទូទៅ ហើយវាមានភាពត្រឹមត្រូវ ទាំងទិដ្ឋភាពសម្ព័ន្ធ និងន័យសេចក្តី។

យើងឃើញថា អវិជ្ជមានបទ***ឥត*** មិនអាចប្រើបានជាទូទៅនៅក្នុងសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅមានទម្រង់(ឥត+គុ.)ដូចនេះឡើយ ពីព្រោះ វាមានភាពផ្ទាំផ្គងនៅក្នុងទិដ្ឋភាពន័យសេចក្តី។

---

[១៧]ឃ្លានេះខ្ញុំតែងឡើងដោយខ្លួនឯង ដោយមិនឱ្យប្រាសចាកពីការនិយាយទូទៅឡើយ។

[១៨]ឃ្លានេះសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានលើកឡើងឱ្យយើងខ្ញុំពិចារណា តើគេអាចប្រើក្នុងទម្រង់ *ឥត+គុ.* បាន ឬទេ?។

## សន្និដ្ឋាន

តាមការសិក្សាខាងលើ យើងសង្កេតឃើញថា អវិជ្ជមានបទ*ឥត* អាចមានលទ្ធភាពបង្កើតសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅ*ដែលមានទម្រង់ ( ឥត+កិ. ) ( ឥត+ន. ) និង(ឥត+គុ.កិ. )* តែនៅ ក្នុងការប្រើប្រាស់ភាសាខ្មែរ អវិជ្ជមានបទ*ឥត* គេមិនសូវមានប្រើជាទូទៅនូវរចនាសម្ព័ន្ធទូទៅដែលមាន ទម្រង់(ឥត+គុ.)ដូចនេះឡើយ ពីព្រោះ វាមានភាពផ្ទាំផ្ទួងនៅក្នុងទិដ្ឋភាពន័យសេចក្ដី។ យន្តការរបស់អវិជ្ជមានបទ*ឥត* ក៏មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងឈ្នាក់ដែលស្ថិតនៅខាងស្ដាំវាផងដែរ នៅពេលគ្មានឈ្នាក់ធ្វើឱ្យឃ្លាមានភាពផ្ទាំផ្ទួងទាំងទិដ្ឋភាពសម្ព័ន្ធនិងទាំងទិដ្ឋភាពន័យ។

## គន្ថនិទ្ទេស

### ១- ស្នាដៃជាភាសាវិទ្យា

#### ១.១- ជាភាសាខ្មែរ


កេង វ៉ាន់សាក់ : មូលភាពនៃការបង្កើតពាក្យថ្មី ( ភាគ១ ) ភ្នំពេញ ១៩៦៤ ៦៦២ទំព័រ។

ច័ន្ទ សំណព្វ : សំរាយឬតំរួត? ក្នុង : ***សន្និសីទជាតិ ស្ដីពីការសិក្សាស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ*** ឆ្នាំ២០០៥ ៣៦ទំព័រ។

ច័ន្ទ សំណព្វ : វាក្យស័ព្ទនាម ក្នុង:***ទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ*** លេខ៤៦ ឆ្នាំ៣៤ ខែមករា កុម្ភៈ មីនា ឆ្នាំ២០០៤ ទំព័រ១២-១៥។

ច័ន្ទ សំណព្វ : ផ្នែកមួយនៃអក្ខរាវិរុទ្ធខ្មែរ ក្នុង:***ទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ*** លេខ៥៥ ឆ្នាំ៣៦ ខែមេសា-ឧសភា-មិថុនា ឆ្នាំ២០០៦ទំព័រ៧សួន-១៤។

ច័ន្ទ សំណព្វ : ធាតុនៃវេយ្យាករណ៍ ដែលប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ ក្នុង : ***ទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ*** លេខ៥៨ ឆ្នាំ៣៧ ខែមករា កុម្ភៈ មីនា ទំព័រ២៤-៣២។

ច័ន្ទ សំណព្វ : ***ការបង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ*** (ឯកសារផ្ទៃក្នុង ដេប៉ាតឺម៉ង់ ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ២០០៨ ៨៨ទំព័រ។

ព្រុំ ម៉ល់ : **អំពីលក្ខណៈវិនិច្ឆ័យរូបនិយម** ក្នុង : ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត សភាកម្ពុជា,*** លេខ០៣ ខែឧសភា ឆ្នាំ២០០២ ទំព័រ៣៧-៥២។

ព្រុំ ម៉ល់ : **លទ្ធភាពបង្កើតពាក្យនិងការបង្កើតពាក្យក្នុងភាសាខ្មែរ** ក្នុង : ទស្សនាវដ្ដី ***វិទ្យាស្ថាន ភាសាជាតិ*** លេខ២ ឆ្នាំទី២ ខែមិថុនា ឆ្នាំ២០០១ ទំព័រ៦៥-៨១។

ព្រុំ ម៉ល់ : **អំពីលក្ខណៈវិនិច្ឆ័យរូបនិយម** ក្នុង :***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ*** លេខ៣ ឆ្នាំទី៣ ខែឧសភា ឆ្នាំ២០០២ ទំព័រ៣៧-៥២។

ព្រុំ ម៉ល់ : **ចំណុចគួរឱ្យកត់សម្គាល់ក្នុងភាសាខ្មែរបច្ចុប្បន្ន** ក្នុង : ***ទស្សនាវដ្ដី វិទ្យាស្ថានភាសា ជាតិ*** លេខ៤ ឆ្នាំទី៤ ខែកញ្ញា ឆ្នាំ២០០៣ ទំព័រ១០៥-១២១។

ម៉ៅ សុក្កន : **ភាសាវិទ្យាជាអ្វី?** ក្នុង : ***ទស្សនាវដ្តី សង្គមសាស្ត្រ-មនុស្សសាស្ត្រ*** ឆ្នាំទី១ ខែឧសភា ឆ្នាំ ១៩៩៥ ទំព័រ១៥-១៦។

វ៉ាន់ ឌីកាអុន : **អំពីភាសា** ក្នុង : ***ព្រឹត្តិប័ត្រស្រាវជ្រាវវិទ្យាសាស្ត្រ*** លេខ៣ ឆ្នាំ១៩៨៧ ទំព័រ៣-៨។

ហ្សង់ មីសែលហ្វីលីពី, ហៀប ច័ន្ទវិចិត្រ : ***ឯកសារណែនាំ អំពីសូរវិទ្យា*** ភ្នំពេញ ២០០៩ ២១៤ទំព័រ។

ឡុង សៀម : ***បញ្ហាវចនស័ព្ទវិទ្យាខ្មែរ*** ភ្នំពេញ ១៩៩៩ ១១៣ទំព័រ។

ឡុង សៀម : ***ស្ថានាមវិទ្យាខ្មែរ*** ភ្នំពេញ ១៩៩៧ ១៥០ទំព័រ។

ឡុង សៀម : **អំពីកិត្យានុភាពនិងការអភិវឌ្ឍន៍ភាសាខ្មែរ(ជាពិសេសតាមឯកសារ ភាសាមន-ខ្មែរ និងសិលាចារឹកកម្ពុជា)**ក្នុង : ***ទស្សនាវដ្តីវិទ្យាស្ថានភាសាជាតិ*** លេខ២ ឆ្នាំទី២ ខែមិថុនា ឆ្នាំ ២០០១ ភ្នំពេញ ទំព័រ១៧-២៣។

ឡុង សៀម : **សិលាចារឹកកម្ពុជា(សតវត្សទី៦ដល់ទី១៤)និងការអភិវឌ្ឍន៍សង្គមវប្បធម៌នៅតំបន់ ភ្នំដងរែក** ក្នុង : ***ទស្សនាវដ្តីវិទ្យាស្ថានភាសាជាតិ*** លេខ៣ ឆ្នាំទី៣ខែឧសភា ឆ្នាំ២០០២ ទំព័រ១-៦។

ឡុង សៀម : **សិលាចារឹកស្តុកកក់ធំជាភាសាសំស្ក្រឹត** ក្នុង : ***ទស្សនាវដ្តី វិទ្យាស្ថានភាសាជាតិ*** លេខ៤ ឆ្នាំទី ៤ ខែកញ្ញា ឆ្នាំ ២០០៣ ទំព័រ៣៥-៤៩។

ឡុង សៀម : **ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យស័ព្ទតាមបម្រើបម្រាស់ផ្នត់នីយកម្ម នៅក្នុងភាសាខ្មែរបុរាណ** ក្នុង : ***ទស្សនាវដ្តី វិទ្យាស្ថានភាសាជាតិ*** លេខ៣ ឆ្នាំទី៣ ខែឧសភា ឆ្នាំ២០០៣ ទំព័រ ៨៩-១០០។

**១.២- ជាភាសាបរទេស**

CHAN Somnoble, ***Identité et variation des unités de langue : étude d'une série d'unités lexico-gramaticales du khmer contemporain***, thèse de doctorat du nouveau régime, université de Paris x-Nanterre, 2002.

CHAN Somnoble, ***Linguistique appliquée: systématique des emplois de t3w en khmer comtemporain,*** mémoire de DEA, Université de Paris x-Nanterre, 1998.

CHAN ***Somnoble, Etude du fonctionnement de ba:n en khmer contemporain,*** mémoire de Maîtrise, Université de Paris x- Nenterre, 1997.

DANIEL JONES, THE PRONUNCIATION OF ENGLISH, cambridge at the university press 1967 223P.

FRANKLIN E. HUFFMAN, វិជ្ជាខេមរភាសា *CAMBODIAN SYSTEM OF WRITING AND BEGINNING READER*, New Haven, September 1969.

Gerald P. Delahunty and James J. Garvey, Language***, Grammar, Communication ACourse for Teachers of Englsh,***1994.

John Miller, Robert Bauer, David Thomas, Carolyn Miller, *mon-khmer studies, Thailand 2000*.

John Lyons, linguistique générale introduction à la linguistique théorique, Printed in France 1983.

OPHRYS : FAITS DE LANGUES Les CAhiers Numéro1 Paris 2009 277P.

ROBERT T. HARMS, *Introduction to PHONOLOGICAL THEORY, ...?*

ROBERT D. BORSLEY, ***SYNTACTIC THEORY A Unified Approach***, New York 1991.

Sadra C. Watts, PERFECTIVE AND IMPERFECTIVE ASPECT IN KHMER NARRTIVES, Long Beach 1998.

Viginia P. Clark, Paul A. Eschholz, Alfred F. Rosa, ***LANGUAGE readings in language and culturec sixth edition.*** New York 1998.

## ២- ស្នាដៃជាវេយ្យាករណ៍

### ២.១- ជាភាសាខ្មែរ

ក្រសួងអប់រំយុវជននិងកីឡា : ***វេយ្យាករណ៍ថ្នាក់ទី៥*** ភ្នំពេញ ១៩៨៣ ១៤៧ទំព័រ។

ក្រសួងអប់រំយុវជននិងកីឡា : ***វេយ្យាករណ៍ថ្នាក់ទី៦*** ភ្នំពេញ ១៩៨៣ ១៥០ទំព័រ។

ក្រសួងអប់រំយុវជននិងកីឡា : ***វេយ្យាករណ៍ថ្នាក់ទី៧*** ភ្នំពេញ ១៩៨៣ ២០២ទំព័រ។

ក្រសួងអប់រំយុវជននិងកីឡា : ***វេយ្យាករណ៍ថ្នាក់ទី៨*** ភ្នំពេញ ១៩៨៦ ...?ទំព័រ។

ខៀវ ជុំ ភិក្ខុ ធម្មបាលោក : វេយ្យាករណ៍យើង ភ្នំពេញ ១៩៦៦ ១៧៤ទំព័រ។

គង់ សុខហេង : ***វេយ្យាករណ៍ពិសេស*** ២០០៦។

គឹម សៃត :***វេយ្យាករណ៍ទំនើបនឹងវិធីសម្ពន្ធ*** កំពង់ចាម បណ្ណាគារ វង់រស្មី ១៩...? ១០៩ទំព័រ។

ឃិន សុខ :***វេយ្យាករណ៍ភាសាខ្មែរ*** ការផ្សាយនៃរាជបណ្ឌិតសភាកម្ពុជា ភ្នំពេញ ២០០៧ ៥០៨ ទំព័រ។

ច័ន្ទ សំណព្វ : ***យុគលពិន្ទុឬសញ្ញាចុចពីរ*** ភ្នំពេញ ២០១០ ២៤ទំព័រ។

ច័ន្ទ សំណព្វ : ***ដំណាក់ឃ្លាក្នុងភាសាខ្មែរ*** ភ្នំពេញ ២០១១ ៦៥ទំព័រ។

ច័ន្ទ សំណព្វ : ***សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*** ភ្នំពេញ ហ្វូណន ២០០៨ ១១២ទំព័រ។

ច័ន្ទ សំណព្វ : ***បង្កើតពាក្យ កម្វីពាក្យ បម្រើបម្រាស់ពាក្យ*** ភ្នំពេញ ២០១០ ១៨៥ទំព័រ។

ឆាយ សុខ : ***វេយ្យាករណ៍និងបំណិនសំខាន់ៗ*** ២០០២ ២៥១ទំព័រ។

ឱ.គាម : ***វេយ្យាករណ៍ខ្មែរ*** ភ្នំពេញ ១៩៥៤ បោះពុម្ពជាថ្មី ២០០៤ ដោយ គីន ប៊ុនថន។

ពៅ អ៊ុម, ញ៉ុក ថែម:***វេយ្យាករណ៍ខ្មែរ*** ភ្នំពេញ ១៩៧០ (ចម្លងឡើងវិញ១៩៨៨) ១១២ ទំព័រ។

ព្រុំ ម៉ល់ :***វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប*** (ភាគទី១)ភ្នំពេញ ២០០៦ ១៤៧ ទំព័រ។

ព្រុំ ម៉ល់ :***វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប*** (ភាគទី២)ភ្នំពេញ ២០០៦ ៧៦ទំព័រ។

ព្រុំ ម៉ល់ : ***មូលដ្ឋាននៃសង្គមភាសាវិទ្យា*** ភ្នំពេញ ២០០៣ ៣៩ទំព័រ។

ព្រុំ ម៉ល់ : ***មូលដ្ឋាននៃសូរវិទ្យា សទ្ទតាវិទ្យា និង វិជ្ជាសន្តាន*** ភ្នំពេញ ២០០៣ ៨៤ទំព័រ។

ព្រុំ ម៉ល់ : ***មូលដ្ឋាននៃន័យកម្មវិទ្យាទូទៅ,*** ភ្នំពេញ ២០០៣ ៥៣ទំព័រ។

ព្រុំ ម៉ល់ : ***សិក្សាកថា អំពីសញ្ញាប្រយោគមួយចំនួនក្នុងភាសាខ្មែរបច្ចុប្បន្ន, អំពីគុណនាមក្នុងភាសាខ្មែរបច្ចុប្បន្ន*** ភ្នំពេញ ២០១០ ៣៨ទំព័រ។

សុង ស៊ីវ : ***ភាសាវិទ្ធ*** ភ្នំពេញ? ១៩៥៨ ១០៤ទំព័រ។

សូ មុយ យៀង ថោង ផែល : ***វេយ្យាករណ៍ខ្មែរ*** ភ្នំពេញ ១៩៧១-១៩៧២ ១០៩ទំព័រ។

សេង នាង : ***បាឡីវេយ្យាករណ៍*** ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ ១៩៩៥ ២៧១ ទំព័រ។

អៀវ កើស ៖ ***ភាសាខ្មែរ*** ភ្នំពេញ បណ្ណាគារមិត្តសេរី ១៩៦៧ ៣៦៧ទំព័រ។

## ក្របខណ្ឌទ្រឹស្ដីនៃអន្តរកម្មនិយមនៅក្នុងការសិក្សា អន្តៈបទ/-ម-/និង/-ន-/នៅក្នុងភាសាខ្មែរ

បណ្ឌិត វង្ស មេង
អនុប្រធានវិទ្យាស្ថានភាសាជាតិ
រាជបណ្ឌិត្យសភាកម្ពុជា

### ១. ១. ទ្រឹស្ដីអន្តរកម្មនិយមប្រើប្រាស់នៅក្នុងការវិភាគ

ការស្រាវជ្រាវអំពីអន្តៈបទ យើងសង្កេតឃើញមានការប្រើប្រាស់ទ្រឹស្ដីមួយសំខាន់នៅក្នុងការវិភាគអំពីអន្តៈបទ ពោលគឺទ្រឹស្ដីអន្តរកម្មនិយម[១៩]។ មូលហេតុបានជាយើងយកទ្រឹស្ដីអន្តរកម្មនិយមនេះមកធ្វើការវិភាគ ពីព្រោះថាមូលដ្ឋានរូបសព្ទឬន័យវិទ្យាពុំមានលក្ខណៈគ្រប់គ្រាន់ នៅក្នុងការបង្កើតពាក្យតាមវិធីកម្លាយបានទេ ដោយសារតែទ្រឹស្ដីនីមួយៗពុំអាចឆ្លើយតបទៅនឹងការវិភាគបាតុភូត នៅក្នុងភាសាខ្មែរបាន។ ចំពោះទ្រឹស្ដីអន្តរកម្មនិយមវិញ ទ្រឹស្ដីនេះមានលក្ខណៈសំយោគរវាងទម្រង់និយមនិងន័យនិយម ដើម្បីបកស្រាយពីភាពចាំបាច់នៃការបង្កើតពាក្យដែលមានជាអាទិ៍ វិធីកម្លាយនេះតែម្ដង។ ដូច្នេះតើទ្រឹស្ដីអន្តរកម្មនិយមមានអត្ថន័យយ៉ាងដូចម្ដេច?

ទ្រឹស្ដីអន្តរកម្មនិយមជាទ្រឹស្ដីមួយនៅក្នុងការវិភាគភាសាវិទ្យា។ ទ្រឹស្ដីនេះ បានបង្ហាញថា៖ «*អន្តរកម្មនិយមជាចលនាសកម្មទ្វេទិសរវាងឯកតាភាសា[២០]មួយ ជាមួយសហបទ[២១]របស់វា នៅក្នុងយន្តការនៃការស្ថាបនាន័យរបស់ឯកតាភាសានោះ ដោយអនុលោមតាមបរិបទ[២២]មួយច្បាស់លាស់*»[២៣]។

តាមរយៈទ្រឹស្ដីអន្តរកម្មនិយមនេះ យើងសង្កេតឃើញអន្តៈបទ/-ម-/និង/-ន-/ដែលជាប្រធានបទនៃនិក្ខេបបទនេះអាចចាត់ទុកថាជាឯកតាភាសានៅក្នុងការសិក្សាផងនិងនៅក្នុងការស្វែងរកន័យរបស់វាផង។ ចំណែកឯ សហបទនោះវិញគឺរាល់ពាក្យឫសទាំងឡាយណាដែលធ្វើអន្តរកម្មជាមួយអន្តៈបទ/-ម-/

---

[១៩] ទ្រឹស្ដីអន្តរកម្មនិយមជាក្របខណ្ឌនៃទ្រឹស្ដីដែលបានបង្កើតឡើង ដោយអ្នកស្រាវជ្រាវខ្មែរម្នាក់ ពោលគឺសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ចាប់តាំងពីឆ្នាំ១៩៩៦មក ហើយបានក្លាយទៅជាប្រទីបនៃការស្រាវជ្រាវរបស់ក្រុមសិក្សាភាសាវិទ្យាខ្មែរបារាំងដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំងមកលើភាសាខ្មែរ។

[២០] ឯកតាភាសាអាចជា រូបសព្ទ វចនសព្ទ សទ្ទតា ឬ អាចជាពាក្យ មួយឃ្លា មួយល្បះ រហូតដល់អត្ថបទមួយ។ ឯកតាភាសានេះទៀតសោតជាចលករនៅក្នុងការស្ថាបនាន័យ។

[២១] សហបទជាវចនសព្ទ ពាក្យ ឬធាតុដែលចូលរួមធ្វើអន្តរកម្មជាមួយនឹងវចនសព្ទ ពាក្យ ឬធាតុណាមួយដែលវាមានតួនាទីជាចលករក្នុងការស្ថាបនាន័យឬស្ថាបនាប្រភេទពាក្យជាដើម។ ធាតុនៅទីនេះគឺចង់សំដៅទៅឯកតាភាសាមួយដែលស្ថិតក្នុងសំណុំឃ្លាឬសំណុំពាក្យណាមួយ ឬអាចជាពាក្យមួយ សំណុំឃ្លាឬសំណុំពាក្យណាមួយ។

[២២] បរិបទជាឯកតាភាសាដែលមាននៅជុំវិញធាតុណាមួយ។

[២៣] ច័ន្ទ សំណព្វ ***ទ្រឹស្ដីអន្តរកម្មនិយម*** ដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ភ្នំពេញ ឆ្នាំ២០០៥ ឯកសារប្រើប្រាស់ផ្ទៃក្នុង។

និង/-ន-/ ដើម្បីបង្កើតបានជាពាក្យកម្លាយនោះយើងហៅថាសហបទ។ នៅក្នុងន័យនេះ ឯកតាភាសាដែលជាចលករយ៉ាងសំខាន់នោះចាំបាច់ត្រូវមានសហបទមួយចូលរួមយ៉ាងសកម្ម ដើម្បីស្ថាបនាន័យមួយនៅក្នុងបរិបទមួយច្បាស់លាស់។ ជាក់ស្តែងនៅក្នុងអន្តបទ/-ម-/ និង/-ន-/ តាមវេយ្យាករណ៍ប្រពៃណី អន្តបទ/-ម-/មានតួនាទីសំខាន់នៅក្នុងការបង្កើតនាមភ្នាក់ងារ ហើយ អន្តបទ/-ន-/មានតួនាទីបង្កើតនាមឧបករណ៍។ ប៉ុន្តែតាមការពិត តាមរយៈទ្រឹស្តីអន្តរកម្មនិយម អន្តបទ/-ម-/ដែលជាឯកតាភាសាមួយយ៉ាងសំខាន់នោះចូលរួមអន្តរកម្មជាមួយពាក្យឫសបង្កើតបានប្រភេទពាក្យជាច្រើនបែប។ ការណ៍នេះយើងសូមលើកយកទឡ្ហីករណ៍មួយដែលបញ្ជាក់អំពីទ្រឹស្តីអន្តរកម្មនិយមដែលអាចអនុវត្តបាននៅក្នុងការវិភាគវិធីកម្លាយ ក៏ដូចជាការវិភាគអន្តបទ/-ម-/និង /-ន-/នៅក្នុងការស្រាវជ្រាវប្រធានបទនិក្ខេបបទនេះ។

*នៅក្នុងទ្រឹស្តីអន្តរកម្មនិយម មូលដ្ឋានរូបសព្ទឬន័យវិទ្យាពុំអាចមានលក្ខណៈគ្រប់គ្រាន់ នៅក្នុងការបង្កើតពាក្យតាមវិធីកម្លាយបានទេ ពីព្រោះទ្រឹស្តីនីមួយៗពុំអាចឆ្លើយតបទៅនឹងការវិភាគបាតុភូតនៅក្នុងភាសាខ្មែរបានឡើយ។ ទ្រឹស្តីនេះមានលក្ខណៈសំយោគរវាងទម្រង់និយមនិងន័យនិយម ដើម្បីបកស្រាយពីភាពចាំបាច់នៃការបង្កើតពាក្យដែលមានជាអាទិ៍ វិធីកម្លាយនេះឯង។ ជាការពិត ការកម្លាយពាក្យនៅក្នុងភាសាខ្មែរ ដោយប្រើផ្នត់ដើមឬផ្នត់ដែក[២៤] ពុំមែនចង់បង្កើតពាក្យដែលមានប្រភេទឬន័យខុសពីពាក្យដើមនោះទេ ប៉ុន្តែ ដើម្បីបង្កើតពាក្យដែលមានប្រភេទនិងមុខងារខុសពីពាក្យដើម។ ទ្រឹស្តីនេះបង្ហាញថាទម្រង់មិនមែនមានន័យដោយខ្លួនឯងនិងសម្ព័ន្ធពុំមែនជាធាតុចាំបាច់នៃភាសាទេ ហើយគេពុំអាចនិយាយពីន័យដែលគ្មានរូបនោះដែរ។ ភាពសំយោគនេះហើយដែលជាមូលដ្ឋាននាំឈាន ឆ្ពោះទៅរកការបង្កើតឡើងនូវទ្រឹស្តីថ្មីមួយដែលហៅថា«ទ្រឹស្តីអន្តរកម្មនិយម» (Interactionisme )[២៥]។ ប្រភេទពាក្យកម្លាយអាស្រ័យទៅលើអន្តរកម្មរវាងពាក្យឫសនិងទម្រង់ផ្នត់ដែលគេយកមកប្រើ[២៦] ។*

តាមរយៈអំណះអំណាងខាងលើ យើងអាចឆ្លុះបញ្ចាំងឲ្យឃើញថាអន្តរកម្មរវាងអន្តបទ/-ម-/និងពាក្យឫសចាំ លើស និង សិញ ផ្តល់ពាក្យកម្លាយផ្សេងគ្នាគឺឆ្មាំ ល្មើស និង ស្មិញ[២៧] ។ ឆ្មាំមានប្រភេទពាក្យជានាមសព្ទ ហើយ ល្មើសមានប្រភេទពាក្យជាកិរិយាសព្ទ នៅពេលដែលស្មិញមានប្រភេទពាក្យជាគុណនាមទៅវិញ។ ដូចគ្នានេះដែរ អន្តរកម្មរវាងអន្តបទ/-ម-/និងពាក្យឫស កើយ ទើស និង សើ ផ្តល់ពាក្យ

---

[២៤]គណៈកម្មាធិការជាតិភាសាខ្មែរបានផ្តល់ជម្រើសនៅក្នុងការប្រើប្រាស់ «ផ្នត់ដើមឬបុព្វបទ» ចំណែកឯ«ផ្នត់ដែកឬអន្តបទ»។ នៅក្នុងនិក្ខេបបទនេះ យើងបានជ្រើសរើសយក«អន្តបទ»ដែលអាចសមមូលទៅ«ផ្នត់ដែក»។ (សូមមើល៖ *ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ* លេខ៣ ឆ្នាំ២០១០ ទំព័រ៦១)

[២៥] ច័ន្ទ សំណព្វ ទ្រឹស្តីអន្តរកម្មនិយម ដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ភ្នំពេញ ឆ្នាំ២០០៥ ឯកសារប្រើប្រាស់ផ្ទៃក្នុង។

[២៦] ច័ន្ទ សំណព្វ បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ (អន្តរកម្មនិយម) រាជបណ្ឌិត្យសភាកម្ពុជា ការផ្សាយរបស់អ្នកនិពន្ធ ២០១០ ទំព័រ១៥៧។

[២៧] ពាក្យ«ស្មិញឬស្មេញ»មាននៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥។ តាមរយៈវចនានុក្រមនេះ ពាក្យ«ស្មិញឬស្មេញ»មានប្រភេទពាក្យជាគុណនាមហើយមានន័យថាល្អិតញឹកសិញ៖ ល្អិតស្មេញ។ សូមមើល៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ទំព័រ១៤៦០។

កម្លាយផ្សេងគ្នាគឺខ្ទើយ ឃ្មើស[២៨] និង ស្ទើ[២៩]។ ខ្ទើយមានប្រភេទពាក្យជានាមសព្ទ ឃ្មើសមានប្រភេទពាក្យជាគុណនាម ហើយ ស្ទើមានប្រភេទពាក្យជាកិរិយាសព្ទ។ ប្រការនេះជាលទ្ធផលដែលស្តែងឡើង តាមរយៈអន្តរកម្មរវាងអន្តែបទនិងពាក្យឫស។ ដូច្នេះ ការផ្តល់តួនាទីផ្តាច់មុខទៅឲ្យអន្តែបទ ក្នុងការកំណត់ប្រភេទពាក្យកម្លាយជាប្រការមិនសមស្របទេ។

## ១. ២. បច្ចេកសព្ទពាក់ព័ន្ធ

ការសិក្សាអំពីអន្តែបទនៅទីនេះ យើងសង្កេតឃើញមានបច្ចេកសព្ទមួយចំនួនដែលមានការជាប់ពាក់ព័ន្ធ។ បច្ចេកសព្ទទាំងនោះរួមមាន៖ វិធីកម្លាយ អក្ខសបទ អន្តែបទ មូលតា កាឡារូប និងអាគម។ ការបង្ហាញទាំងនេះមានសារៈសំខាន់នៅក្នុងការវិភាគ ក្នុងក្របខណ្ឌនៃការសិក្សា។ សូមអានសេចក្តីពិស្តារស្តីពីបច្ចេកសព្ទទាំងនេះ នៅក្នុងកថាភាគជាបន្តបន្ទាប់ដូចខាងក្រោម។

### ១.២.១. វិធីកម្លាយ

មានអ្នកស្រាវជ្រាវជាច្រើនបានសិក្សាពីវិធីកម្លាយ[៣០]នៅក្នុងភាសាខ្មែរ ក៏ប៉ុន្តែដោយសារការសិក្សារបស់យើងនៅទីនេះធ្វើឡើងតាមរយៈទ្រឹស្តីអន្តរកម្មនិយម ដូច្នេះ យើងលើកយកតែគោលគំនិតនៃវិធីកម្លាយដែលមានការជាប់ទាក់ទងទៅនឹងទ្រឹស្តីនេះតែប៉ុណ្ណោះ ដើម្បីឲ្យមានភាពស្របគ្នាទៅនឹងខ្លឹមសារនៃការសិក្សា នៅក្នុងនិក្ខេបបទនេះ។

តាមរយៈទ្រឹស្តីអន្តរកម្មនិយម យើងសង្កេតឃើញថា៖ *«វិធីកម្លាយជាវិធីបង្កើតពាក្យដោយប្រើផ្នត់មកកម្លាយឫស ដើម្បីបង្កើតជាពាក្យថ្មី ទោះបីផ្នត់នោះជាផ្នត់ដើមក្តីឬជាផ្នត់ដែកក្តី ... ផ្នត់ផ្សេងៗដែលខ្មែរបានប្រើក្នុងការកម្លាយពាក្យរហូតមកដល់បច្ចុប្បន្នកាលនេះមានពីរប្រភេទ គឺ ផ្នត់ដើម និង ផ្នត់ដែក»*[៣១]។

---

[២៨] តាមវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ពាក្យ«ឃ្មើស»មានប្រភេទពាក្យជាគុណនាមដែលមានន័យថាដែលទើស, ទាក់, ទាស់ : ឃ្មើសចិត្ត ។ សូមមើល៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ ទំព័រ១៦២។

29 ពាក្យនេះមាននៅក្នុងវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ វាមានប្រភេទពាក្យជាកិរិយាសព្ទ ដោយមានន័យថាសួរឲ្យដឹងសិន, ពិគ្រោះឬប្រឹក្សាមុនសិន ។ សូមមើល៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ ទំព័រ ១៤៥៩។

[៣០] គណៈកម្មាធិការជាតិភាសាខ្មែរបានផ្តល់និយមន័យថា៖«វិធីកម្លាយជាវិធីមួយនៃការបង្កើតពាក្យចេញពីពាក្យឫស/ឫស តាមរយៈផ្នត់/អក្ខសបទ»។ សូមមើល៖ ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៣ ឆ្នាំ២០១០ ទំព័រ៦៣។

[៣១] ច័ន្ទ សំណព្វ «បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ» ភ្នំពេញ ២០១០ ទំព័រ២៤-២៥។ ផ្នត់ដើមជាធាតុវេយ្យាករដែលប្រើដាក់នៅខាងដើមព្យញ្ជនៈដើមព្យាង្គនៃឫស ដើម្បីកម្លាយឫសនោះឲ្យកើតបានជាពាក្យថ្មីមួយ។ វាមានលក្ខណៈខុសពីបុរបទនិងបុរេសព្ទ ដោយសារតែវាមានទម្រង់ច្រើននិងមានតួនាទីទៅតាមទម្រង់នីមួយៗ ហើយ លក្ខណៈសម្ព័ន្ធរបស់វាក៏ប្លែកគ្នាដែរ។ នៅក្នុងទម្រង់នីមួយៗមានផ្នត់ជាច្រើន ហើយ ផ្នត់នីមួយៗត្រូវបានប្រើប្រាស់ដោយអនុលោមទៅតាមឫសដែលគេយកមកកម្លាយ។ ដោយផ្អែកទៅលើទម្រង់របស់វា ផ្នត់ដើមខ្លះអាចបង្កើតពាក្យកម្លាយដែលមានប្រភេទពាក្យដូចពាក្យឫស ហើយ ខ្លះទៀតបង្កើតបានជាពាក្យកម្លាយដែលមានប្រភេទខុសពីពាក្យឫស។ ឧទាហរណ៍ ពាក្យឫស *កាយ*

តាមរយៈការបង្ហាញខាងលើ គោលគំនិតនោះគឺ«*វិធីកម្លាយគឺជាវិធីបង្កើតពាក្យថ្មី តាមរយៈអន្តរកម្មរវាងឫសនិងផ្នត់ដែលជាធាតុសំខាន់ក្នុងវិធីនេះ ដើម្បីបំប្លែងឫសឲ្យកើតបានទៅជាពាក្យថ្មីមួយដែលអាចមានឬគ្មានប្រភេទពាក្យដូចពាក្យឫស*»។ ឧទាហរណ៍ ពាក្យឫស រៀន ជាកិរិយាសព្ទ ពេលគេកម្លាយវាតាមរយៈផ្នត់ដើម/ប'ង-/ ពាក្យកម្លាយ បង្រៀន ដែលបានមកក៏មានប្រភេទពាក្យជាកិរិយាសព្ទដែរ។ ផ្ទុយទៅវិញ ផ្នត់ដើម /ក-/ ក្នុងទម្រង់/ព-/កម្លាយពាក្យឫស បាំង ដែលមានប្រភេទជាកិរិយាសព្ទឲ្យកើតបានទៅជាពាក្យថ្មី ក្បាំង[៣២] ដែលមានប្រភេទជានាមសព្ទទៅវិញ។

សរុបសេចក្តីមក យើងសង្កេតឃើញថាភាសាខ្មែរពិតជាមានវិធីកម្លាយ ហើយវិធីកម្លាយដែលយើងប្រើប្រាស់សព្វថ្ងៃគឺត្រូវគេស្គាល់ជាទូទៅ ជាពិសេស ការសិក្សានៅមធ្យមសិក្សារហូតដល់មហាវិទ្យាល័យនិងការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ដែលរួមមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត ថែមទៀតផង។ តាមរយៈការបង្ហាញជូនអំពីវិធីកម្លាយនេះ យើងយល់ឃើញថាវិធីកម្លាយនៅក្នុងភាសាខ្មែរគឺសំដៅដល់ការបង្កើតពាក្យថ្មី ដោយប្រើផ្នត់ ហើយ ផ្នត់ដែលមានការប្រើប្រាស់នៅក្នុងភាសាខ្មែរនោះទៀតសោតគឺមានផ្នត់ដើមនិងផ្នត់ដែក។ ម្យ៉ាងវិញទៀត ការយកពាក្យ«ផ្នត់»មកប្រើបែបនេះគឺជារឿងសក្តិសមនឹងឈ្មោះនេះណាស់។ ការប្រើប្រាស់បែបនេះមានភស្តុតាងមួយបានសរសេរបញ្ជាក់ថា៖«...*ពាក្យ ផ្នត់ ជាពាក្យខ្មែរ ហើយជាពាក្យកម្លាយដែលត្រូវប្រើនឹងតួនាទីរបស់ផ្នត់ ក្នុងការកម្លាយពាក្យខ្មែរថែមទៀតផង*»[33] ។ដូច្នេះ យើងអាចសរុបបានថា«*វិធីកម្លាយគឺជាវិធីបង្កើតពាក្យថ្មី តាមរយៈអន្តរកម្មរវាងពាក្យឫសនិងផ្នត់ដើម្បីបង្កើតបានជាពាក្យថ្មីមួយដែលមានឬគ្មានប្រភេទពាក្យដូចពាក្យឫស*។» ប្រការនេះបណ្តាលមកពី «ផ្នត់» ក៏ជាពាក្យកម្លាយពីឫស«បទ» តាមរយៈអន្តេបទឬផ្នត់ដែក/-ន-/ ក្នុងទម្រង់ /-ព-/។

### ១.២.២. អព្ភាសបទ

ពាក្យ«អព្ភាសបទ»ជាបច្ចេកសព្ទដែលមានការប្រើប្រាស់នៅក្នុងស្នាដៃ របស់លោក សាស្ត្រាចារ្យ កេង វ៉ាន់សាក់ ស្តីអំពី«មូលភាពនៅក្នុងការបង្កើតពាក្យថ្មី»[៣៤]។ យើងបានយកពាក្យនេះមកប្រើនិងប្រើតាមគណៈកម្មាធិការជាតិភាសាខ្មែរផង និងដើម្បីប្រើឲ្យមានឯកភាពគ្នាផង។ ហេតុដូច្នេះ តើអ្វីទៅជា«អព្ភាសបទ»? ពាក្យនេះជាពាក្យដែលយើងបានប្រើប្រាស់នៅក្នុងនិក្ខេបបទ អាស្រ័យហេតុនេះ យើង

---

*ជាកិរិយាសព្ទ ពេលគេកម្លាយវាតាមរយៈផ្នត់ដើម[ក-] ក្នុងទម្រង់ /ពស/ ពាក្យកម្លាយ***កកាយ** *ដែលបានមកក៏មានប្រភេទជាកិរិយាសព្ទដែរ។ ឧទាហរណ៍៖ កាយ + [ក-] >កកាយ (ទំព័រ៩៤)។ ចំណែកឯ វេយ្យាករ នៅក្នុងបរិបទនេះ មានមុខងារជាគុណនាមដែលបញ្ជាក់ពីប្រភេទនៃមុខងារ។ ហេតុនេះ វាពុំមាន* **ណ៍** *នៅខាងចុងទេ។* **មុខងារវេយ្យាករ** *(fonction grammatical) ខុសពី* **មុខងារវេយ្យាករណ៍** *(fontion de la grammaire) (ទំព័រ៨៧)។*

[៣២] *ឧទាហរណ៍នេះ យើងខ្ចីពីសាស្ត្រាចារ្យ ច័ន្ទ សំណព្វ។*

[៣៣] *ច័ន្ទ សំណព្វ បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ ដ.ឯ.ម. ទំព័រ៩៥។*

[៣៤] *សូមមើល៖ កេង វ៉ាន់សាក់ មូលភាពនៃការបង្កើតពាក្យថ្មី ដ.ឯ.ម. ទំព័រ១៤២-១៤៣។*

លើកយកពាក្យនេះមក ដើម្បីជាពន្លឺនៃការសិក្សានិក្ខេបបទរបស់យើង។

គណៈកម្មាធិការជាតិភាសាខ្មែរបានប្រើប្រាស់បច្ចេកសព្ទ «អព្ភាសបទឬផ្នត់» ដោយបច្ចេកសព្ទនេះត្រូវនឹងពាក្យ «Affix» នៃភាសាអង់គ្លេសនិងពាក្យ«Affixe» នៃភាសាបារាំង។ ពាក្យនេះគណៈកម្មាធិការជាតិភាសាខ្មែរបានកំណត់និយមន័យថា៖

*«អព្ភាសបទជារូបតាសម្រាប់ប្រើដើម្បីបង្កើតពាក្យកម្លាយ/កម្លាយលើកម្លាយ សម្រាប់ ភ្ជាប់នឹង៖ ពាក្យឫស ដឹង + អព្ភាសបទ/ផ្នត់ [ប៉-] > ប្ដឹង, ពាក្យកម្លាយ ម្ដងហើយ ប្ដឹង + អព្ភាសបទ/ផ្នត់ [-អ'ណ-] > បណ្ដឹង, ឫសក្នុងភាសាបារាំង, ឧទាហរណ៍៖ · all + អព្ភាសបទ/ផ្នត់ er > aller; · form + អព្ភាសបទ/ផ្នត់ (-tion)> (formations)...»*[៣៥] ។

តាមការបង្ហាញខាងលើរបស់គណៈកម្មាធិការជាតិភាសាខ្មែរ យើងសង្កេតឃើញ«អព្ភាសបទឬផ្នត់»គឺជារូបតា។ រូបតានេះគឺមូលតាមួយបែបដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសា ប៉ុន្តែអព្ភាសបទនេះមានមុខងារនៅវេយ្យាករណ៍ជាមួយពាក្យឫស ក្នុងការបង្កើតពាក្យកម្លាយផងប្រើជាមួយពាក្យកម្លាយដែលជាវចនស័ព្ទ ដើម្បីបង្កើតជាពាក្យកម្លាយថ្មីមួយទៀត។

ចំពោះការសិក្សាតាមបែបទ្រឹស្ដីអន្តរកម្មនិយមវិញ យើងសង្កេតឃើញមានប្រើប្រាស់បច្ចេកសព្ទ«ធាតុវេយ្យាករ»។ ធាតុវេយ្យាករបានជាសរសេរបែបនេះពីព្រោះ៖« *វេយ្យាករ នៅក្នុងបរិបទនេះ មានមុខងារជាគុណនាមដែលបញ្ជាក់ពីប្រភេទនៃ ធាតុ ។ ហេតុនេះ វាពុំមាន ណ៍ នៅខាងចុងទេ។ ធាតុវេយ្យាករ (éléments grammatical) ខុសពីធាតុវេយ្យាករណ៍ (èléments de la grammaire)*»[៣៦] ។នៅក្នុងបច្ចេកស័ព្ទ«ធាតុវេយ្យាករ» បានពិពណ៌នាអំពី បុព្វបទ អន្តរបទ និងបច្ឆិមបទ[៣៧]។ អន្តរកម្មនិយមបានចែកបុព្វបទជាបីប្រភេទគឺមាន បុរេបទ បុរេសព្ទ និង ផ្នត់ដើម ចំណែកឯ អន្តរបទវិញ ទ្រឹស្ដីនេះបែងចែក

---

[៣៥] ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរលេខ៣ ឆ្នាំ២០១០ ទំព័រ៦០-៦១។

អព្ភាសបទរបស់លោក កេង វ៉ាន់សាក់ យើងសង្កេតឃើញថាវាមាននិយាយអំពីអព្ភាសបទបាឡី-សំស្ក្រឹតផង។ *ចំណែកឯការសិក្សារបស់លោក អៀវ កើស ក៏មានការជាប់ទាក់ទងទៅនឹង«Affix»នេះផងដែរ។ លោក អៀវ កើស បានប្រើបច្ចេកស័ព្ទ«បទភ្ជាប់»ដែលជាកន្ទេចពាក្យភ្ជាប់ទៅនឹងភាសាបារាំងហៅថា«Affixes» ដោយលោកបានសរសេរថា៖«កន្ទេចពាក្យនោះខ្ញុំសូមសន្មតឈ្មោះជា បទភ្ជាប់ (affixes)។ កាលបើលោកដាក់បទភ្ជាប់បីខាងមុខមូលបទ លោកហៅថា ឧបសគ្គ ឬ បុព្វបទ, (préfixe)។ ឧ. អនុ + លោម > អនុលោម bi + pède > bipède លោម, pède ជាមូលបទ, racines; អនុ, bi ជាបុព្វបទ, préfixes ។ បុព្វបទ ប្រែថា មុន, បុព្វបទ=បទមុន។ បទភ្ជាប់ កាលបើលោកដាក់ពីក្រោយមូលបទ លោកហៅថាបច្ច័យ (suffixe)។ ឧ. ទា + អក > ទាយកgrand + eur > grandeur អក, eur ជាបច្ច័យ (suffixe)។ បច្ច័យក្នុងភាសាអំបូរមន ខ្មែរ គ្មានប្រើទេ មានប្រើតែបុព្វបទ។ មែនពិត ...បទភ្ជាប់នោះយើងដាក់ ជៀតជ្រែកកណ្ដាលមូលបទ ។ បារាំងហៅថាinfixe,ខ្ញុំសូមសន្មតឈ្មោះជា បទជ្រែក។អៀវ កើស* ***ភាសាខ្មែរ (ការល្បងពិនិត្យដោយរកហេតុផល)*** *ដ.ឯ.ម. ទំព័រ១៦៨-១៦៩។*

[៣៦] ច័ន្ទ សំណព្វ ***បង្កើតពាក្យ កម្មីពាក្យ បម្រើបម្រាស់ពាក្យ*** ដ.ឯ.ម. ទំព័រ៨៧។

[៣៧] ដដែល ទំព័រ៨៧-១២៦។

ជាពីរគឺ ផ្នត់ដែកនិងស្នៀត នៅពេលខណៈពេលការសិក្សាអំពីបច្ឆិមបទមានបច្ច័យបទនិងបច្ច័យសព្ទ។

ការសិក្សាអំពីធាតុវេយ្យាករនៅក្នុងទ្រឹស្ដីអន្តរកម្មនិយម យើងសង្កេតឃើញថាផ្នត់ដើមជាផ្នែកមួយនៃបុព្វបទ ចំណែកឯ ផ្នត់ដែកជាផ្នែកមួយនៃអន្តរបទ ចំណែកឯធាតុវេយ្យាករគឺក្ដោបលើបុព្វបទផងអន្តរបទផង និងបច្ឆិមបទផង។ ដោយពិនិត្យមើលទៅ យើងឃើញថាអញ្ញាសបទមានលក្ខណៈប្រហាក់ប្រហែលទៅនឹងធាតុវេយ្យាករនៃការសិក្សាតាមរយៈអន្តរកម្មនិយម។ ដោយឡែក អញ្ញាសបទរបស់លោក កេង វ៉ាន់សាក់មាន បុព្វបទ អន្តរាបទ និងបច្ឆិមបទ នៅពេលដែលគណៈកម្មាធិការជាតិភាសាខ្មែរ[៣៨]បានបង្ហាញថា អញ្ញាសបទមាន បុព្វបទ/ផ្នត់ដើម អន្តេបទ/ផ្នត់ដែក និងបច្ឆិមបទ/ផ្នត់ចុង។

សរុបសេចក្ដីមក យើងសង្កេតឃើញថាបច្ចេកសព្ទ«អញ្ញាសបទ»កើតអំឡុងនៅទសវត្សឆ្នាំ១៩៦៥ ដោយសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ចំណែកឯបច្ចេកស័ព្ទ«បទភ្ជាប់»បានកើតឡើងនៅឆ្នាំ១៩៤៧ ដោយ លោក អៀវ កើស។ លើសពីនេះ យើងក៏ឃើញមានបច្ចេកសព្ទ«ផ្នត់»ដែលទំនងជាកើតឡើង នៅក្នុងអំឡុងទសវត្សទី៨០ ដោយក្រសួងអប់រំ។ លោក កេង វ៉ាន់សាក់និងលោក អៀវ កើស បានប្រើបច្ចេកសព្ទនេះសមមូលទៅនឹងភាសាបារាំងថា«Affixe» ហើយម្យ៉ាងវិញទៀត គណៈកម្មាធិការជាតិភាសាខ្មែរបានប្រើបច្ចេកសព្ទ «អញ្ញាសបទឬផ្នត់» ដោយមានបច្ចេកសព្ទអង់គ្លេស «Affix»និងភាសាបារាំង«Affixe» ចំណែកឯ សាស្ត្រាចារ្យ ច័ន្ទ សំណព្វ បានប្រើបច្ចេកសព្ទ «ធាតុវេយ្យាករ» ដោយគ្របដណ្ដប់ទៅលើបុព្វបទ អន្តរបទ និងបច្ឆិមបទ។ បើទោះបីជា លោក អៀវ កើស បានប្រើប្រាស់បច្ចេកសព្ទ«បទភ្ជាប់»មុនគេក៏ដោយ ក៏ប៉ុន្តែការសិក្សារបស់គាត់មានលក្ខណៈដូច affixes នៃភាសាបារាំងផង និង ដូច racines primaire របស់លោក Joseph Guesdon ផង។ ការណ៍នេះ គណៈកម្មាធិការជាតិភាសាខ្មែរបានបញ្ជាក់យ៉ាងច្បាស់ថា៖

*សៀវភៅរបស់លោក អៀវ កើស បានបោះពុម្ពច្រើនឆ្នាំក្រោយពីអ្នកនិពន្ធទទួលមរណភាព៖ ដូច្នេះ ពាក្យ បទភ្ជាប់ ប្រើក្នុងសៀវភៅនេះ ទំនងជាបានបង្កើតឡើងមុន ពាក្យអញ្ញាសបទ របស់លោក កេង វ៉ាន់សាក់។ អ្នកនិពន្ធ អៀវ កើស បានដាក់ពាក្យបារាំង Affixes ជាប់នឹងពាក្យ បទភ្ជាប់ ប៉ុន្តែ បទភ្ជាប់ ដែលគាត់បានស្រង់នោះមាន លក្ខណៈដូច Affixes នៃភាសាបារាំងផង និង ដូច racines primaires របស់លោក* Joseph Guesdon ផង[៣៩]។

សរុបសេចក្ដីមក បច្ចេកសព្ទទាំងប៉ុន្មានខាងលើដែលយើងបានពិចារណា យើងយល់ឃើញថា

---

[៣៨] សូមមើល៖ ***ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ*** លេខ៣ ឆ្នាំ២០១០ ទំព័រ៦០-៦២។ នៅក្នុងការពន្យល់របស់គណៈកម្មាធិការជាតិមិនបានបង្ហាញថាអញ្ញាសបទចែកចេញជាប៉ុន្មាននោះទេ ប៉ុន្តែយើងអាចពិនិត្យមើលទៅលើនិយមន័យ **បុព្វបទ/ផ្នត់ដើម អន្តេបទ/ផ្នត់ដែក** និង**បច្ឆិមបទ/ផ្នត់ចុង**។ និយមន័យទាំងបីនោះគឺ សុទ្ធតែបង្ហាញថាវាទាំងនោះគឺជាអញ្ញាសបទឬផ្នត់។ តាមការពន្យល់នោះ ធ្វើឲ្យយើងធ្វើសន្និដ្ឋានបានថាអញ្ញាសបទមានបីប្រភេទដូចបានរៀបរាប់ខាងលើ។

[៣៩] ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៣ ឆ្នាំ២០១០ ទំព័រ៦០។

នៅក្នុងបរិបទនៃការសិក្សាភាសាអំពីបច្ចេកសព្ទ«Affix»នៃភាសាអង់គ្លេសឬ «Affixe» នៃភាសាបារាំងមានការប្រែប្រួលទៅតាមដំណាក់កាលនិងបញ្ញត្តិផ្ទាល់របស់អ្នកនិពន្ធ។ បញ្ញត្តិទាំងនេះយើងអាចនិយាយដោយសង្ខេបថា នៅក្នុងបរិបទនៃការបកប្រែយើងគួរបកប្រែបច្ចេកសព្ទ «AffixឬAffixe» ជាអព្ភាសបទទៅតាមគណៈកម្មាធិការជាតិភាសាខ្មែរ ចំណែកឯការសិក្សាអំពីបរិបទនៃភាសាខ្មែរយើងគួរធ្វើឡើងនៅក្នុងសង្គមខ្មែរ ពីព្រោះថា ភាសាខ្មែរមានលក្ខណៈពិសេសដែលភាសាខ្លះគ្មាន។ យើងប្រើប្រាស់«អព្ភាសបទឬផ្នត់»ទៅតាមគណៈកម្មាធិការជាតិភាសាខ្មែរ ដើម្បីឲ្យមានឯកភាព ពីព្រោះថាគណៈកម្មាធិការជាតិភាសាខ្មែរជាស្ថាប័នដែលកំពុងតែស្វែងរកឯកភាពជាតិខាងភាសាខ្មែរជូនជនរួមជាតិក៏ដូចជាអ្នកប្រើប្រាស់ភាសាខ្មែរទូទៅផងដែរ។

### **១.២.៣. អន្តោបទ**

អន្តោបទ[៤០]ត្រូវនឹងពាក្យ«infix»នៃភាសាអង់គ្លេសនិង«infixe»នៃភាសាបារាំង។ ចំពោះដំណើរការឬវិធីវិញ យើងខ្ញុំសន្មតហៅថាអន្តោបទនីយកម្មឬអន្តោបទវិធីឬផ្នត់ដែកនីយកម្មត្រូវនឹងពាក្យ«infixation» នៃភាសាអង់គ្លេស។

គណៈកម្មាធិការជាតិភាសាខ្មែរបានផ្តល់និយមន័យនៃពាក្យអន្តោបទដែលមានខ្លឹមសារដូចជា៖ « *អន្តោបទ/ផ្នត់ដែកគឺជាអព្ភាសបទ/ផ្នត់មួយបែបដែលគេដាក់ជ្រៀតចូលក្នុងពាក្យ ដើម្បីបង្កើតជាពាក្យកម្លាយ ឧទាហរណ៍៖ ចាំ+[-ម-]> ចំណាំ, គាប+[-ន-]> ឃ្នាប...*»[៤១]។

តាមរយៈនិយមន័យនេះ យើងសង្កេតឃើញថា អន្តោបទគឺជាអព្ភាសបទឬផ្នត់មួយបែបដែលមានតួនាទីសម្រាប់បង្កើតពាក្យកម្លាយ ដោយយកអន្តោបទនោះដាក់បញ្ចូលទៅក្នុងពាក្យ។ ដូចនៅក្នុងឧទាហរណ៍ខាងលើបង្ហាញស្រាប់ អន្តោបទ/-ម-/បានដាក់បញ្ចូលទៅក្នុងពាក្យកិរិយាសព្ទ ចាំ ដើម្បីបង្កើតនាមសព្ទកម្លាយ ចំណាំ ដែលជានាមភ្ជាក់ងារ។ ដូចគ្នានេះដែរ អន្តោបទ/-ន-/ដាក់បញ្ចូលទៅក្នុងពាក្យគាប ដើម្បីបង្កើតបានពាក្យកម្លាយ ឃ្នាប ដែលជានាមឧបករណ៍។

ដោយសារតែការសិក្សារបស់យើងផ្អែកលើទ្រឹស្តីអន្តរកម្មនិយម យើងសូមលើកយកខ្លឹមសារ

---

[៤០] **អន្តោបទ** គណៈកម្មាធិការជាតិភាសាខ្មែរបានសម្រេចនិងប្រើប្រាស់បច្ចេកសព្ទនេះ ដោយវាអាចសមមូលទៅនឹងពាក្យថា**ផ្នត់ដែក** ដូច្នេះ នៅក្នុងនិក្ខេបបទរបស់យើងខ្ញុំបានប្រើប្រាស់បច្ចេកសព្ទទាំងពីរនេះ ដោយមានការផ្លាស់ប្តូរគ្នា។ ដោយឡែក លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ បានប្រើបច្ចេកសព្ទអន្តរាបទដែលសមមូលទៅនឹងinfixe នៃភាសាបារាំង ក៏ប៉ុន្តែ លោកសាស្ត្រាចារ្យ នៅ ស៊ុន បានផ្តល់យោបល់ថា *«អន្តរ/អន្តរា» មានន័យដូច «inter» នៃភាសាបារាំង ឧ. អន្តរជាតិ=international, អន្តរក្រសួង=inter-service... ដូច្នេះ វាក្យសព្ទ«អន្តរាបទ»របស់លោក កេង វ៉ាន់សាក់ ត្រូវគ្នានឹង«interfixe» ដែលមានក្នុងភាសារុស្ស៊ី គឺមិនមែន«infixe»ទេ គប្បីយើងប្រែពាក្យ«infixe»ថា«អន្តោបទ»វិញ*។ សូមមើល៖ ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៣ ឆ្នាំ២០១០ ទំព័រ៦១។ លោក អៀវ កើស បានប្រើបច្ចេកសព្ទ **បច្ច័យជ្រែក** ដែលសមមូលទៅនឹងinfixe នៅក្នុងភាសាបារាំង។ សូមមើល៖ អៀវ កើស ***ភាសាខ្មែរ(ការល្បងពិនិត្យដោយរកហេតុផល)*** ជ.ឯ.ម. ទំព័រ១៧៧។

[៤១] ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៣ ឆ្នាំ២០១០ ទំព័រ៦១។

ដែលទាក់ទងទៅនឹងអន្តែបទឬផ្នត់ដែកនេះមកបង្ហាញជូនដូចខាងក្រោម៖

យោងតាមទ្រឹស្តីអន្តរកម្មនិយម ផ្នត់ដែក គឺចង់សំដៅទៅលើ *«ធាតុវេយ្យាករប្រើដាក់នៅចន្លោះធាតុនៃពាក្យឬសមួយ ដើម្បីកម្លាយវាឲ្យកើតបានទៅជាពាក្យថ្មីមួយ។ ដោយអនុលោមទៅតាមលក្ខណៈនៃពាក្យឬសនិងទម្រង់ផ្នត់ដែលគេប្រើពាក្យកម្លាយដែលបានមកអាចមានប្រភេទពាក្យដូចគ្នាឬមិនដូចគ្នានឹងពាក្យឬស។ ឧទាហរណ៍ ផ្នត់ដែកទម្រង់[-ព-] អាចកម្លាយពាក្យឬស កើត ដែលជាកិរិយាសព្ទ ឲ្យបានទៅជាពាក្យកម្លាយដែលមានប្រភេទជានាមសព្ទ។ ឧទាហរណ៍ កើត + [-ន-] > ខ្នើត, កើត + [-ម-] > ខ្មើត»*[៤២] ។

តាមរយៈឧទាហរណ៍នេះ យើងអាចដឹងបានថាអន្តរកម្មរវាងពាក្យឬស កើត ដែលជាកិរិយាសព្ទ និងអន្តែបទឬផ្នត់ដែក/-ន-/ បង្កើតបានជាពាក្យកម្លាយ ខ្នើត ដែលមានប្រភេទពាក្យជានាមសព្ទខុសពីពាក្យឬស។ ជាមួយគ្នានេះផងដែរ អន្តរកម្មរវាងកិរិយាសព្ទ កើត ជាមួយអន្តែបទឬផ្នត់ដែក[-ម-] បង្កើតបានជាពាក្យកម្លាយ ខ្មើត ដែលមានប្រភេទពាក្យជានាមភ្នាក់ងារខុសពីពាក្យឬស។ លទ្ធផលនេះសបញ្ជាក់ឲ្យឃើញថាពាក្យកម្លាយដែលកើតមកអំពីអន្តរកម្មរវាងពាក្យឬស និង ផ្នត់គឺស្តែងឲ្យឃើញថាផ្នត់មិនមែនជាអ្នកផ្តល់តួនាទីផ្តាច់មុខនៅក្នុងការកំណត់ប្រភេទពាក្យនៃពាក្យកម្លាយនោះទេ។ ប្រភេទពាក្យកម្លាយគឺអាស្រ័យទៅលើអន្តរកម្មរវាងពាក្យឬសនិងផ្នត់នៅក្នុងបរិបទមួយកំណត់ច្បាស់លាស់។

## សន្និដ្ឋាន

ជាសន្និដ្ឋាន តាមការបង្ហាញអំពីនិយមន័យនៃអន្តែបទខាងលើ យើងសង្កេតឃើញថាលទ្ធផលនៃនិយមន័យទាំងពីរគឺមានលក្ខណៈដូចគ្នាត្រង់ថា អន្តែបទមានតួនាទីមួយសម្រាប់បង្កើតពាក្យកម្លាយ។ ដោយនិយមន័យនៃគណៈកម្មាធិការជាតិភាសាខ្មែរ អន្តែបទដាក់ជ្រៀតចូលទៅក្នុងពាក្យឬស ដើម្បីបង្កើតពាក្យកម្លាយ ចំណែកឯ ទ្រឹស្តីអន្តរកម្មនិយមវិញ អន្តែបទឬផ្នត់ដែកចូលរួមយ៉ាងសកម្មជាមួយពាក្យឬស បង្កើតបានពាក្យកម្លាយដែលអាចមានប្រភេទពាក្យដូចឬខុសពីពាក្យឬស ហើយ ប្រភេទនៃពាក្យកម្លាយគឺវាអាស្រ័យទៅនឹងអន្តរកម្មរវាងពាក្យឬសនិងផ្នត់។ នៅក្នុងការសិក្សារបស់យើងនៅទីនេះ យើងបានប្រើប្រាស់ទ្រឹស្តីអន្តរកម្មនិយមសម្រាប់ធ្វើការវិភាគទៅលើអន្តែបទឬផ្នត់ដែក/-ម-/និង/-ន-/។ អាស្រ័យហេតុនេះ ទ្រឹស្តីអន្តរកម្មនិយមបានឆ្លុះបញ្ចាំងឲ្យឃើញថាអន្តរកម្មរវាងអន្តែបទ /-ម-/និង/-ន-/ គឺជាឯកតាភាសាដែលជាចលករចូលរួមយ៉ាងសកម្ម នៅក្នុងការបង្កើតពាក្យកម្លាយ ក៏ប៉ុន្តែការចូលរួមនេះគឺមិនមែនអន្តែបទទាំងពីរនេះជាអ្នកកំណត់ប្រភេទពាក្យ ឬ ជាអ្នកកំណត់ន័យឲ្យពាក្យកម្លាយនោះក៏មិនមែនដែរ។ អន្តែបទទាំងពីរនេះគឺគ្រាន់តែចលករដែលចូលរួមជាមួយនឹងពាក្យឬស នៅក្នុងការស្ថាបនាន័យ ដោយអនុលោមទៅតាមបរិបទកំណត់មួយច្បាស់លាស់។

[៤២] ច័ន្ទ សំណព្វ ***«បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ»*** ភ្នំពេញ ២០១០ ទំព័រ១១២-១១៣។

### ១.២.៤. មូលតា

បច្ចេកសព្ទ«មូលតា[៤៣]»ត្រូវគណៈកម្មាធិការជាតិភាសាខ្មែរបានអនុម័ត ដោយបច្ចេកសព្ទនេះសមមូលទៅនឹងភាសាអង់គ្លេសថា «morpheme» និងភាសាបារាំងថា«monème»។ បច្ចេកសព្ទនេះផងដែរ យើងសង្កេតឃើញគណៈកម្មាធិការជាតិភាសាខ្មែរបានពន្យល់ថា៖

*«មូលតា ជាការបកប្រែពាក្យ «monème» ដែលលោក André Martinet បានកំណត់ន័យថា ជាឯកតាអប្បបរមាដែលមានន័យ ដូច៖ ក្នុងភាសាបារាំង៖ voilà ton père មានមូលតាចំនួនបី៖ voilà, ton, père; embarquons មានមូលតាចំនួនបី៖ em-, barqu-, -ons ។ ក្នុងភាសាខ្មែរ៖ ពាក្យ ឆ្មាំ មានមូលតាចំនួនពីរ៖ ចាំ និង អន្តោបទ/ផ្នត់ ដែក [-ម-], ពាក្យ ឃ្នាប មានមូលតាចំនួនពីរ៖ គាប និង អន្តោបទ/ផ្នត់ដែក [-ន-] មូលតាអាចជាវចនតា ឬ រូបតា »[៤៤]។*

ន័យដូចបានបង្ហាញរបស់គណៈកម្មាធិការខាងលើ ឆ្លុះបញ្ចាំងតាមរយៈគំនិតរបស់លោក អង់ដ្រេម៉ាទីណេ។ ដោយផ្អែកលើការពន្យល់នេះ យើងសង្កេតឃើញថាមូលតាអាចជាវចនតា[៤៥]ឬរូបតា[៤៦]។ ឆ្លងតាមការពន្យល់នេះ យើងសង្កេតឃើញថា មូលតាអាចជាពាក្យទោល ពាក្យឫស និងជាធាតុ នៅក្នុងភាសា។

ទាក់ទងទៅនឹង«Morpheme» សព្វវចនាធិប្បាយអង់គ្លេសបានសរសេរថា៖ «*នៅក្នុងភាសាវិទ្យា*

---

[៤៣] សាស្ត្រាចារ្យ ច័ន្ទ សំណព្វ បានផ្ដល់យោបល់ថា បច្ចេកស័ព្ទ«monème» ឬ«មូលតា» *គឺជាឯកតាដែលមានសូរឯករាជ្យ ហើយន័យវិញមានស្វ័យភាពផ្ទាល់។* ទាក់ទងទៅនឹងបញ្ហានេះ លោកសាស្ត្រាចារ្យបានផ្ដល់ការវិភាគថា ពាក្យ«ចាំ»នៅក្នុងពាក្យ«ឆ្មាំ»គឺជាមូលតា តែពាក្យ«ចាំ»ជាមួយផ្នត់ដែក[-ម-]គឺជាវចនសព្ទ។ កិច្ចពិភាក្សាជាមួយសាស្ត្រាចារ្យ ច័ន្ទ សំណព្វ នៅថ្ងៃសុក្រ ទី១៣ ខែឧសភា ឆ្នាំ២០១១។

[៤៤] ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៣ ឆ្នាំ២០១០ ទំព័រ៥៦។

[៤៥] តាមគណៈកម្មាធិការជាតិបច្ចេកស័ព្ទ«វចនតា»សមមូលទៅនឹងពាក្យ «Lexical morpheme»នៃភាសាអង់គ្លេសនិងពាក្យ«lexème»នៃភាសាបារាំង ដោយបានពន្យល់ថា៖«វចនតាជាមូលតាមួយបែបដែលជាពាក្យទោល ឬ ជាឫស/ធាតុនៃពាក្យក្នុងភាសាឥណ្ឌូអឺរ៉ុប, ឧទាហរណ៍៖ វចនតាជាពាក្យទោល ឧ. គាប, ធំ, កូន, crayon, jardin, chaise, ... វចនតាជាឫសក្នុងភាសាបារាំង ឧ. all(ទៅ) ក្នុងពាក្យ aller, ...។ វចនតាជាធាតុ ក្នុងភាសាបាឡី ឧ. ទា (ឱ្យ) ក្នុងពាក្យ ទេតិ, ទាន, ...។ កាលណាគេយកពាក្យទោលទៅធ្វើមូលដ្ឋានក្នុងការបង្កើតពាក្យ ពាក្យទោលនោះត្រូវគេហៅថា ពាក្យឫស»។ សូមមើល៖ ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៣ ឆ្នាំ២០១០ ទំព័រ៥៦-៥៧។

[៤៦] បច្ចេកសព្ទ«រូបតា»វិញគឺសមមូលទៅនឹងពាក្យ«grammatical morpheme»នៃភាសាអង់គ្លេស ហើយ សមមូលទៅនឹង«morphème» នៃភាសាបារាំង។ លើសពីនេះទៀត គណៈកម្មាធិការជាតិក៏បានពន្យល់ផងដែរថា៖ «*រូបតាជាមូលតាមួយបែបដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យ ក្នុងភាសា (លោក អៀវ កើស ហៅថា «កន្ទេចពាក្យ» សម្រាប់ភ្ជាប់ជាមួយពាក្យឫស ឬ ជាមួយឫស ដើម្បី៖ បង្កើតពាក្យ ឧទាហរណ៍៖ ក្នុងភាសាខ្មែរ៖ ពាក្យឫស ជួញ + [-ម-] > ឈ្មួញ, ពាក្យឫស គាប + [-ន-] > ឃ្នាប...។ ក្នុងភាសាបារាំង៖ ពាក្យឫស* jardin + ier > jardinier, *ឫស all + er >* aller, *... បំបែកពាក្យ ឧទាហរណ៍៖ ក្នុងភាសាបារាំង៖ ឫស* all + ons > allons *(បុ.១. ពហុ.), ឫស* all + ez > allez *(បុ.២. ពហុ.),..»* ។ សូមមើល៖ ***ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ*** លេខ៣ ឆ្នាំ២០១០ ទំព័រ៥៧។

*មូលតាគឺជាឯកតាតូចបំផុតរបស់ពាក្យ ឬ ជាឯកតាភាសាដទៃទៀតដែលមានន័យ។ បច្ចេកសព្ទនេះបានត្រូវគេប្រើជាផ្នែកមួយនៃភាសាវិទ្យា ដោយគេស្គាល់ថាមូលតាផ្អែកលើរូបសព្ទ។ មូលតាគឺផ្សំឡើងពីសទ្ទតា (ឯកតាតូចបំផុតនៃសូរដែលមានលក្ខណៈខុសគ្នានៅក្នុងភាសាវិទ្យា) នៅក្នុងភាសានិយាយ និង ផ្សំឡើងពីលេខនតា (ឯកតាតូចបំផុតនៃភាសាសរសេរ) នៅក្នុងភាសាសរសេរ»*[៤៧]។

និយមន័យនេះក៏មិនខុសគ្នាប៉ុន្មានពីនិយមន័យរបស់លោក អង់ដ្រេ ម៉ាទីណេប៉ុន្មានដែរ ពោលគឺមូលតានោះគឺជាឯកតាតូចបំផុតរបស់ពាក្យឬជាឯកតាភាសាដទៃទៀតដែលមានន័យ។ ម្យ៉ាងនិយមន័យខាងលើនេះបានបង្ហាញថាមូលតាផ្សំឡើងពីសទ្ទតាផងនិងផ្សំឡើងពីលេខនតាផង។ ក្នុងន័យនេះមូលតាមានទាំងសូរនិងមានទាំងសំណេរ។

សរុបសេចក្ដីមក យើងសង្កេតឃើញថា«មូលតា»ជាបច្ចេកសព្ទដែលរួមបញ្ចូលទាំងវចនតានិងរូបតា ហើយក៏បង្កើតឲ្យមានកិច្ចពិភាក្សាផងដែរ នៅពេលដែលក្នុងការនិពន្ធ យើងប្រើពាក្យមូលតាជំនួសឲ្យរូបតាឬវចនតា ដោយហេតុថា ក្នុងវិសាលភាពនៃការវិភាគបែបនេះ គេអាចច្រឡំថារូបតាក៏ជាវចនតាឬវចនតាជារូបតា។ តាមការពិត រូបតាខុសអំពីវចនតា បើទោះបីជាធាតុទាំងពីរនេះជាមូលតាក៏ដោយ[48]។ ឧទាហរណ៍ ពាក្យ ចាំ ដែលជាពាក្យកម្លាយកើតឡើងពីអន្តរកម្មរវាងពាក្យឫស ឆ្មាំ និង អន្តេបទ /-ម-/។ ពាក្យ ចាំ គឺជាវចនតា ចំណែកឯ អន្តេបទ/-ម-/គឺជារូបតា។ ដូចគ្នានេះដែរ ពាក្យសែងនៅក្នុងពាក្យ«ស្នែង»គឺជាវចនតា ចំណែកឯ អន្តេបទ/-ន-/គឺជារូបតា[៤៩]។

### ១.២.៥. កាឡារូប

កាឡារូបគឺជាបច្ចេកសព្ទដែលយើងនឹងលើកយកមកវិភាគ នៅក្នុងក្របខណ្ឌនៃនិក្ខេបបទនេះ ដើម្បីផ្សារភ្ជាប់ទៅនឹងការសិក្សារបស់យើងដែលពាក់ព័ន្ធ។ ទាក់ទងទៅនឹងបញ្ហានេះ យើងនឹងបង្ហាញអំពីគោលការណ៍ទ្រឹស្ដីនិងការអនុវត្តជាក់ស្ដែង ទាំងក្នុងភាសាដែលពាក់ព័ន្ធនិងនៅក្នុងបរិបទភាសាខ្មែរ។

បច្ចេកសព្ទ«កាឡារូប»សមមូលទៅនឹងពាក្យ«Allomorph»នៃភាសាអង់គ្លេសនិង«Allomorphe» នៃភាសាបារាំង។ គណៈកម្មាធិការជាតិភាសាខ្មែរក៏បានអនុម័តនិងកំណត់និយមន័យថា៖*«រូបផ្សេងៗរបស់រូបតាណាមួយដែលអាចប្ដូររូបទៅតាមបរិបទ ដូច៖ រូបតា /-s/ នៃពហុវចនៈរបស់នាមសព្ទអង់គ្លេសដែលអាចមានកាឡារូប [-s] ក្នុងពាក្យ* books, *[-z] ក្នុងពាក្យ* dogs, *[-iz] ក្នុងពាក្យ* Boxes»[៥០]។

ការពន្យល់បង្ហាញខាងលើរបស់គណៈកម្មាធិការជាតិគឺមានការពិពណ៌នាត្រឹមតែភាសាអង់គ្លេស

---

[៤៧] http://www.absoluteastronomy.com/topics/Morpheme <<*In linguistics, a* ***morpheme*** *is the smallest component of word, or other linguistic unit, that has semantic meaning. The term is used as part of the branch of linguistics known as morpheme-based morphology. A morpheme is composed by phoneme(s) (the smallest linguistically distinctive units of sound) in spoken language, and by grapheme(s) (the smallest units of written language) in written language.>>*

[៤៨] សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ក៏មានគំនិតយល់ស្របគ្នាអំពីបញ្ហាដែលយើងខ្ញុំបានលើកឡើងនេះផងដែរ។

[៤៩] លោកសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានផ្ដល់ការវិភាគថា ពាក្យ ចាំ នៅក្នុងពាក្យ**ឆ្មាំ**គឺជាមូលតា ក៏ប៉ុន្តែ ពាក្យ **ចាំ** ជាមួយអន្តេបទ /-ម-/គឺជាវចនសព្ទ។

[៥០] ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៣ ឆ្នាំ២០១០ ទំព័រ៥៧-៥៨។

ដោយមិនបានលើកភាសាខ្មែរមកបញ្ជាក់នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គំនិតខាងលើនេះអាចជាមធ្យោបាយមួយសម្រាប់យកមកពិចារណានិងស្វែងរកកាឡារូបបានផងដែរ នៅក្នុងភាសាខ្មែរ។ ការមិនបង្ហាញអំពីកាឡារូបនៅក្នុងភាសាខ្មែរ របស់គណៈកម្មាធិការជាតិភាសាខ្មែរទំនងជារកគោលការណ៍ឯកភាពមិនទាន់បានទៅលើកាឡារូបនៃភាសាខ្មែរ ហេតុដូច្នេះ ការណ៍ខាងលើគឺត្រឹមតែបង្ហាញតែនៅក្នុងភាសាអង់គ្លេស ដោយហេតុថា ភាសាអង់គ្លេសមានការឯកភាពគ្នាទៅលើការកំណត់នៃលក្ខណៈពហុវចនៈជារួម។ នៅក្នុងឧទាហរណ៍ខាងលើ យើងសង្កេតឃើញថាទម្រង់នៃពហុវចនៈ នៅក្នុងភាសាអង់គ្លេសប្រែប្រួលទៅតាមបរិបទ ហើយ សទ្ទតាទាំងនោះមានន័យសម្រាប់សម្គាល់ពហុវចនៈ។

លោកសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានផ្តល់ជាយោបល់ថា ដើម្បីកំណត់កាឡារូបនៅក្នុងភាសាខ្មែរ យើងត្រូវពិនិត្យមើលកត្តាពីរ។ កត្តាទីមួយ យើងត្រូវពិនិត្យមើលអំពីអក្ខរក្រមនៅក្នុងភាសាខ្មែរតើអក្ខរក្រមណាមួយដែលមានលំដាប់មុនគេ បន្ទាប់មកយើងអាចសម្រេចយកអក្ខរក្រមនោះជាបង្គោលនៅក្នុងកាឡារូបនៅក្នុងភាសាខ្មែរ។ កត្តាទីពីរ យើងត្រូវពិនិត្យមើលប្រព័ន្ធនៃការបន្លឺសំឡេងថាតើការបន្លឺសំឡេងណាមួយមានភាពងាយស្រួលជាងគេ បន្ទាប់មក យើងអាចសម្រេចយកប្រព័ន្ធនៃការបន្លឺសំឡេងនោះជាកាឡារូប។ ឧទាហរណ៍ មូលតា/-អ'ង-/ឬ/-អ៊'ង-/អាចមានកាឡារូបផ្សេងគ្នាទៅតាមបរិបទ នៅក្នុងនោះ យើងសង្កេតឃើញចុងរូបតា/ង/អាចមានកាឡារូបជា [ង], [ញ], [ណ], [ន], និង[ម]។ ការបង្ហាញនេះមានន័យថារូបតា /-អ'ង-/ឬ/-អ៊'ង-/ អាចមានកាឡារូបជា [-អ'ង-] ឬ [-អ៊'ង-], [-អ'ញ-], [-អ៊'ញ-] [-អ'ណ-], [-អ'ន-], [-អ៊'ន-], [-អ'ម-]ឬ[-អ៊'ម-]ទៅតាមបរិបទ[៥១]។ តាមការសង្កេតឧទាហរណ៍ខាងលើយើងឃើញថារូបតា /-អ'ង-/ ឬ /-អ៊'ង-/មានសញ្ញាព្យញ្ជនៈ/ង/ដែលជាអក្ខរក្រមដំបូងគេ អាស្រ័យហេតុនេះយើងសន្មតយក /-អ'ង-/ ឬ /-អ៊'ង-/គឺជារូបតា ដោយមានកាឡារូបផ្សេងៗគ្នាទៅតាមបរិបទ។ ដូចគ្នានេះដែរ រូបតា/ប៉-/មានកាឡារូបផ្សេងៗគ្នាទៅតាមបរិបទ ពោលគឺរូបតា/ប៉-/អាចមានកាឡារូបជា[ប៉-]នៅក្នុងពាក្យប៉ឹង កាឡារូប[ផ-]នៅក្នុងពាក្យផ្ទឹម កាឡារូប[ប'ញ-]នៅក្នុងពាក្យបញ្ចូល កាឡារូប[ប'ន-]នៅក្នុងពាក្យបន្សុំ កាឡារូប[ប'ម-]នៅក្នុងពាក្យបំបួស កាឡារូប[ប'ង-]នៅក្នុងពាក្យបង្អួត[៥២]។ បើទោះបីជាកាឡារូបនៃមូលតា[ប៉-]មានបន្លែកផ្សេងៗគ្នាយ៉ាងណាក៏ដោយ ក៏ការបន្លឺសំឡេងនៃកាឡារូបនោះ យើងឮសូរ[ប៉-]នៅពេលដែលគេបន្លឺពាក្យទាំងនោះឡើង ចំណែកឯន័យនៃរូបតា[ប៉-]នោះទៀតសោតនៅរក្សាន័យដដែល ពោលគឺជាមានន័យថា«ធ្វើឲ្យ»។

### **១.២.៥.១. វិភាគរកកាឡារូបរបស់អន្តែបទ/-ម-/និង/-ន-/**

#### ១.២.៥.១.១. វិភាគរកកាឡារូបរបស់អន្តែបទ/-ម-/

---

[៥១] សូមមើល៖ កែវ លីណែត *សម្រង់ពាក្យកម្លាយកើតចេញពីពាក្យដើមសរសេរជាព្យាង្គតម្រួតតាមរយៈអន្តែបទ [-អ'ង-] ឬ [-អ៊'ង-]* ២០០៩, ១៦ទំព័រ។

[៥២] ឧទាហរណ៍នេះខ្ចីពីសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ នៅក្នុងស្នាដៃរបស់លោកស្តីអំពី *មូលដ្ឋាននៃន័យកម្មវិទ្យាទូទៅ* ឆ្នាំ២០០៣ ទំព័រ១២-១៣។

មានអ្នកស្រាវជ្រាវខ្លះបានចាត់ទុក[-រម-]ជាកាឡារូប[៥៣] ក៏ប៉ុន្តែ អ្នកទាំងនោះមិនបានបកស្រាយ និងពន្យល់មូលហេតុអ្វីបានជាមានកាឡារូបទ្រង់ទ្រាយបែបនេះ។ នៅក្នុងសម្មតិកម្មនេះ យើងសង្កេតឃើញមានក្នុងឧទាហរណ៍ដូចខាងក្រោម៖

បាញ់ > ប្មាញ់ > ប្រមាញ់

ធឹក > ប្មឹក > ប្រមឹក

ការលើកឡើងអំពីកាឡារូបរបស់អន្តេបទ/-ម-/ថាមាន[-រម-] ជាកាឡារូបនៅក្នុងឧទាហរណ៍ខាងលើនោះ យើងសង្កេតឃើញថាអំណានពាក្យ«ប្រមាញ់»ឬ«ប្រមឹក»គឺគ្រាន់តែជាអំណានសូរដើម្បីសម្រួលអំណានតែប៉ុណ្ណោះ ហើយប្រសិនបើយើងពិនិត្យទៅលើនិយមន័យនៃកាឡារូបខាងលើ គឺវាមិនឆ្លើយតបទៅនឹងនិយមន័យនោះផងទេ ចំពោះប្រជាជនខ្មែរវិញ យើងដឹងថាពាក្យ«ប្មាញ់» បែបនេះមានលក្ខណៈពិបាកអាននិងមិនស្រួលមាត់ថែមទៀត។ ម្យ៉ាងវិញទៀត យើងអាចនិយាយបានថា ពាក្យនេះដំបូងជាពាក្យមួយព្យាង្គកន្លះ ក៏ប៉ុន្តែ ពលរដ្ឋខ្មែរទូទៅអានច្រើនលេបនៅដើមព្យាង្គ។ ហេតុដូច្នេះ ដើម្បីសម្រួលការអានឲ្យមានលក្ខណៈល្អនិងងាយស្រួលផងនោះ ទើបបុព្វបុរសខ្មែរបានបន្ថែមខ្យល់ «រ» ដើម្បីបង្កលក្ខណៈស្រួលនៅក្នុងអំណាន។ ជាលទ្ធផល ពាក្យ«ប្មាញ់»ក៏អានយារមកជា«ប្រមាញ់»។

ដំណាក់កាលដំបូង យើងប្រើ «ប្មាញ់» ក្រោយមក យើងប្រើយារមកជា«ប្រមាញ់» នេះបណ្តាលមកពី «ប្មាញ់»មានលក្ខណៈពិបាកនៅក្នុងអំណាន ហើយអំណានបែបនេះទំនងជាភាសាខ្មែរទទួលឥទ្ធិពលពីភាសាបាឡីផង ពីព្រោះភាសាបាឡីមានប្រើខ្យល់បែបនេះជាច្រើនដែលគេហៅថា«អាគម»។ ទស្សនៈលើកឡើងបែបនេះគឺស្របទៅតាមគំនិតរបស់លោក អៀវ កើស ផងដែរ ដោយលោកបានលើកឡើងថា៖«*កាលណាអង្គប្រធានរបស់ពាក្យជាឫសរបស់ព្យញ្ជនៈ «ប» នោះតែងតែមានចុះ «រ» ជាអាគម» ដូចមានក្នុងឧទាហរណ៍៖ បាញ់ >ប្រមាញ់, បុក>ប្រមុក, បោយ>ប្រមោយ*»[៥៤]។

អំណះអំណាងខាងលើសបញ្ជាក់ឲ្យឃើញថាសូរ [-រម-] គឺជាដំណើរការវិវត្តនៃអំណាននៅក្នុងភាសាខ្មែរពីភាពលំបាកមកកាន់ភាពងាយស្រួល។ ភាសានៅលើពិភពលោកតែងតែមានការវិវត្ត តាមលក្ខណៈធម្មជាតិនៃអ្នកប្រើប្រាស់មិនមានអ្វីមករារាំងចលនាបែបនេះបាននោះទេ ពីព្រោះបែបផែនទាំងនេះគឺជាកត្តាសត្យានុម័តដែលកើតមានឡើងចំពោះភាសាផ្សេងៗ ហើយភាសាខ្មែរក៏មានលក្ខណៈដូចភាសាដទៃទៀតផងដែរ។ អាស្រ័យហេតុនេះ យើងអាចធ្វើសន្និដ្ឋានបានថាមិនមានកត្តាធម្មជាតិកំណត់ទម្រង់ [-រម-] បានថាជាកាឡារូបនោះទេ ពីព្រោះទម្រង់នេះកើតមាននៅពេលអំណានមានការលំបាកសម្រាប់អ្នកប្រើប្រាស់ប៉ុណ្ណោះ ហើយ លក្ខណៈបែបនេះគឺមានក្នុងភាសាជាច្រើនក្នុងសាកលលោកដែលគេហៅថា«អាគម» ដោយយើងនឹងសិក្សាអំពី«អាគម»នៅកថាភាគបន្ទាប់។

---

[៥៣] See: Philip N. Jenner, ***Affixation in Modern Khmer***, op-cit., p.144 and Judith M. Jacob, ***Cambodian Linguistics, Literature and History***. David A. Smyth (ed.), op-cit., p.66. (រ=ព្យញ្ជនៈ រ ឬ ខ្យល់ រ, ចំណែក ស=ស្រៈ, ម=សំឡេង ម នៅក្នុងអន្តេបទ/-ម-/)។

[៥៤] អៀវ កើស *ភាសាខ្មែរ (ការល្បងពិនិត្យដោយរកហេតុផល)* ជ.ឯ.ម. ទំព័រ១៧៨។

ម្យ៉ាងវិញទៀត អ្នកសិក្សាខ្លះ[៥៥]ទៀតបានពិពណ៌នាអន្តេបទ/-ម-/មានកាឡារូបមួយបែបទៀតពោលគឺ [-អ'ម-]។ ការពិពណ៌នាថាអន្តេបទ/-ម-/មានកាឡារូប[-អ'ម-]ខ្លះបង្ហាញថាទម្រង់[-អ'ម-]មានលទ្ធភាពសម្រាប់បង្កើតនាមសព្ទដូចអន្តេបទ /-ម-/ ឬពេលខ្លះទៀត អន្តេបទ/-ម-/និងទម្រង់[-អ'ម-]មានប្រភេទពាក្យស្ទួនគ្នា ដូចមាននៅក្នុងឧទាហរណ៍ពាក្យ ធ្មក់ និង ជម្រាប។ ធ្មក់ ជាមានប្រភេទពាក្យជាកិរិយាសព្ទ ដែលមានមានន័យថា *លួចល្បក់* ដោយពាក្យនេះបានមកអំពីអន្តរកម្មរវាងអន្តេបទ/-ម-/និងពាក្យឫស ធក់។ ជាមួយគ្នានេះ ជម្រាបដែលជាពាក្យកម្លាយកើតមកអំពីអន្តរកម្មរវាងពាក្យឫសជ្រាបនិងអន្តេបទ/-អ'ម-/មានប្រភេទពាក្យជាកិរិយាសព្ទ។

ដូច្នេះ យើងសង្កេតឃើញថាទម្រង់[-រម-]និង[-អ'ម-]មិនអាចជាកាឡារូបរបស់អន្តេបទ/-ម-/បាននោះទេ។ ទម្រង់ [-រម-] ដូចមាននៅក្នុងឧទាហរណ៍ខាងលើគឺជាដំណើរការវិវត្តនៃសូរដែលអាចកើតមាននៅក្នុងភាសាខ្មែរ ដើម្បីសម្រួលអំណាន ចំណែកឯ[-អ'ម-]គឺជាអន្តេបទមួយប្រភេទ។ តាមរយៈទិន្នន័យអន្តេបទ/-អ'ម-/ដែលមានចំនួន១៨៨[៥៦]នោះ អន្តេបទនេះមានតួនាទីយ៉ាងសំខាន់សម្រាប់ធ្វើអន្តរកម្មជាពាក្យឫស ដើម្បីបង្កើតពាក្យកម្លាយ ដោយពាក្យកម្លាយទាំងនោះមានប្រភេទពាក្យខុសពីពាក្យឫសឬអាចដូចពាក្យឫស។

---

[៥៥] ឡុង សៀម «ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យសព្ទតាមបម្រើបម្រាស់ផ្នត់នីយកម្ម» នៅក្នុង ***សន្និសីទស្តីពីការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ ភាសាខ្មែរ*** ដ.ឯ.ម. ទំព័រ២៦-២៧។ លោកសាស្ត្រាចារ្យ ឡុង សៀមបានសរសេរថាទម្រង់ [-អ'ម-] គឺអាចជាកាឡារូបរបស់អន្តេបទ /-ម-/ ដូចមាននៅក្នុងសំណេររបស់លោកជាតឹកតាង៖«*កាឡារូបស័ព្ទនៃផ្នត់មួយចំនួន តាមវចនាសម្ព័ន្ធសូរសព្ទបានក្លាយទៅជាសទិសសព្ទ។ ឧទាហរណ៍៖ អង្កត់ [-am-] អាចជាកាឡារូបស័ព្ទនៃផ្នត់ដែកភ្ជាក់ងារ /-m-/ ឬអាចជាកាឡារូបស័ព្ទនៃផ្នត់ដើមសម្តែងហេតុ/p-/ឬអាចជាកាឡារូបស័ព្ទរបស់ផ្នត់ដែក/-amn-/។ ហេតុនេះ យើងអាចធ្វើសន្និដ្ឋានដូចតទៅ ចេញពីឫសតែមួយ គេអាចបង្កើតពាក្យកម្លាយផ្សេងគ្នាដែលជាសទិសសព្ទ ដោយដាក់ផ្នត់ជាសទិសសព្ទ ហើយន័យរបស់វាអាចកំណត់បានតែដោយសារទីសេចក្តីរបស់ពាក្យកើតថ្មីតែប៉ុណ្ណោះ។ ចេញពីពាក្យ Chlak ឆ្លក k.៣៩៧ មានពាក្យកម្លាយដែលជាសទិសសព្ទដូចតទៅ៖Camlak ចំលក k.៧២៖ «ធ្លាក់» ([-am-] ជាកាឡារូបស័ព្ទនៃផ្នត់ដើម /p-/) Camlak ចំលក k.២១, k.១៦៥ ៖ «រូបចំលាក់» ([-am-] ជាកាឡារូបស័ព្ទនៃផ្នត់ដែក /-amn-/) Camlak ចំលក k.១៩២៖ «ដាងចំលាក់» ([-am-] ជាកាឡារូបស័ព្ទនៃផ្នត់ដែក /-m-/)។*» លោក កេងវ៉ាន់ សាក់ បានលើកឡើងថា អន្តេបទ«ម» អាចចុះកណ្តាលធាតុពាក្យ«ខ្លាច» (ខ+ម+្ល) បង្កើតជា«កម្លាច»។ សូមមើល៖ កេង វ៉ាន់សាក់ ***មូលភាពនៃការបង្កើតពាក្យថ្មី*** ដ.ឯ.ម. ទំព័រ១៦១។

[៥៦] ទិន្នន័យទាក់ទងនឹងអន្តេបទ/-អ'ម-/ យើងបានរកឃើញថាពាក្យកម្លាយដែលកើតអំពីអន្តរកម្មរវាងអន្តេបទ/-អ'ម-/និងពាក្យឫសមានប្រភេទពាក្យជានាមសព្ទ(កម្រ កំហុស) ហេតុកិរិយា(កំដៅ កម្ទេច) សកម្មកិរិយា (កម្ចាយ សម្លឹង) អកម្មកិរិយា (តម្អឹង បម្រុង) គុណនាម(កម្លាច គម្រប់ ជម្ងើយ) កិរិយាវិសេសន៍(សម្កុង) និងឈ្នាប់(ទម្រាំ)។ លោក កែវ លីណែត បានស្រង់អន្តេបទ/-អ'**ᨀ**-/ឬ/-អ៊'**ᨀ**-/ពីវចនានុក្រមដែលមានចំនួន៣១១ពាក្យ នៅក្នុងនោះ លោកបានសរសេរថា/**ᨀ**/ គឺជាព្យញ្ជនៈសម្រាប់សម្គាល់ចុងរូបសព្ទ(មូលតា)ដែលអាចក្នុងកាឡារូបសព្ទ(allomorphes)ក្លាយទៅជា[ង],[ញ], [ណ], [ន], [ម] ទៅតាមបរិបទ។ នេះមានន័យថាលោកបានកំណត់យក/-អ'**ᨀ**-/ឬ/-អ៊'**ᨀ**-/ជាអន្តេបទ ដោយ[-អ'ម-]ឬ[-អ៊'ម-]ជាកាឡារូបមួយរបស់អន្តេបទ/-អ'**ᨀ**-/ឬ/-អ៊'**ᨀ**-/។ ការណ៍នេះទំនងជាលោកយល់ថាសញ្ញាព្យញ្ជនៈ/ង/ជាសញ្ញាព្យញ្ជនៈនៅវគ្គទីមួយ។ សូមមើល កែវ លីណែត ***សម្រង់ពាក្យកម្លាយកើតចេញពីពាក្យដើមសរសេរជាព្យាង្គតម្រួតតាមរយៈអន្តេបទ/-អ'ᨀ-/ឬ/-អ៊'ᨀ-/*** គណៈកម្មាធិការជាតិភាសាខ្មែរ ២០០៩។

### ១.២.៥.១.២. វិភាគរកភាឡារូបរបស់អន្តេបទ/-ន-/

ទាក់ទងទៅនឹងកាឡារូបនេះ លោក ហ្វីលីប ហ្សែននឺរ បានបែងចែកកាឡារូបអន្តេបទ /-ន-/ ជាពីរគឺ /-សន-/និង/-រសន-/[៥៧] ដោយលោកបានពិពណ៌នាដូចខាងក្រោម៖

> *អន្តេបទ/-ន-/មានពីរប្រភេទគឺ /-សន-/និង/-រសន-/ បន្ថែមលើ /-ន-/ខ្លួនវាផ្ទាល់។ទីមួយគឺឃើញមាននៅក្នុងពាក្យកម្លាយពីរដែលផ្ដើមឡើងដោយព្យញ្ជនៈដើមព្យាង្គ«អ»៖ អារ > អារណា, អប > អាណាប ក្នុងករណីទាំងពីរនេះ ស្រៈ«អា»ជំនួសឲ្យ «អ» ។ ទីពីរគឺឃើញមាននៅក្នុងពាក្យកម្លាយចំនួន២០ដែលផ្ដើមឡើង ដោយព្យញ្ជនៈដើមព្យាង្គដូចជា /ប៉ ព ប ត ទ ដ ច ស/ និងបម្លាស់ទីជាមួយ/-ន-/៖ ផ្ទុក~ប្រណូក។ កាឡារូប/-ន-/អាចប្រើជាមួយនឹងព្យញ្ជនៈដើមព្យាង្គដូចជា/ព ភ ប ត ទ ដ ច ក ខ យ រ ស/ ចំណែកព្យញ្ជនៈដើមព្យាង្គ «ឡឬល»គឺយើងមិនឃើញមាននោះទេ។ ម្យ៉ាងវិញទៀត ទិន្នន័យពីនេះតទៅរួមមានពាក្យកម្លាយដែលមកពីពាក្យឫសចំនួនពីរដែលនៅខាងក្រោយខ្យល់«ហ» ដូចជា ធូត > ធ្នូត, យោរ>យ្នោរ (ចូរចំណាំថាពាក្យឫសគឺជាភាសាបាឡីសំស្ក្រឹត «យោរៈ»ដែលមានន័យថា«គួរឲ្យខ្លាចឬកំណាច)*[៥៨]។

តាមរយៈការរៀបរាប់ខាងលើ យើងសង្កេតឃើញថា លោកហ្វីលីប ហ្សែននឺរ គឺប្រាកដណាស់ថាលោកបានបង្ហាញអំពីទម្រង់កាឡារូបរបស់អន្តេបទ/-ន-/ដែលមាននៅក្នុងអ្វីដែលលោកបានលើកឡើងខាងលើស្រាប់។ តឹកតាងនេះសបញ្ជាក់ឲ្យឃើញថា អន្តេបទ/-ន-/មានកាឡារូបពីរដូចយើងបានរៀបរាប់រួចមកហើយ។ ទោះបីជាមានការបែងចែកបែបនេះហើយក៏ដោយ ក៏ការពិពណ៌នាឬបង្ហាញអំពីហេតុផលនិងអំណះអំណាង ដោយយោងទៅលើទ្រឹស្ដីនិងបាតុភូតផ្សេងៗផងនោះ គឺមិនទាន់មានលក្ខណៈច្បាស់លាស់និងការបរិយាយអំពីមូលហេតុពិតប្រាកដនៅឡើយ។ ម្យ៉ាងវិញទៀត ឧទាហរណ៍ដែលបានចង្អុលបង្ហាញខាងលើគឺមានទិន្នន័យតែតិចតួចប៉ុណ្ណោះ សម្រាប់ជាភស្ដុតាង នៅក្នុងការលើកហេតុផលនៃកាឡារូបអន្តេបទ/-ន-/។

តាមការបកស្រាយនិងលើកឧទាហរណ៍នោះ ទិន្នន័យដែលផ្ដល់ឲ្យគឺហាក់មានលក្ខណៈជាពាក្យកម្លាយដែលកម្រនឹងប្រើនៅក្នុងសំណេរនិងការប្រើប្រាស់ទូទៅ ពីព្រោះថា ពាក្យឫស «អប» អាចក្លាយទៅជា «អាណាប» នៅក្នុងករណីពាក្យឫស«អាណាប»ជាពាក្យដែលមានការប្រើប្រាស់ នៅក្នុងការនិយាយធម្មតាឬសម្រាប់ប្រជាជនសាមញ្ញប្រើប្រាស់ តែពាក្យ«អាណាប»មិនមែនជាពាក្យផ្លូវការនោះទេ។ ប៉ុន្តែពាក្យដែលជាផ្លូវការនោះវិញគឺ«រណាប»។ តាមវចនានុក្រម ពាក្យ«រណាប»គឺនាមសព្ទដែលមានន័យថា«ប្រដាប់សម្រាប់អប, របស់ដែលអបពីលើគេ ឧទាហរណ៍៖ រណាបជញ្ជាំង ។ បើជាពាក្យប្រៀបវិញមានន័យថា« អ្នកដែលរងបន្ទាប់គេ» ឧទាហរណ៍៖ ធ្វើជារណាបគេ; អ្នកដែលជួយការពារឬជួយស្រោបដណ្ដប់

---

[៥៧] «ស»គឺសម្រាប់សម្គាល់ស្រៈ ចំណែកឯ«រ»គឺជាសំឡេងខ្យល់ព្យញ្ជនៈ«រ»ឬជើង«រ»។

[៥៨] Philip N. Jenner, ***Affixation in Modern Khmer***, op-cit., p.147.

ដូចគេអបស្នប ឧទាហរណ៍៖ អាងមានរណប។»  តើពាក្យកម្លាយដែលលោក ហ្វីលីប ហ្សែនន័រ លើកឡើងនោះ «អាណប»គឺពិតជាពាក្យកម្លាយដែលក្លាយមកពីពាក្យឫស«អប»មែនទេ ?

ប្រសិនបើ យើងសម្អាងលើវចនានុក្រមខ្មែរសម័យទំនើបដែលបោះពុម្ពឡើងដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យគ្រាទី៥ ឆ្នាំ១៩៦៧ យើងមិនអាចរកឃើញពាក្យ«អាណប»បាននោះទេ ក៏ប៉ុន្តែ យើងអាចរកប្រភពមួយផ្សេងទៀត ចេញពីវចនានុក្រមរបស់ លោក ហ្សូសែហ្វ ហ្គេដុង គឺមានបង្ហាញថាពាក្យឫស«អាណប»គឺពិតជាក្លាយមកពីពាក្យឫស«អប»ពិតប្រាកដមែន[៥៩]។ ហើយម្យ៉ាងវិញទៀត លោកស្រី ពៅ សាវរស និង លោក ហ្វីលីប ហ្សែនន័រ ក៏មានតឹកតាងបែបនេះផងដែរ ដោយថែមទាំងគូសបញ្ជាក់ថាពាក្យ«រណប»និង«អាណប»អាចប្រើប្រាស់ផ្លាស់ប្តូរគ្នាបាន[៦០]។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ពាក្យ «អាណបឬរណប» អាចមានប្រភពមកពីពាក្យឫស«អប»ពិតមែន ក៏ប៉ុន្តែ ទំនងជាការប្រើយារក្រោយមកពី«អាណប»មកជា«រណប»។

ពាក្យ«អាណារ»ជាពាក្យកម្លាយដែលក្លាយមកពីកិរិយាសព្ទ«អារ»។ ក៏ប៉ុន្តែ នៅក្នុងភាសាខ្មែរសម័យទំនើបមានត្រឹមតែពាក្យ«រណារ»ដែលបែបនេះហើយទើប លោក ហ្វីលីប ជែនន័រ បានចាត់ទុកថាទម្រង់បែបនេះជាកាឡារូបរបស់អន្តេបទ/-ន-/។ តាមពិតនៅក្នុងភាសាខ្មែរ បាតុភូតបែបនេះកើតមានជាច្រើន ចំពោះពាក្យពេចន៍មួយចំនួន ដូចយើងបានរៀបរាប់ រួចមកហើយ ថាជាបាតុភូតសម្របសូរ ដោយហេតុថា នៅក្នុងភាសាខ្មែរការអានពាក្យ«រណារ»គឺមានការពិបាកសម្រាប់ជនជាតិខ្មែរទូទៅ ក៏ប៉ុន្តែ ការអានពាក្យ«អាណារ»មានលក្ខណៈងាយស្រួលជាង។ អាស្រ័យហេតុនេះ កាឡារូប/-សន-/និង/-សរន-/គឺគ្រាន់តែបាតុភូតភាសាក្នុងអំណានដែលតែងតែកើតមានឡើងជាញឹកញាប់នៅក្នុងភាសាខ្មែរឬយើងអាចហៅថាជាអាគម សម្រាប់សម្រួលអំណាន។ ដូច្នេះ កាឡារូប/-សន-/និង/-សរន-/មិនអាចជាកាឡារូបនៃអន្តេបទ/-ន-/នោះទេ ក៏ប៉ុន្តែ យើងអាចនិយាយបានថា ទម្រង់បែបនេះគឺជាបាតុភូតនៃសម្របសូរនៅក្នុងភាសាខ្មែរ ដើម្បីសម្រួលអំណានឲ្យមានការងាយស្រួល ជាពិសេស អ្នកអានឬអ្នកនិយាយភាសាកំណើតរបស់ខ្មែរ ហើយបញ្ហានេះយើងនឹងបង្ហាញជូននៅកថាភាគខាងក្រោម។

### ១.២.៦. អាគម

តាមគណៈកម្មាធិការជាតិភាសាខ្មែរ បច្ចេកសព្ទ «អាគម» ត្រូវនឹងភាសាអង់គ្លេស«epenthesis» និងភាសាបារាំង«épenthèse»។ ពាក្យនេះ គណៈកម្មាធិការជាតិភាសាខ្មែរបានកំណត់និយមន័យថា៖« *សទ្ទតាដែលឥតទាក់ទងនឹងជាតិសព្ទ កើតឡើងក្នុងពាក្យឬកន្សោមពាក្យខ្លះ ដើម្បីជាវិសោលសូរ ឬ ដើម្បីសម្រួលអំណាន, ឧទាហរណ៍៖ ភាសាបរទេស* lat.camera> frs cham**b**re *(b ជាអាគម)*, lat. Hibernum> *it./*port. I**n**verno *(n ជាអាគម)។ ភាសាខ្មែរ៖ ជង់>ផ្នង់>ជ្រនង់ [crOnON] ([rO] ជាអាគម), ចតុ+អង្គ > ចតុរង្គ (រ ជាអាគម), ឆ+អភិញ្ញា > ឆឡភិញ្ញា ( ឡ ជាអាគម តាមឯកឧត្តម ឈន*

---

[៥៩] See: Joseph GUESDON, ***Dictionnaire Cambodien-Français***, op.cit., p.36.

[៦០] See: Philip N. Jenner and Pou Saveros, ***A Lexicon of Khmer Morphology***, op.cit., p.415.

*អៀម)»*[៦១]។

និយមន័យខាងលើអាចជួយបាននៅក្នុងការសិក្សានិក្ខេបបទនេះ ពីព្រោះចំពោះអន្តេបទ/-ម-/ និង/-ន-/ក៏មានអាគមនៅជាមួយផងដែរ។ ដូចឧទាហរណ៍ខាងលើ ពាក្យ *ជង់>ជ្នង់>ជ្រនង់* ដែលឧទាហរណ៍នេះសបញ្ជាក់ឲ្យឃើញថាភាសាខ្មែរមានអន្តេបទ/-ន-/មានប្រើអាគមដែលអាចជួយឲ្យអ្នកអានងាយស្រួល នៅក្នុងការបន្លឺសំឡេង ដើម្បីឲ្យស្រួលមាត់។ ក្រៅអំពីឧទាហរណ៍នៃអន្តេបទ/-ន-/ដែលមានប្រើអាគមដូចខាងលើ យើងសង្កេតឃើញថាភាគច្រើននៃអន្តេបទ/-ន-/មានប្រើអាគម«រ» ដូចនៅក្នុងឧទាហរណ៍ខាងក្រោមផ្សេងទៀតជាទឡ្ហីករណ៍ស្រាប់៖

| | |
|---|---|
| ជីក+/-ន-/> ជ្នីក>ជ្រនីក | ទង+/-ន-/> ទ្នង>ទ្រនង |
| តម+/-ន-/> ត្នម>ត្រណម | ទិច+/-ន-/> ទ្និច>ទ្រនិច |
| ទប់+/-ន-/> ទ្នប់>ទ្រនប់>ទំនប់ | បួល+/-ន-/> ប្នួល>ផ្នួល>ប្រផ្នួល |
| ព+/-ន-/> ព្ន>ព្រនរ | ពាក់+/-ន-/> ព្នាក់>ព្រនាក់ |
| សាន+/-ន-/> ស្នាន>ស្រណាន | សុខ+/-ន-/> ស្នុខ>ស្រណុក |

តាមរយៈឧទាហរណ៍ខាងលើទាំងនេះ អន្តរកម្មរវាងពាក្យឫសនិងអន្តេបទ/-ន-/បានបង្កើតឲ្យមានបរិបទមួយគឺអាគមដែលកើតមានចំពោះពាក្យកម្លាយ។ អាគម«រ»ដែលបានចុះនៅក្នុងពាក្យកម្លាយខាងលើគឺមិនមែនជាការណ៍ចៃដន្យនោះទេ ប៉ុន្តែបាតុភូតនេះកើតឡើងចំពោះអន្តេបទ/-ន-/ជាមួយពាក្យឫស«ជីក ទង តម ទិច ទប់ បួល ព ពាក់ សាន និងសុខ»។ ការចុះអាគមនោះឡើងគឺធ្វើឡើងដើម្បីសម្រួលអំណាននៅក្នុងភាសាខ្មែរ ពីព្រោះថាប្រសិនបើយើងអានតាម«ជ្នីក ទ្នង ត្នម ទ្និច ទ្នប់ ប្នួល ព្ន ព្នាក់ ស្នាន និងស្នុខ»បែបនេះ គឺពិតជាធ្វើឲ្យអ្នកអានមានការលំបាក ព្រមទាំងជាឧបសគ្គនៃការបន្លឺសូរនៃពាក្យទាំងនោះ។ អាស្រ័យហេតុនេះ ដើម្បីបង្កភាពស្រួលដល់អ្នកអាននិងដើម្បីឲ្យរត់មាត់ស្រួលនិយាយផងនោះ ពាក្យកម្លាយ ទាំងនោះក៏បានជាលទ្ធផល«ជ្រនីក ទ្រនង់ ត្រណម ទ្រនិច ទ្រនប់ ប្រផ្នួល ព្រនរ ព្រនាក់ ស្រណាន និងស្រណុក»បែបនេះឡើង។

ដូចគ្នានេះ អន្តេបទ/-ម-/ក៏មានការចុះអាគមផងដែរ នៅពេលដែលអន្តេបទនេះមានអន្តរកម្មរវាងពាក្យឫសនិងអន្តេបទ/-ម-/។ ហើយ អាគមដែលយើងជួបប្រទះនោះក៏ដូចជាអាគមនៅក្នុងអន្តេបទ /-ន-/ ដែរគឺគេប្រើអាគម «រ» នៅក្នុងការសម្រួលអំណាននៃពាក្យកម្លាយដែលជាលទ្ធផលនៃអន្តរកម្មរវាងពាក្យឫសនិងអន្តេបទ/-ម-/។ឧទាហរណ៍៖

| | |
|---|---|
| បុក +/-ម-/>ប្មុក>ប្រមុក | បង់ +/-ម-/>ប្មង់>ប្រមង់ |
| បាញ់ +/-ម-/>ប្មាញ់>ប្រមាញ់ | ទាក់ +/-ម-/>ទ្មាក់>ទម័កឬទ្រមាក់ |
| ផឹក+/-ម-/>ផ្មឹក>ប្រមឹក | បោយ +/-ម-/>ប្មោយ>ប្រមោយ |

ដូចមាននៅក្នុងឧទាហរណ៍ខាងលើស្រាប់ ការអានតាមបែប«ប្មុក ប្មង់ប្មាញ់ ទ្មាក់ ផ្មឹក ប្មោយ»គឺពិតជាមានការលំបាកនៅក្នុងអំណាន ដោយអ្នកអានមានការប្រឹងអាន ដើម្បីបញ្ចេញសំឡេងមកក្រៅ។ ដូច្នេះ ដើម្បីធ្វើឲ្យមានភាពងាយស្រួលដល់អ្នកអានការប្រើអាគម«រ»ក៏កើតមានឡើង សម្រាប់ធ្វើឲ្យអ្នក

---

[៦១] ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ លេខ៤ ឆ្នាំ២០១០ ទំព័រ៦២។

អានកាន់តែមានភាពងាយស្រួលឡើងៗ នៅក្នុងការបន្លឺពាក្យទាំងនោះ។

ជាលទ្ធផលនៃទិន្នន័យដែលបង្ហាញខាងលើ ការប្រើប្រាស់អាគមគឺពិតជាកើតមាននៅក្នុងភាសាខ្មែរ ចំណែកឯ ពាក្យកម្លាយដែលជាលទ្ធផលនៃអន្តរកម្មរវាងពាក្យឫសនិងអន្តេបទ/-ម-/និង/-ន-/ក៏មានប្រើប្រាស់អាគមផងដែរ ដោយទិន្នន័យដែលយើងសង្កេតឃើញនោះ ការប្រើប្រាស់អាគមនៅក្នុងអន្តេបទទាំងពីរនេះ គឺភាគច្រើនមានប្រើត្រឹមតែអាគមមួយប៉ុណ្ណោះ ពោលគឺអាគម «រ»ដែលគេបង្កើតឡើងដើម្បីសម្រួលអំណាន ទៅលើពាក្យកម្លាយដែលជាលទ្ធផលនៃអន្តរកម្មរវាងពាក្យឫសនិងអន្តេបទ/-ម-/និង/-ន-/។

សរុបសេចក្ដីមក យើងយល់ឃើញថាបច្ចេកសព្ទដែលយើងបានធ្វើការសិក្សាខាងលើដែលរួមមាន វិធីកម្លាយ អញ្ញសបទ អន្តេបទ មូលតា កាឡាររូប និង អាគម គឺជាទិដ្ឋភាពមួយក្នុងការឆ្លុះបញ្ចាំងឲ្យឃើញអំពិពីការសិក្សាភាសាខ្មែរនៅក្នុងបរិបទនៃការសិក្សាអំពីអន្តេបទ/-ម-/និង/-ន-/។ បច្ចេកសព្ទទាំងនោះគឺជាពន្លឺដើម្បីបំភ្លឺការពន្យល់ ក៏ដូចជាការចេន្លុះបំភ្លឺផ្លូវសម្រាប់ការវិភាគនិងស្រាយបញ្ហាដែលកើតឡើងនៅក្នុងអន្តេបទ/-ម-/និង/-ន-/ ដោយមានទ្រឹស្ដីអន្តរកម្មនិយមជាបង្អែក។

# ការសិក្សាប្រៀបធៀប
# ព្យញ្ជនៈធនិតក្នុងភាសាខ្មែរ និង ថៃ [៦២]

ជុំ ស៊ុនណាង (Chom Sonnang)
អ្នកស្រាវជ្រាវខាងភាសា, វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា
និងជា គ្រូបង្រៀនភាសាខ្មែរ នៅសាកលវិទ្យាល័យមហាសារខាម ប្រទេសថៃ
សារអេឡិចត្រូនិក៖ snang_inl@yahoo.com
ទូរស័ព្ទ៖ ០១២ ៦២៥ ៣២៥

## ១. សេចក្តីផ្តើម

ភាសាខ្មែរ និង ភាសាថៃ ជាភាសាដែលស្ថិតនៅក្នុងអំបូរភាសាផ្សេងគ្នា។ ប៉ុន្តែបើពិនិត្យលើពាក្យឃើញថាភាសាទាំងពីរមានពាក្យជាច្រើនដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ប្រការនេះត្រូវបានការសិក្សាមួយចំនួនកន្លងមករកឃើញថា ភាសាទាំងពីរមានទំនាក់ទំនងនឹងគ្នាទាំងខាងប្រវត្តិសាស្ត្រយូរអង្វែង និងមានភូមិសាស្ត្រនៅក្បែរគ្នា ដែលនាំដល់ការទទួលឥទ្ធិពលរវាងគ្នានិងគ្នា។ ក្នុងនោះ ថៃបានខ្ចីពាក្យយ៉ាងច្រើនពីភាសាខ្មែរទាំងពាក្យប្រើប្រាស់ប្រចាំថ្ងៃពាក្យផ្លូវការពាក្យប្រើប្រាស់ក្នុងរាជវង្ស(រាជស័ព្ទ) និងពាក្យក្នុងអក្សរសិល្ប៍។ ចរន្តនៃការខ្ចីនេះបានចេញដំណើរពីខ្មែរទៅមុន គឺនៅសម័យដែលថៃទើបមកបានពើបប្រទះអរិយធម៌ថ្មី ប្លែក និង មានលក្ខណៈរុងរឿងជាងខ្លួន ម្ល៉ោះហើយខ្លួនឃើញថាសមល្មមនឹងទទួលបានខ្លួនក៏បានទទួលយកយ៉ាងពេញទំហឹងទៅ (អៀវ កើស ១៩៦៧ : ២៦២-២៦៣)។ ពាក្យរាប់ពាន់ត្រូវបានខ្ចីពីភាសាខ្មែរទៅ។ ពាក្យទាំងនោះជាពាក្យខ្មែរសុទ្ធផង ពាក្យកម្ចីបាឡីសំស្ក្រឹតផង។ ក្រោយពេលខ្មែរធ្លាក់ថមថយឥទ្ធិពល អរិយធម៌ខាងលិចបានហូរបញ្ច្រាសមកវិញ។ ស្ថិតក្នុងបរិបទឥទ្ធិពលភាសា ពាក្យថៃមួយចំនួនបានហូរចូលមកក្នុងភាសាខ្មែរ។

| | | ខ្មែរ | | ថៃ | | Gloss |
|---|---|---|---|---|---|---|
| (1) | (a) | /pha: hom/ | ផាហ៊ុម | /phâ: hum/ | ผ้าห่ม | blanket |
| | (b) | /pha: dip/ | ផាឌិប | /phâ: dip/ | ผ้าดิบ | unbleached muslin |
| | (c) | /wɛn ta:/ | វ៉ែនតា | /wɛ̂n ta:/ | แว่นตา | glasses |
| | (d) | /ti: neaŋ/ | ទីនាំង | /thî: naŋ/ | ที่นั่ง | seat |
| | (e) | /sɑm khan/ | សំខាន់ | /sǎm khǎn/ | สำคัญ | important, special |

[๖๒] การศึกษาเปรียบเทียบพยัญชนะธนิตในภาษาเขมรและภาษาไทย โดย จุม สุนนาง จาก สถาบันภาษาแห่งชาติ ราชบัณฑิตยสถานกัมพูชา ณ กรุงพนมเปญ ประเทศกัมพูชา

ចេញពីឧទាហរណ៍ខាងលើ យើងឃើញថាមានពាក្យខ្លះជាពាក្យថៃសុទ្ធ (1a-c)។ ក្រៅពីពាក្យថៃសុទ្ធដូចបានបង្ហាញ នៅមានពាក្យខ្មែរជាច្រើនដែលថៃខ្ចីទៅ ហើយបានហូរត្រឡប់មកក្នុងភាសាខ្មែរវិញ (1d – e)។ លោក អៀវ កើស (១៩៦៧ : ២៧៤) បានហៅពាក្យខ្ចីត្រឡប់មកវិញទាំងនោះថា ពាក្យសងបំណុល (reborrowing words)។ ខាងផ្នែកសម្ព័ន្ធវិទ្យា (syntax) វិញ ភាសាខ្មែរ និង ថៃក៏មិនខុសគ្នាប៉ុន្មានដែរ។ គួរកត់សម្គាល់ថា ភាគល្អិតនៃសម្ព័ន្ធវិទ្យាគឺចាប់តាំងពីបន្សំពាក្យដែលហៅថា កន្សោមពាក្យ (phrase) ឡើងទៅជាល្បះ។ ទម្រង់មូលដ្ឋាននៃសម្ព័ន្ធរបស់ភាសាទាំងពីរគឺ ប្រធាន + កិរិយាសព្ទ + កម្មបទ (SVO)។

| *ភាសា* | S | V | O | Gloss |
|---|---|---|---|---|
| *ខ្មែរ*<br>*ថៃ* | *ចាប*<br>นก | *យំ*<br>ร้อง | -<br>- | The bird cries/cried |
| *ខ្មែរ*<br>*ថៃ* | *ឆ្មា*<br>แมว | *ចាប់*<br>จับ | *ចាប*<br>นก | The cat catches the bird. |

តារាងទី 1. ការប្រៀបធៀបទម្រង់ល្បះភាសាខ្មែរនិងភាសាថៃ

យើងអាចនិយាយបានថា ទិដ្ឋភាពរួមនៃសម្ព័ន្ធវិទ្យារបស់ភាសាទាំងពីរមានលក្ខណៈដូចគ្នាច្រើន ហើយប្លែកគ្នាបន្តិចបន្តួចប៉ុណ្ណោះ។ សម្រាប់បន្លែកនេះសូមមើលឧទាហរណ៍ (2) ៖

| | | **ខ្មែរ** | **ថៃ** | **Gloss** |
|---|---|---|---|---|
| (2) | (a) | /bat ka: bo:p/ <u>បាត់</u>កាបូប | /kra pǎw hǎ:j/ กระเป๋า | The box is lost. |
| | (b) | /bej thaj tiet/ បីថ្ងៃ<u>ទៀត</u> | /ʔi:k sǎ:m wan/ <u>อีก</u>สาม | Three days more. |
| | (c) | /tɤw trɑŋ/ ទៅ<u>ត្រង់</u> | /troŋ paj/ <u>ตรง</u>ไป | To go straight |

នៅក្នុងឧទាហរណ៍ (2) នេះ ទីតាំងរបស់ពាក្យក្នុងភាសាថៃនិងភាសាខ្មែរមិនដូចគ្នាទេ ព្រោះមានការឆ្លាស់គ្នានៃពាក្យដែលគូសបន្ទាត់ពីក្រោម។

គួររំឭកថា ការសិក្សាលម្អិតទៅលើរឿងសម្ព័ន្ធវិទ្យាក៏ដូចជាវាក្យស័ព្ទមិនមែនជាប្រធានបទដែលត្រូវលើកយកមកពិភាក្សានៅទីនេះទេ។ ការលើកឡើងត្រួសៗខាងលើ គ្រាន់តែជាការបង្ហាញខ្លះៗ អំពីទិដ្ឋភាពរួមនិងទិដ្ឋភាពដោយឡែកដែលភាសាខ្មែរ និង ភាសាថៃមានតែប៉ុណ្ណោះ។ អ្វីដែលជាកម្មវត្ថុក្នុងអត្ថបទនេះ គឺការសិក្សាអំពីសូរ។ ហើយការសិក្សាអំពីសូរនេះទៀតសោត យើងនឹងពិនិត្យតែទៅលើព្យញ្ជនៈធនិតនៃភាសាខ្មែរនិងថៃប៉ុណ្ណោះ។ ទោះយ៉ាងណា យើងត្រូវលើកយកបញ្ហាមួយចំនួនដែលពាក់ព័ន្ធមកពិនិត្យជាមុនសិន។

បរិមាណពាក្យខ្មែរនិងពាក្យថៃ ដែលដូចឬស្រដៀងគ្នាដ៏ច្រើនដូចដែលបានលើកឡើងខាងលើ អាចជាលទ្ធផលនៃការជះឥទ្ធិពលរវាងគ្នានិងគ្នា។ គួបផ្សំនឹងឥទ្ធិពលរបស់ខ្មែរនៅសម័យអតីត ព្រមជាមួយនឹងមូលដ្ឋានសូរវិទ្យានៃភាសាទាំងពីរមានលក្ខណៈប្រហាក់ប្រហែលគ្នាច្រើននោះ ជាកត្តានាំឲ្យពាក្យនៃភាសាមួយអាចចូលទៅនៅក្នុងភាសាមួយទៀតបានយ៉ាងស្រួល។ ហេតុនេះការសិក្សាទាក់ទងនឹងពាក្យ ពិសេសក្នុងបរិបទបម្រែបម្រួលពាក្យ ជាចាំបាច់គេត្រូវពិនិត្យឲ្យបានល្អិតល្អន់ទៅលើសូរនៃភាសាទាំងពីរជាមុនសិន ថាតើមានលក្ខណៈដូចនិងខុសគ្នាកម្រិតណា។

ទិដ្ឋភាពដោយឡែកខាងសូរវិទ្យារបស់ភាសាខ្មែរនិងថៃ គឺ ស្នៀង[៦៣] (tone)។ បន្លែកន័យមួយភាគធំរបស់ពាក្យនៅក្នុងភាសាថៃត្រូវបានកំណត់ដោយវត្តមានរបស់ស្នៀង។ បានន័យថា ពាក្យថៃពីរពាក្យដែលមានធាតុផ្សំរបស់ព្យាង្គ (ព្យញ្ជនៈនិងស្រៈ) ដូចគ្នាទាំងអស់ អាចជាពាក្យពីរផ្សេងគ្នាបាន កាលណាពាក្យទាំងពីរនោះមានវត្តមាន ស្នៀង មិនដូចគ្នា។ ឧទាហរណ៍៖ /ba:n/ **บาน** មានន័យថា "រីក" និង /bâ:n/ **บ้าน** មានន័យថា "ផ្ទះ" ។ នៅក្នុងពាក្យទាំងពីរនេះមានទីតាំងព្យញ្ជនៈដើមព្យាង្គ /b/ ព្យញ្ជនៈចុងព្យាង្គ /n/ និងស្រៈ /a:/ ដូចគ្នា។ ប៉ុន្តែពាក្យទីមួយមានស្នៀងធម្មតា (mid tone) ចំណែកពាក្យទី២ មានស្នៀងឡើង (rising tone)។

ចំណែកភាសាខ្មែរមិនមានសទ្ទតាស្នៀងក្នុងការកំណត់ន័យពាក្យនីមួយៗ ដូច ភាសាថៃទេ។ ដោយសារតែវត្តមានស្នៀងនេះឯង ទើបមានម្តងនោះនាអតីតកាលមិនយូរមកនេះ ភាសាថៃត្រូវបានអ្នកភាសារាប់បញ្ចូលទៅក្នុងអំបូរភាសាចិនយួន។ ប៉ុន្តែបច្ចុប្បន្ន ទស្សនៈនេះត្រូវបានបដិសេធទៅវិញ ព្រោះឈរលើមូលដ្ឋានស្នៀង គេមិនអាចបែងចែកអំបូរភាសាបានទេ ដោយសារស្នៀងនេះទើបមានវត្តមានក្នុងភាសាក្នុងលោកប្រហែលជាងពីរពាន់ឆ្នាំកន្លងមកនេះឯង។ ការសិក្សាក្រោយមកទៀតបានរកឃើញថាភាសាថៃជាអំបូរភាសាមួយស្ថិតក្នុងអំបូរភាសាមេ ឈ្មោះថាអំបូរភាសាតៃ (ไท) (Tai Language Family) (สุริยา 1988 : 38) ។

មានការសិក្សាច្រើនថ្ងួនល្មមដែរហើយអំពីវត្តមានស្នៀងក្នុងភាសាថៃ ប៉ុន្តែបើនៅមានចំណុចខ្វះខាតប្រការណាមួយអំពីស្នៀងនេះ ក៏នៅទីនេះយើងសូមទុករឿងស្នៀងនេះសម្រាប់សិក្សាលើកក្រោយសិនចុះ ព្រោះវត្ថុបំណងនៃការសិក្សាទីនេះផ្តោតជាសំខាន់ទៅលើរឿងព្យញ្ជនៈ (consonants)។ ហើយបើនិយាយឲ្យរួមតូចបន្តិចទៅទៀត យើងក៏នឹងមិនសិក្សាលម្អិតអំពីព្យញ្ជនៈទាំងអស់ដែរ។ ទីនេះ យើងនឹងឬិចយកតែព្យញ្ជនៈមួយក្រុមប៉ុណ្ណោះមកសិក្សាប្រៀបធៀប នោះគឺ ព្យញ្ជនៈធនិត (ផ្ទុះបង្ហូរគ្រដុស) (aspirated stops)។

## ២. លក្ខណៈរួមនៃការសិក្សាអំពីព្យញ្ជនៈធនិត

---

[៦៣] នៅក្នុងភាសាខ្មែរនិងថៃមានពាក្យ វណ្ណយុត្តិ ដូចគ្នា។ ខ្មែរយើងប្រើពាក្យនេះសំដៅលើ គ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្សរ (ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧ : ១១៥៧) ដូចជាសញ្ញា ត្រីស័ព្ទ ( ៊ ), ខណ្ឌ (។), បន្តក់ ( ់ )... ។ ចំណែកភាសាថៃពាក្យ វណ្ណយុត្តិ (**วรรณยุกต์**) បានដល់កម្រិតសូរខ្ពស់ទាបក្នុងពាក្យ។ ភាសាថៃមាន វណ្ណយុត្តិ ចំនួន ៥ គឺ ធម្មតា ឯក ទោ ត្រី និង ចតុ (រាជបណ្ឌិត្យ ២០១១ : ១១០០)។ ខ្មែរហៅកម្រិតសូរទាំងនោះថា ស្នៀង។

ដើម្បីងាយស្រួលដល់ការសិក្សាអំពីរឿងនេះ  យើងសូមលើកយកតារាងសូរព្យញ្ជនៈនៃភាសាខ្មែរ (តារាងទី ២) និងថៃ (តារាងទី ៣) មកបង្ហាញជាមុនសិន។

| | Bilabial | Alveolar | Palatal | Velar | Glottal |
|---|---|---|---|---|---|
| Plosive | p  b | t  d | C | k | ʔ |
| Nasal | m | n | ɲ | ŋ | |
| Fricative | | s | | | h |
| Trill | | r | | | |
| Lateral Appr. | | l | | | |
| Approximant | w | | j | | |

តារាងទី 2.    សទ្ទតាព្យញ្ជនៈភាសាខ្មែរ

| | Bilabial | Labio-dental | Aveolar | Post-alveolar | Palatal | Velar | Glottal |
|---|---|---|---|---|---|---|---|
| Plosive | p  $p^h$[64] | | t  $t^h$  d | | k  $k^h$ | | ʔ |
| Nasal | m | | n | | | ŋ | |
| Fricative | | f | s | | | | h |
| Affricative | | | | tɕ  $tɕ^h$ | | | |
| Trill | | | r | | | | |
| Approximant | | | | | j | w | |
| Lateral Appr. | | | l | | | | |

តារាងទី 3.    សទ្ទតាព្យញ្ជនៈភាសាថៃ (*សម្រួលចេញពី* Tingsabadh. 1999 : 147)

ជួរឈរនីមួយក្នុងតារាងទី ២ ត្រូវបែងចែកជាពីរ។ ទីមួយជាជួរព្យញ្ជនៈ អឃោសៈ និងទីពីរជាជួរព្យញ្ជនៈឃោសៈ, ឧទាហរណ៍៖ p  b, t  d ។ ជួរឈរនីមួយៗ ក្នុងតារាងទី ៣ ចែកជាបីផ្នែកគឺ ផ្នែកទី១ សម្រាប់ព្យញ្ជនៈអឃោសៈ ទី២ សម្រាប់ព្យញ្ជនៈធនិត និងទី៣ សម្រាប់ព្យញ្ជនៈឃោសៈ, ឧទាហរណ៍៖ p  $p^h$  b, t  $t^h$  d ។

ផ្អែកលើតារាងទាំងពីរខាងលើ ភាសាខ្មែរមានសទ្ទតាព្យញ្ជនៈចំនួន ១៧ ឯភាសាថៃមានសទ្ទតាព្យញ្ជនៈ ២១។ ហេតុនេះក្នុងភាសាថៃមានចំនួនសទ្ទតាព្យញ្ជនៈលើសភាសាខ្មែរចំនួន ៤ គឺ ph, th, ch, និង kh។ ក៏ប៉ុន្តែបើយើងពិនិត្យនៅក្នុងភាសាខ្មែរ ឃើញថាមានពាក្យមិនតិចទេដែលមានព្យញ្ជនៈទាំងនេះ ។ សំណួរនឹងចោទឡើងថា ហេតុអ្វីបានជា ph, th, ch, និង  kh មិនត្រូវបានចាត់បញ្ចូលជាសទ្ទាតាព្យ-ញ្ជនៈទោលនៃភាសាខ្មែរដែរទៅ?

---

[៦៤] We transcribe aspirated by means of a raised 'h' = $p^h$, $t^h$, $c^h$, $k^h$.

តាមពិតមានអ្នកសិក្សាមួយចំនួន នៅតែចាត់ទុកថាព្យញ្ជនៈដូចបានបង្ហាញខាងលើជាព្យញ្ជនៈទោល (Single Consonant, Simplex consonant) ក្នុងភាសាខ្មែរ។ ទន្ទឹមនឹងនោះក៏មានអ្នកសិក្សាមួយចំនួនទៀតមិនចាត់បញ្ចូលជាព្យញ្ជនៈទោលទេ (Huffman 1967; Jacob 1968; ព្រុំ ម៉ល់ ២០០៦) ។ បញ្ហាពីរដែលនឹងយកមកបង្ហាញខាងក្រោមនេះគឺ ការចាត់ និង ការមិនចាត់ព្យញ្ជនៈខាងលើក្នុងភាសាថៃ និង ភាសាខ្មែរ ជាព្យញ្ជនៈទោល។

ការសិក្សាអំពីចំនួន ឬ អំពីវត្តមានសទ្ទតាព្យញ្ជនៈ ស្រៈ រហូតដល់ធាតុផ្សេងៗ នៃសូរក្នុងភាសាបានកើតឡើងក្នុងរង្វង់អ្នកសូរវិទ្យាជាច្រើនទសវត្សមកហើយ។ កាលដើមឡើយការកំណត់ចំនួនព្យញ្ជនៈក្តី ស្រៈក្តី ផ្អែកទៅលើតួអក្សរក្នុងភាសានីមួយៗ (Orthographic perspective)។ តាមទស្សនៈនេះ ក្នុងភាសាខ្មែរមានព្យញ្ជនៈ ៣៣ ព្រោះខ្មែរមានតួព្យញ្ជនៈ ៣៣ តួ។ ចំណែកភាសាថៃ មានព្យញ្ជនៈ ៤៤ សូរ ព្រោះថៃមានតួព្យញ្ជនៈ ៤៤ តួ។ ក្រោយមក ការកំណត់ចំនួនព្យញ្ជនៈតាមរបៀបនេះត្រូវគេគិតថាជាការយល់ច្រឡំ ព្រោះតួអក្សរទាំងនោះប្រៀប បានទៅនឹងរូបសញ្ញាតំណាងឲ្យសូរនៃភាសាប៉ុណ្ណោះ។ សូរខ្លះមានអក្សរតំណាងឲ្យច្រើនតួ ពោលគឺ អក្សរមួយតួៗ មិនបានតំណាងឲ្យសូរតែមួយៗ នោះទេ។ ឧទាហរណ៍ អក្សរ ក គ ក្នុងភាសាខ្មែរ តាងឲ្យសូរតែមួយគឺ /k/ ។ លើសពីនេះ នៅក្នុងកម្រិតសូរវិទ្យា (65) (phonetics) អក្សរ ក គ អាចមានសូរផ្សេងមួយទៀត គឺ [ʔ][៦៦] កាលណារូបព្យញ្ជនៈនេះប្រើជាព្យញ្ជនៈប្រកប ដូចជា ភាគ [phẹa:ʔ], ចាក [ca:ʔ]។ ករណីនេះមិនមែនកើតមានឡើងតែក្នុងភាសាខ្មែរនោះទេ សូម្បីភាសាអង់គ្លេសដែលមនុស្សភាគច្រើនចាត់ទុកថាជាភាសាស្រួលរៀននោះក៏មានបញ្ហាមិនពិតប្រាកដនៃរូបសំណេរនិងការបន្លឺសូរនេះដែរ។ អក្សរ o និង u នៃភាសានេះជួនកាលតាងឲ្យសូរ [ʌ] ដូចក្នុងពាក្យ son [sʌn] និង sun [sʌn]។ នៅក្នុងពាក្យមួយចំនួនទៀតអក្សរ o តាងឲ្យសូរ [oʊ] ក៏មាន ដូចក្នុងជាពាក្យ open [oʊpᵊn] និង hotel [hoʊtel] ។ នៅក្នុងពាក្យខ្លះទៀត o តាងឲ្យសូរ [ɒ] ទៅវិញ ដូចនៅក្នុងពាក្យ hot [hɒt] និង not [nɒt]។

ប្រការដូចបានលើកឡើងខាងលើនេះហើយ ទើបនាំទៅដល់ការរិះរកសញ្ញាតំណាង ដោយ មិនយករូបព្យញ្ជនៈដូចពោលខាងលើមកធ្វើជាមូលដ្ឋាននៃការសិក្សាសូរក្នុងភាសា។ រូបតំណាងទាំងនោះគេហៅថា អក្ខរក្រមសូរវិទ្យាអន្តរជាតិ (ព្រុំ ម៉ល់. ២០០៦) ដែលសរសេរកាត់ជា IPA មកពីពាក្យថា (International Phonetic Alphabets)។ ទោះយ៉ាងណាក្តីក៏រូបសញ្ញាថ្មីនេះផ្អែកលើរូបអក្សរឡាតាំងដដែល ប៉ុន្តែអ្នកភាសាវិទ្យាបានកំណត់ឲ្យយករូបមួយតាងឲ្យសូរមួយ សម្រាប់ប្រើប្រាស់ក្នុងរង្វង់អ្នកភាសា ។

វិធីមួយក្នុងចំណោមវិធីនានា ដែលប្រើក្នុងការសិក្សាកំណត់រកចំនួនសូរពិតប្រាកដក្នុងភាសានីមួយៗ បានផ្អែកទៅលើការសិក្សាគូអប្បបរមា (minimal pair)។ ការសិក្សាគូអប្បបរមា គឺការនាំយក

---

[៦៥] ភាគ : /phẹa:k/ (កម្រិតសទ្ទតាវិទ្យា phonemics) → [phẹa:ʔ] (កម្រិតសូរវិទ្យា phonetics)

[៦៦] ក្នុងទីតាំងជាព្យញ្ជនៈចុងព្យាង្គដូចឧទាហរណ៍ពាក្យខាងលើ ខ្មែរកម្ពុជាក្រោមនៅរក្សាធម្មភាពដើមនៃព្យញ្ជនៈ ក នៅឡើយ ។ នេះជាបន្លែកមួយដែលអាចឲ្យខ្មែរកណ្តាលស្តាប់ទៅអាចដឹងថាអ្នកនោះជាខ្មែរក្រោមបាន ។

ពាក្យពីរមកប្រៀបធៀបគ្នា។ ពាក្យទាំងពីរនេះមានចំនួនសមាសធាតុផ្សំដូចគ្នា ព្រមទាំង មានការរៀងលំដាប់សូរត្រូវគ្នា។ ប៉ុន្តែក្នុងសមាសធាតុទាំងអស់នោះ មានធាតុមួយប៉ុណ្ណោះមិនដូចគ្នា។ ធាតុដែលមិនដូចគ្នានោះ មានផលធ្វើឲ្យពាក្យទាំងពីរមានន័យខុសគ្នា។ ធាតុទាំងពីរនោះត្រូវបានគេចាត់ទុកថាជាសទ្ទតាផ្សេងគ្នា, សូមមើលឧទាហរណ៍ (3)។

| | | ពាក្យទី ១ | | ពាក្យទី ២ | | **Gloss** |
|---|---|---|---|---|---|---|
| (3) | (a) | /ca:p̲/ | ចាប | /ca:m̲/ | ចាម | bird ; the Cham |
| | (b) | /b̲a:n/ | បាន | /d̲a:n/ | ដាន | obtain ; trace |
| | (c) | /s̲ɑ:k/ | សក | /c̲ɑ:k/ | ចក | shed skin ; duckweed |

ព្យញ្ជនៈមួយគូរ ៗ ដែលគូសបន្ទាត់ពីក្រោម ក្នុងឧទាហរណ៍ (3a), (3b), (3c) គឺ /b/ – /d/, /p/ – /m/ និង /s/ – /c/ តាមលំដាប់ គឺជាគូអប្បបរមា។ វត្តមាននៃព្យញ្ជនៈទាំងនោះធ្វើឲ្យមានបន្លែកន័យពាក្យ។ ហេតុនេះ យើងបាន [p] , [b] , [m] , [c] និង [s] ជាសទ្ទតាព្យញ្ជនៈផ្សេងគ្នា។

ការសិក្សាវិភាគរកចំនួនសូរព្យញ្ជនៈក្នុងភាសាថៃ (คณะกรรมการกลุ่มผลิตชุดรายวิชาภาษาไทย 3. 2548 : 228-230) និងភាសាខ្មែរបានប្រើវិធីសិក្សារកគូអប្បបរមាដូចបានបង្ហាញខាងលើនេះជាមូលដ្ឋាន។ ជាលទ្ធផល ភាសាថៃនិងភាសាខ្មែរមានសទ្ទ-តាព្យញ្ជនៈចំនួន ២១ ដូចគ្នា ព្រោះ $p^h$, $t^h$, $c^h$ និង $k^h$ បានធ្វើឲ្យពាក្យមានបន្លែកន័យ និងនាំទៅដល់ការចាត់ព្យញ្ជនៈទាំងនេះជាព្យញ្ជនៈទោលក្នុងភាសាទាំងនេះ។ ប៉ុន្តែការសិក្សាអំពីសទ្ទតាព្យញ្ជនៈខ្មែរមិនបាននៅទ្រឹងត្រឹមនេះទេ ព្រោះការសិក្សាក្រោយមកទៀតបានរកឃើញថាចំនួននេះបានថយមកត្រឹម១៧សទ្ទតា។ ពេលនេះយើងសូមលើកយកបញ្ហានេះមកអធិប្បាយបន្តិច។ ហេតុអ្វីទើបសទ្ទតាព្យញ្ជនៈខ្មែរមានតែ១៧ ?

វិធីបង្កើតពាក្យក្នុងភាសាខ្មែរមានជាអាទិ៍៖ បន្សំ កម្លាយ សមាស... ។ ប្រព័ន្ធបង្កើតពាក្យតាមបែបកម្លាយជាវិធីមួយដែលនិយមប្រើនាសម័យអតីតកាល។ ការបង្កើតពាក្យដោយវិធីកម្លាយនេះមានវត្តមានក្នុងអំបូរភាសាមន-ខ្មែរ អស់កាលជាយូរមកហើយ។ ការកម្លាយ ពាក្យ គឺជាការនាំយកពាក្យឫសមួយមកផ្សំជាមួយនឹងមូលបទ (affix) ដើម្បីបង្កើតពាក្យថ្មី។ ពាក្យថ្មីនេះមិនមានបន្លែកន័យជាមួយនឹងពាក្យដើមទេ ប៉ុន្តែមានមុខងារខាងវេយ្យាករណ៍ (gramatical function) ផ្សេងគ្នា។ ពាក្យឫសនិងពាក្យកម្លាយក្នុងឧទាហរណ៍ (4) មានន័យដើម (primitive meaning) ដូចគ្នា ប៉ុន្តែមុខងារពាក្យឫសជាកិរិយាស័ព្ទ ចំណែកពាក្យកម្លាយជានាមស័ព្ទ, មើលក្នុងឧទាហរណ៍ (4a-c) ឬ ពាក្យឫសជាកិរិយាស័ព្ទសកម្ម ឯពាក្យកម្លាយជាកិរិយាស័ព្ទអសកម្ម, មើលឧទាហរណ៍ (4d-e)។

| | | **ពាក្យឫស** | | | **ពាក្យកម្លាយ** | | **Gloss** |
|---|---|---|---|---|---|---|---|
| (4) | (a) | /kaət/ | កើត | > | /khnaət/ | ខ្នើត | to bear > period of waxing moon |
| | (b) | /daə/ | ដើរ | > | /dɑm naə/ | ដំណើរ | to walk > a walk |
| | (c) | /rẹam/ | រាំ | > | /rɔ bam/ | របាំ | to dance > a dance |

| | | | | | | |
|---|---|---|---|---|---|---|
| (d) | /troːw/ | ត្រូវ | > | /tɑm roːw/ | តម្រូវ | right > adjust, correct |
| (e) | /kaət/ | កើត | > | /bɑŋ kaət/ | បង្កើត | to bear > to give birth to |

ចំណែកមូលបទនីមួយៗ ដែលនាំយកមកប្រើក្នុងការបង្កើតពាក្យ ក៏សុទ្ធសឹងមានន័យនិងមុខងារខាងវេយ្យាករណ៍របស់ខ្លួនជាក់លាក់ដែរ ពិសេសក្នុងភាសាខ្មែរបុរាណ។ ប៉ុន្តែមកដល់បច្ចុប្បន្ននៅសល់មូលបទតែពីរបីប៉ុណ្ណោះដែលនៅរក្សានិរន្តភាពរបស់ខ្លួនបានច្រើនជាងមូលបទផ្សេងទៀត។ ឧទាហរណ៍មូលបទ /p-/, មូលបទនេះប្រើសម្រាប់បង្កើតកិរិយាស័ព្ទហេតុ (Causitive verb) ដែលមានន័យថា "ធ្វើឲ្យ, បណ្ដាលឲ្យ" ដូចក្នុងឧទាហរណ៍ (4e)។ ទន្ទឹមនឹងនេះ មូលបទផ្សេងទៀតនៅក្នុងឧទាហរណ៍ (4b) និង (4d) មិនបានរក្សាលក្ខណៈដើមបាននឹងនរល្អដូចមូលបទ /p-/ទេ។ ប៉ុន្តែមូលបទនេះនៅមានវត្តមាននៅឡើយក្នុងភាសាខ្មែរ ព្រោះមានពាក្យកម្លាយច្រើនណាស់ដែលកើតចេញពីបន្សំរវាងមូលបទនេះជាមួយពាក្យឫស។

គួរសង្កេតថា មូលបទដែលប្រើក្នុងឧទាហរណ៍ (4b) និង (4d) ទំនងជាមានទម្រង់ដើមជា /Vm/ (V ជាស្រៈ , m ជាព្យញ្ជនៈ ច្រមុះរង្វះបន្ទះ) ។ /Vm/ មានកាឡូរូបស័ព្ទ (allo-morph) ច្រើនសណ្ឋានដូចជា ɑm/n (អំម/ន) , ɔm/n (អុំម/ន), ɑm (អំម), ɔm (អុំម) ។ កាឡូរូបស័ព្ទទាំងនេះកើតឡើងដោយយោងទៅតាមប្រភេទព្យញ្ជនៈដើមព្យាង្គ។ ក្នុងនោះ ទម្រង់ ɑm ឬ ɔm ប្រើសម្រាប់ផ្សំជាមួយពាក្យឫសដែលមានព្យញ្ជនៈដើមព្យាង្គជាព្យញ្ជនៈបន្តឹល្បាយ [67] (complex onset ឬ initial cluster consonant), មើលក្នុងឧទាហរណ៍ (4d) និង (5) ។ ចំណែក ɔm/n ឬ ɑm/n ប្រើផ្សំជាមួយពាក្យឫសដែលផ្ដើមដោយព្យញ្ជនៈទោល (simplex onset) ដូចក្នុងឧទាហរណ៍ (4b) ។

| | | | **ពាក្យឫស** | | | **ពាក្យកម្លាយ** | **Gloss** |
|---|---|---|---|---|---|---|---|
| (5) | (a) | /prap/ | ប្រាប់ | > | /bɑm rap/ | បម្រាប់ | to tell > cue |
| | (b) | /slot/ | ស្លុត | > | /sɑm lot/ | សម្លុត | anxious > threat |
| | (c) | /sruol/ | ស្រួល | > | /sɑm ruol/ | សម្រួល | easy > ease |
| | (d) | /krọŋ/ | គ្រោង | > | /kɔm rọŋ/ | គម្រោង | to plan > frame |

ក្នុងឧទាហរណ៍ (5) ខាងលើនេះ ពាក្យឫសផ្ដើមដោយព្យញ្ជនៈបន្តឹល្បាយ pr, sl, sr, kr ។ ព្យញ្ជនៈបន្តឹល្បាយទាំងនេះត្រូវបានបំបែកដោយមូលបទ ɔm ឬ ɑm ក្នុងពាក្យកម្លាយឲ្យទៅជា p + r, s + l, s + r, k + r តាមលំដាប់ ។ ចំណែកក្នុងឧទាហរណ៍ (4b) ពាក្យឫសផ្ដើមដោយព្យញ្ជនៈដើមព្យាង្គជាព្យញ្ជនៈទោល ហេតុនេះវេយ្យាករណ៍ខ្មែរតម្រូវឲ្យមានការថែម n ទៅក្នុងពាក្យកម្លាយ ពោលគឺ Vm > Vm/n ។ ទាំងនេះបង្ហាញថា វត្តមានរបស់មូលបទ Vm អាចឲ្យយើងដឹងអំពីសមាសធាតុផ្សំរបស់ព្យញ្ជនៈដើមព្យាង្គ ថាតើជាព្យញ្ជនៈទោល ឬ ព្យញ្ជនៈបន្តឹល្បាយ ។

[៦៧] ខ្មែរយើងនិយមហៅព្យញ្ជនៈបន្តឹល្បាយថា ព្យញ្ជនៈផ្ញើជើង ។

François Martini បានសាងស្នាដៃជាច្រើនទាក់ទងទៅនឹងខ្មែរ។ ក្នុងនោះលោកបានសិក្សាលើប្រធានបទមួយ ដែលទាក់ទងទៅនឹងវត្តមានព្យញ្ជនៈធនិត (aspirated consonants) នេះ។ លទ្ធផលរួមនៃការស្រាវជ្រាវរបស់លោកអំពីព្យញ្ជនៈខ្មែរបានបង្ហាញថា ph, th, ch និង kh ជាបន្សំរវាងព្យញ្ជនៈពីរពោលគឺក្រុមព្យញ្ជនៈទាំងនេះមានតម្លៃស្មើនឹងព្យញ្ជនៈផ្សំ (បន្លឺល្បាយ) មិនមែនព្យញ្ជនៈទោលទេ។ ខាងក្រោមនេះជាឧទាហរណ៍ដែលបញ្ជាក់អំពីរឿងនេះ ។

| | | ពាក្យឫស | | | ពាក្យកម្លាយ | | Gloss |
|---|---|---|---|---|---|---|---|
| (6) | (a) | /khœŋ/ | *ខឹង* | > | /kɑm hœŋ/ | *កំហឹង* | angry > anger |
| | (b) | /khaːk/ | *ខាក* | > | /kɑm haːk/ | *កំហាក* | spit out > spittle |
| | (c) | /cheaːn/ | *ឈាន* | > | /cɔm heaːn/ | *ជំហាន* | to step > step |
| | (d) | /thɔm/ | *ធំ* | > | /thɔm hɔm/ | *ទំហំ* | big > being big |

ពាក្យឫសទាំងអស់ក្នុងឧទាហរណ៍ (6) សុទ្ធតែផ្ដើមដោយ kh, ch, th។ ព្យញ្ជនៈទាំងនេះត្រូវបំបែកជា t + h, c + h, k + h ដោយមូលបទ Vm ។ ការបំបែកនេះមានលក្ខណៈដូច ដែលបង្ហាញក្នុងឧទារណ៍ (5) អីចឹងដែរ។ ហេតុនេះហើយទើបលោក François Martini ឈានដល់ការសន្និតថា kh, ch, th ជាបន្សំព្យញ្ជនៈ មិនមែនព្យញ្ជនៈទោលទេ។ ក្រោយមកស្នាដៃរបស់លោកត្រូវបានចាត់ទុកថា ជាបេកគំហើញថ្មីនៃអវត្តមានព្យញ្ជនៈផ្ទុះបង្ហូរត្រដុសក្នុងភាសាខ្មែរ។ ទោះបីជាគេមិនទាន់រកឃើញថា ph ជាព្យញ្ជនៈបន្លឺល្បាយឬជាព្យញ្ជនៈទោល ព្រោះនៅមិនទាន់មានឧទាហរណ៍មាំទាំណាមួយមកបញ្ជាក់ដូច kh ch th ដូចបានបង្ហាញខាងលើនៅឡើយក្ដី ក៏នៅក្នុងការសិក្សាអំពីសូរវិទ្យាខ្មែរ មានអ្នកភាសាមួយចំនួនបានកំណត់យកលទ្ធផលដែលរកឃើញដោយលោក François Martini ខាងលើ ទៅប្រើក្នុងការសិក្សារបស់ខ្លួនទៅហើយ។ ប៉ុន្តែបណ្ឌិតព្រុំ ម៉ល់ (២០០៦ : ២៣) ហាក់ស្ថិតនៅក្នុងសម្មតិកម្មនៅឡើយចំពោះវត្តមាននៃព្យញ្ជនៈធនិត។

## ៣. ព្យញ្ជនៈធនិតនៅក្នុងសំណង់ព្យាង្គ

បញ្ហាវត្តមានព្យញ្ជនៈធនិតក្នុងភាសាខ្មែរ និង ថៃ ប្រៀបដូចជាការនាំគ្នាធ្វើការសន្និតច្រើនជាងការធ្វើពិសោធន៍ជាក់ស្ដែង។ ព្រោះបើភាសាថៃមានប្រព័ន្ធបង្កើតពាក្យរបៀបខ្មែរ ឬមានអ្វីដែលមានលទ្ធភាពបំបែកព្យញ្ជនៈបន្លឺល្បាយ នោះសមនឹងថា ថៃក៏មិនមានព្យញ្ជនៈធនិតដែរហើយ។ អត្ថបទនេះមិនមានគោលដៅនឹងវែកញែកឲ្យស៊ីជម្រៅអំពីវត្តមានព្យញ្ជនៈប្រភេទនេះក្នុងភាសាទាំងពីរទេ ប៉ុន្តែគ្រាន់តែទាញការសង្កេតជារួមដូចបានអធិប្បាយរួចមកហើយ។ ទោះយ៉ាងណាក្ដី នៅក្នុងការសិក្សានេះយើងសូមប្រើ

ពាក្យ ព្យញ្ជនៈធនិត (ជាបណ្ដោះអាសន្ន) ដើម្បីហៅឈ្មោះព្យញ្ជនៈមួយពួកដែលមានបន្លែកលក្ខណៈ (distinctive feature) របស់ខ្លួនជា voiceless stop + h ។

តទៅនេះយើងនឹងពិនិត្យលើសមាសភាពរបស់ព្យញ្ជនៈទាំងនោះនៅក្នុងសំណង់ព្យាង្គ ។ តារាងខាងក្រោមបង្ហាញអំពីរូបតំណាងនៃព្យញ្ជនៈទាំងនេះ។

| IPA | ខ្មែរ | ថៃ |
|---|---|---|
| ph | ផ ភ | พ ภ ผ |
| th | ឋ ថ ឌ ឍ ធ | ท ธ ฐ ฒ ฑ ถ |
| ch | ឆ ឈ | ช ฉ ฌ |
| kh | ខ ឃ | ค ข ฆ |

តារាងទី 4. តារាងព្យញ្ជនៈធនិត សូរ និង រូប

រូបព្យញ្ជនៈទាំងនេះ មានមួយចំនួនអាចផ្ទៀបគ្នាបានយោងតាមលំដាប់អក្ខរក្រមខ្មែរថៃ (មើលក្នុងតារាងព្យញ្ជនៈខ្មែរថៃក្នុងឧបសម្ព័ន្ធនៃអត្ថបទនេះ)។ នៅក្នុងនោះ พ ท ฑ ช និង ค កត់សូរព្យញ្ជនៈធនិតក្នុងភាសាថៃ ph th th ch ចំណែកក្នុងភាសាខ្មែរ អក្សរទាំង ព ទ ឌ ជ និង គ ប្រើសម្រាប់កត់សូរព្យញ្ជនៈសិថិលទាំងអស់ គឺ p t d c និង k។

## ៣.១. ព្យញ្ជនៈទោលដើមព្យាង្គក្នុងពាក្យមួយព្យាង្គ

នៅទីនេះ យើងនឹងពិនិត្យលទ្ធភាពក្នុងសមាសភាពជាព្យញ្ជនៈដើមព្យាង្គរបស់ព្យញ្ជនៈធនិត។ ទម្រង់ព្យាង្គក្នុង (7) មានលក្ខណៈជា ៖

$C_1V(C_2)$

($C_1$ ព្យញ្ជនៈធនិត, V ស្នូលព្យាង្គ, $C_2$ ជាព្យញ្ជនៈចុងព្យាង្គ អាចមានឬមិនមានក៏បាន)

| | | ពាក្យខ្មែរ | | ពាក្យថៃ | | Gloss |
|---|---|---|---|---|---|---|
| (7) | (a) | /phɛ/ | ផែ | /phîː/ | พี่ | port ; elder |
| | (b) | /thaː/ | ថា | /thɔː/ | ทอ | to say ; to weave |
| | (c) | /chaː/ | ឆា | /chɨ̂a/ | เชื่อ | fry ; believe |
| | (d) | /khɑo/ | ខោ | /khɔ̌ː/ | ขอ | trouser ; ask for |
| | (e) | /phaəŋ/ | ផើង | /phaːn/ | พาน | basin ; pass |

| | | | | | |
|---|---|---|---|---|---|
| (f) | /thɑŋ/ | ថង់ | /thǒŋ/ | ถุง | bag ; bag |
| (g) | /cha:k/ | ឆាក | /chà:k/ | ฉาก | scene ; scene |
| (h) | /khoh/ | ខុស | /kho:m/ | โคม | wrong ; lamp |

ឧទាហរណ៍ (7a – 7h) បង្ហាញថា ព្យញ្ជនៈធនិតទាំងអស់ក្នុងភាសាខ្មែរនិងភាសាថៃអាចប្រើជាព្យញ្ជនៈទោលដើមព្យាង្គបានដូចគ្នា ទាំងក្នុងព្យាង្គបើកនិងក្នុងព្យាង្គបិទ។

## ៣.២. ព្យញ្ជនៈទោលដើមព្យាង្គក្នុងព្យាង្គទី ១

ទម្រង់ព្យាង្គក្នុង (8) មានលក្ខណៈជា ៖

ព្យាង្គទី១ ព្យាង្គទី២

$C_1V_1(C_2)$ $C_3V_2(C_4)$ "$C_1$ ជាព្យញ្ជនៈធនិត"

| | | ពាក្យខ្មែរ | | ពាក្យថៃ | | Gloss |
|---|---|---|---|---|---|---|
| (8) | (a) | /pha: dip/ | ផាទិប | /pha: sǎ:/ | ภาษา | unbleached muslin ; language |
| | (b) | /thea: nea:/ | ធានា | /tha: wɔ:n/ | ถาวร | assure ; enduring |
| | (c) | /chɑo lɑo/ | ឆោឡោ | /chom pû:/ | ชุมพู่ | turmoil ; rose apple |
| | (d) | /khan tej/ | ខន្តី | /kha nɛ:n/ | | be patient ; score |

## ៣.៣. ព្យញ្ជនៈទោលដើមព្យាង្គក្នុងព្យាង្គទី ២

ទម្រង់ព្យាង្គក្នុង (9) មានលក្ខណៈជា ៖

ព្យាង្គទី១ ព្យាង្គទី២

$C_1V_1(C_2)$ $C_3V_2(C_4)$ "$C_3$ ជាព្យញ្ជនៈធនិត"

| | | ពាក្យខ្មែរ | | ពាក្យថៃ | | Gloss |
|---|---|---|---|---|---|---|
| (9) | (a) | /bɑm phoh/ | បំផុស | /chom phû:/ | ชุมพู่ | activate ; rose apple |
| | (b) | /kɑn thɑo/ | កន្ថោរ | /kha: thǎ:/ | คาถา | spitting pot ; the spell |
| | (c) | /kaɲ chɛ:t/ | កញ្ឆែត | /ban cha:/ | | water mimosa ; to order |
| | (d) | /bɑŋ khɑm/ | បង្ខំ | /ni khom/ | นิคม | to force ; community |

ពាក្យដែលមានព្យាង្គទី២ផ្ដើមដោយធនិតក្នុងភាសាខ្មែរមិនសូវមានពាក្យធម្មតា (simple word) ប៉ុន្មានទេ។ ពាក្យទាំងនោះច្រើនជាពាក្យកម្លាយ (derivative word) ដែលមានពាក្យឫសផ្ដើមដោយ

ព្យញ្ជនៈធនិតស្រាប់ (9a , 9d)។ ចំណែកក្នុងភាសាថៃវិញ ពាក្យប្រភេទនេះច្រើនតែជាពាក្យកម្ចី (9b – 9d) ។

## ៣.៤. ព្យញ្ជនៈទោលដើមព្យាង្គក្នុងព្យាង្គទាំងពីរ

ទម្រង់ព្យាង្គក្នុងផ្នែកនេះមានលក្ខណៈជា ៖

ព្យាង្គទី១ ព្យាង្គទី២

$C_1V_1(C_2)$ $C_3V_2(C_4)$ "$C_1$ និង C3 ជាព្យញ្ជនៈធនិត"

ការរណ្ដំព្យាង្គជាវិធីមួយដែលតែងកើតមានឡើងនៅក្នុងភាសា។ ប៉ុន្តែវិធីនេះមិនមានលក្ខណៈដូចគ្នាទាំងអស់សម្រាប់គ្រប់ភាសានោះទេ។ ពាក្យរណ្ដំមានព្យាង្គយ៉ាងតិចពីរព្យាង្គ។

នៅក្នុងវគ្គនេះយើងនឹងពិនិត្យលើពាក្យដែលមានព្យាង្គទី១និងព្យាង្គទី២ផ្ដើមដោយព្យញ្ជនៈធនិតដូចគ្នា គឺ $C_1$ និង $C_3$ ជាធនិត។

| | | ពាក្យខ្មែរ | | ពាក្យថៃ | | Gloss |
|---|---|---|---|---|---|---|
| (10) | (a) | /pheh phɑŋ/ | ផេះផង់ | /phə̂:m phu:n/ | | ash ; increase |
| | (b) | /thɔm thɔɑt/ | ធំធាត់ | /thâ: thi:/ | ท่าที | grow, fat ; attitude |
| | (c) | /che:w cha:w/ | ឆេវឆាវ | /chə̂:t chu:/ | เชิด | easily angry ; to boost |
| | (d) | /khet khɑm/ | ខិតខំ | /khàp khì:/ | ขับขี่ | to try ; to drive |

ឧទាហរណ៍ (10) បង្ហាញថាព្យញ្ជនៈធនិតទាំងក្នុងភាសាខ្មែរទាំងក្នុងភាសាថៃមានលទ្ធភាពបង្កើតពាក្យរណ្ដំដែលមានព្យញ្ជនៈដើម្បីនៃព្យាង្គទាំងពីរ ។

## ៣.៥. ព្យញ្ជនៈបន្សំល្បាយដើមព្យាង្គក្នុងពាក្យមួយព្យាង្គ

ដោយយោងការចាត់លំដាប់ព្យញ្ជនៈក្នុងតារាងទី១និងទី២ តទៅនេះយើងនឹងបែងចែកប្រភេទព្យញ្ជនៈបន្សំល្បាយដែលផ្ដើមដោយព្យញ្ជនៈធនិតជា ៥ ទម្រង់ និងមួយទម្រង់ទៀតជាបន្សំរវាងព្យញ្ជនៈទូទៅផ្សំជាមួយព្យញ្ជនៈធនិត ។

១. Aspirated + stop (p, b, t, d, c, k, ʔ)

២. Aspirated + Nasal (m, n, ɲ, ŋ)

៣. Aspirated + Fricative (f, s, h)

៤. Aspirated + Glide (r, l)

៥. Aspirated + Approximant (w, j)

៦. Consonant + Aspirated

### ៣.៥.១. ធនិត + រង្វះបន្ទុះ (Aspirated + stop)

ដោយផ្អែកតាមលក្ខណៈខ្យល់ ព្យញ្ជនៈផ្ទុះក្នុងភាសាខ្មែរនិងភាសាថៃមានចំនួន ៧ គឺ /p, b, t, d, c, k, ʔ/ ។ នៅក្នុងតារាងខាងក្រោមនេះ អក្សរ *Kh* និង *Th* ជាអក្សរកាត់របស់ពាក្យ Khmer និង Thai តាមលំដាប់ ។

| | p | | b | | T | | d | | c | | k | | ʔ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* |
| ph | - | - | - | - | + | - | - | - | + | - | + | - | + | - |
| th | + | - | - | - | - | - | - | - | - | - | + | - | - | - |
| ch | + | - | + | - | - | - | + | - | - | - | + | - | + | - |
| kh | + | - | + | - | + | - | - | - | + | - | - | - | - | - |

តារាងទី 5. បន្សំល្បាយរវាងព្យញ្ជនៈធនិតនិងព្យញ្ជនៈផ្ទុះ

ក្នុងភាសាខ្មែរ បន្សំល្បាយរវាង Aspirated + stop មានចំនួន ១៥ គូ។ ចំណែកក្នុងភាសាថៃ បន្សំល្បាយរវាង Aspirated + stop មិនមានទេ។

### ៣.៥.២. ធនិត + ព្យញ្ជនៈនាសិកជះ (Aspirated + Nasal)

| | M | | n | | n | | n | |
|---|---|---|---|---|---|---|---|---|
| | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* |
| ph | - | - | + | - | + | - | + | - |
| th | + | - | + | - | - | - | + | - |
| ch | + | - | + | - | - | - | + | - |
| kh | + | - | + | - | + | - | + | - |

តារាងទី 6. បន្សំល្បាយរវាងព្យញ្ជនៈធនិតនិងព្យញ្ជនៈច្រមុះ/នាសិកជះ

ក្នុងភាសាខ្មែរ បន្សំល្បាយរវាង Aspirated + Nasal មានចំនួន ១៣ គូ។ ចំណែកក្នុងភាសាថៃ បន្សំល្បាយរវាង Aspirated + Nasal មិនមានទេ។

### ៣.៥.៣. ធនិត + ព្យញ្ជនៈរង្វះត្រដុស (Aspirated + Fricative)

| | f | | s | | h | |
|---|---|---|---|---|---|---|
| | *Kh* | *Th* | *Kh* | *Th* | *Kh* | *Th* |
| ph | - | - | + | - | - | - |
| th | - | - | - | - | - | - |
| ch | - | - | - | - | - | - |
| kh | - | - | + | - | - | - |

តារាងទី 7. បន្សំល្បាយរវាងព្យញ្ជនៈធនិតនិងព្យញ្ជនៈត្រដុស

ក្នុងភាសាខ្មែរ បន្ទីល្បាយរវាង Aspirated + Fricative មានចំនួន ២ គូ។ ចំណែកក្នុងភាសាថៃ មិនមានបន្ទីល្បាយរវាង Aspirated + Nasal ទេ។

### ៣.៥.៤. ធនិត + ព្យញ្ជនៈរង្វះលំហូរ (Aspirated + Liquid)

រវាងព្យញ្ជនៈ r និង l មានលក្ខណៈបន្ទីផ្សេងគ្នា គឺ Trill និង Lateral Approximant ។ ប៉ុន្តែ អ្នកសូរវិទ្យាមួយចំនួនបានហៅព្យញ្ជនៈទាំងពីរជាឈ្មោះតែមួយថា liquid ។

| | r | | l | |
|---|---|---|---|---|
| | *Kh* | *Th* | *Kh* | *Th* |
| ph | - | + | + | + |
| th | - | + | + | - |
| ch | - | - | + | - |
| kh | - | + | + | + |

តារាងទី 8. បន្ទីល្បាយរវាងព្យញ្ជនៈធនិតនិងព្យញ្ជនៈរអិល

ភាសាខ្មែរមានបន្ទីល្បាយ Aspirated + liquid ចំនួន ៤ គូ។ ចំណែកភាសាថៃមាន ៥ គូ។ យើងឃើញថា បន្ទីល្បាយ phr thr និង khr មិនមានវត្តមានក្នុងរចនាសម្ព័ន្ធសូរនៃភាសាខ្មែរទេ។ ប្រការនេះជាហេតុធ្វើឲ្យខ្មែរបញ្ចេញសំឡេង phr, thr និង khr មិនបានឬពិបាកបន្ទី។ ហេតុនេះខ្មែរដែលរៀនភាសាថៃពិបាកក្នុងការបញ្ចេញសំឡេងពាក្យដែលមានព្យញ្ជនៈបន្ទីល្បាយបែបនេះ, មើលឧទាហរណ៍ (11) ។

| | | ថៃបញ្ចេញសំឡេង | | ខ្មែរបញ្ចេញសំឡេង | **Gloss** |
|---|---|---|---|---|---|
| (11) | (a) | **พระ** | /phra/ | [pra] | Monk |
| | (b) | **จันทรา** | /can thra:/ | [can tra] | Moon |
| | (c) | **ครบ** | /khrop/ | [krop] | Enough |
| | (d) | **ครับ** | /khrap/ | [krap] | Enough |

ប្រការនេះទាមទារឲ្យសិក្សាត្រូវមានការហ្វឹកហាត់យ៉ាងហ្មត់ចត់ ។

### ៣.៥.៥. ធនិត + ព្យញ្ជនៈកន្លះ (Aspirated + Glide)[68]

អ្នកសូរវិទ្យាមួយចំនួនបានចាត់បញ្ចូល /w/ និង /j/ ទៅក្នុងប្រភេទស្រៈ គឺស្រៈកន្លះ ប៉ុន្តែមានអ្នកខ្លះទៀតបានចាត់ /w/ និង /j/ ថាជាព្យញ្ជនៈកន្លះទៅវិញ ហើយបានដាក់ព្យញ្ជនៈប្រភេទនេះទៅ

[៦៨] មានការប្រើពាក្យបច្ចេកផ្សេងគ្នាក្នុងការហៅព្យញ្ជនៈ /w/ *និង* /j/ ដូចជា glide, approximant, semi-vowel ។ នៅក្នុងអត្ថបទនេះ យើងហៅព្យញ្ជនៈប្រភេទនេះថា ព្យញ្ជនៈកន្លះ តាមបណ្ឌិត ព្រុំ ម៉ល់ (២០០៣ : ៤៨) ។

ក្នុងតារាងសទ្ទតាព្យញ្ជនៈ (Carr. 1993 : 145, ព្រុំ ម៉ល់. ២០០៣ : ៤៨)។ ការសិក្សានាពេលនេះកំណត់យកទស្សនៈទី ២ ដែលថា /w/ និង /j/ ជាព្យញ្ជនៈកន្លះ។

| | w Kh | w Th | j Kh | j Th |
|---|---|---|---|---|
| ph | - | - | + | - |
| th | + | - | - | - |
| ch | + | - | - | - |
| kh | + | + | + | - |

តារាងទី ៩. បន្ទឹល្បាយរវាងព្យញ្ជនៈធនិតនិងព្យញ្ជនៈកន្លះ

ក្នុងតារាងខាងលើនេះ ព្យញ្ជនៈធនិតនៅក្នុងភាសាខ្មែរអាចប្រើផ្គួបជាមួយព្យញ្ជនៈកន្លះបានប្រាំគូ ចំណែកភាសាថៃអាចប្រើបានមួយគូ។

### ៣.៥.៦. ព្យញ្ជនៈធនិត (Consonant + Aspirated)

ព្យញ្ជនៈបន្ទឹល្បាយដែលមានព្យញ្ជនៈធនិតស្ថិតនៅបន្ទាប់មិនសូវមានទេ។ នៅក្នុងភាសាខ្មែរលំដាប់បែបនេះមានតែបួនគូប៉ុណ្ណោះ គឺ mph mkh sth និង lkh។ ចំណែកក្នុងភាសាថៃមិនមានទេ។ បន្ទឹល្បាយទាំងនេះមានតែក្នុងជាទម្រង់ សទ្ទតាវិទ្យា ប៉ុណ្ណោះ ។ នៅក្នុងទម្រង់សូរវិទ្យា បន្ទឹល្បាយទាំងនេះត្រូវជែកស្រៈ [ə] (ə epenthesis), សូមមើលក្នុងឧទាហរណ៍ (12)។ ការដែលមានបញ្ចេកស្រៈអាចមកពីសរីរាង្គបន្ទឺសំឡេងត្រូវបញ្ចេញសូរ m ឬ l ឲ្យផុតសិន ទើបចាប់ផ្ដើមសូរព្យញ្ជនៈទី ២ ជាក្រោយ ។ បន្ទឹល្បាយបែបនេះគេឲ្យឈ្មោះថា បន្ទឹល្បាយមិនស្និទ្ធ។

(12) (a) /mkhaːŋ/ ម្ខាង ข้างเดียว one side
(b) /mphẹj/ ម្ភៃ ยี่สิบ twenty
(c) /sthet/ ស្ថិត อยู่ at
(d) /lkh/ ល្ខោន ละคร drama

**សរុបមក** ព្យញ្ជនៈធនិតទាំងក្នុងភាសាថៃ ទាំងក្នុងភាសាខ្មែរអាចឈរជាព្យញ្ជនៈដើមព្យាង្គនៃពាក្យមួយព្យាង្គបានទាំងអស់។ ពាក្យពីរព្យាង្គភាគច្រើន ដែលមានព្យញ្ជនៈធនិតស្ថិតនៅដើមព្យាង្គនៃព្យាង្គទី១ មិនសូវជាពាក្យថៃឬខ្មែរសុទ្ធទេ គឺច្រើនតែជាពាក្យកម្ចី។ ក្នុងសមាសភាពជាព្យញ្ជនៈបន្ទឹល្បាយ, ធនិតក្នុងភាសាខ្មែរមានលទ្ធភាពផ្សំជាមួយព្យញ្ជនៈផ្សេងទៀតបានច្រើនជាងធនិតក្នុងភាសាថៃ។ ប៉ុន្តែក្នុងភាសាខ្មែរមិនមានបន្ទឹល្បាយរវាង ធនិត + រ។

## ៤. ព្យញ្ជនៈចុងព្យាង្គ (Coda)

សទ្ទតាព្យញ្ជនៈក្នុងភាសាខ្មែរនិងភាសាថៃទាំងអស់អាចប្រើជាព្យញ្ជនៈដើមព្យាង្គបាន។ ប៉ុន្តែក្នុង

តំណែងចុងព្យាង្គ មានព្យញ្ជនៈមួយចំនួនប៉ុណ្ណោះដែលអាចប្រើក្នុងតំណែងនេះបានទេ។ ទោះនៅក្នុងសំណេរ យើងតែងសង្កេតឃើញមានរូបព្យញ្ជនៈទាំងនោះត្រូវបានគេសរសេរនៅចុងព្យាង្គក្តី ក៏ព្យញ្ជនៈទាំងនោះមិនអាចបន្លឺចេញមកបានទាំងស្រុងដែរ ដោយសារបន្ថែកលក្ខណៈ (distinctive feature) ខ្លះរបស់ព្យញ្ជនៈទាំងនោះត្រូវបាត់ ឬមានការប្រែប្រួល, មើលឧទាហរណ៍(13)។ យ៉ាងណាក្តី រូបសំណេរទាំងនោះអាចជួយយើងបានមួយកម្រិតអំពីទម្រង់សទ្ទតាវិទ្យារបស់ពាក្យ។ មកដល់ត្រឹមនេះ យើងសូមបើកវង់ក្រចកបន្តិចដើម្បីអធិប្បាយអំពីអ្វីទៅដែលហៅថាទម្រង់សទ្ទតាវិទ្យា។ គេបែងចែកការសិក្សាសូរនៃភាសាជាពីរផ្នែកធំៗ គឺ សូរវិទ្យា (phonetics) និង សទ្ទតាវិទ្យា (phonology) ។ ទម្រង់សទ្ទតាវិទ្យា (underlying form)[៦៩] បានដល់ទិន្នន័យពាក្យដែលមាននៅក្នុងខួរក្បាលរបស់ម្ចាស់ភាសាម្នាក់ៗ។ ទម្រង់នេះនឹងមានការប្រែប្រួលកាលណាគេបន្លឺពាក្យនោះចេញមក ពោលគឺមិនបានរក្សារូបដើមទាំងស្រុងទេ។ យើងសូមហៅពាក្យដែលយើងបានឮនោះថាទម្រង់សូរវិទ្យា ត្រូវនឹងពាក្យអង់គ្លេសថា (surface form) ។ ឧទាហរណ៍ (13) ខាងក្រោមនេះ នឹងបង្ហាញអំពីបន្លែករវាង ទម្រង់សទ្ទតាវិទ្យា ធៀបគ្នានឹង ទម្រង់សូរវិទ្យា នៃពាក្យនីមួយៗ។

| | | ទម្រង់សទ្ទតាវិទ្យា | | ទម្រង់សូរវិទ្យា | Gloss |
|---|---|---|---|---|---|
| (13) | (a) | មាឌ /mead/ | → | [meat] | size |
| | (b) | ចាស /ca:s/ | → | [ca:h] | respond particle for female |
| | (c) | សាប/sa:b/ | → | [sa:p] | sow |
| | (d) | ชล /chɔl/ | → | [chɔn] | collide |
| | (e) | ทาส /thas/ | → | [that] | slave |
| | (f) | บด /bod/ | → | [bot] | grind |

យើងឃើញថា d s b l នៅក្នុងឧទាហរណ៍ (13) មិនបានរក្សាលក្ខណៈដើម ឬ ធម្មភាពដើមរបស់ខ្លួនទេ។

ជាបន្តយើងនឹងសិក្សាទៅលើលទ្ធភាពព្យញ្ជនៈធនិតនៅក្នុងតំណែងជាព្យញ្ជនៈចុងព្យាង្គ។

| | | ទម្រង់សទ្ទតាវិទ្យា | | ទម្រង់សូរវិទ្យា | Gloss |
|---|---|---|---|---|---|
| (14) | (a) | លោភ /lọph/ | → | [lọp] | ambition |
| | (b) | រថ /rɔth/ | → | [rɔt] | vehicle |
| | (c) | សុខ /sokh/ | → | [sok] | happiness |

[៦៩] មានការហៅផ្សេងគ្នាអំពីពាក្យបច្ចេកទេសនេះ។

- ទម្រង់សទ្ទតាវិទ្យា ៖ underlying form, input, underlying representative, phonemic
- ទម្រង់សូរវិទ្យា ៖ Surface form, output, surface representative, phonetic.

(d) ภาพ /pha:ph/ → [phá:p] draw
(e) รถ /roth/ → [rót] vehicle
(f) โรค /ro:kh/ → [ró:k] disease, illness
(g) ราช /ra:ch/ → [rá:t] king

មិនខុសពីការលើកឡើងពីខាងដើមនេះប៉ុន្មានទេ យើងតែងឃើញពាក្យជាច្រើនដែលសរសេរព្យញ្ជនៈធនិតជាព្យញ្ជនៈប្រកប។ ទោះណារូបព្យញ្ជនៈទាំងនោះត្រូវបានគេប្រើជាព្យញ្ជនៈចុងព្យាង្គបែបនេះក្តី ក៏ម្ចាស់ភាសា (ខ្មែរ ថៃ) មិនអាចបញ្ចេញសំឡេងព្យញ្ជនៈទាំងនោះឲ្យដូចនៅជាតំណែងព្យញ្ជនៈដើមព្យាង្គបានដែរ ពោលគឺ ធម្មជាតិជាធនិតត្រូវបាត់ ដោយប្តូរមកជាព្យញ្ជនៈសិថិលវិញ។

តាមការពិនិត្យជារួម សំណេរព្យញ្ជនៈធនិតក្នុងតំណែងជាព្យញ្ជនៈចុងព្យាង្គ ច្រើនតែធ្វើឡើងសម្រាប់សរសេរពាក្យកម្ចី បាឡី-សំស្ក្រឹត។ សម្រាប់ពាក្យខ្មែរ ឬ ថៃ ព្យញ្ជនៈទាំងនោះមិនសូវនិយមប្រើរូបព្យញ្ជនៈធនិតទេ។ ជាមួយគ្នានេះដែរ តាមរយៈឧទាហរណ៍ (13) និង (14) នៅក្នុងភាសាថៃមានព្យញ្ជនៈចុងព្យាង្គចំនួន ១០ ចំណែកខ្មែរមានចំនួន ១៣។

## សេចក្តីសន្និដ្ឋាន

ព្យញ្ជនៈធនិតក្នុងភាសាខ្មែរនិងភាសាថៃមានលទ្ធភាពប្រើជាព្យញ្ជនៈដើមព្យាង្គបានទាំងអស់។ វត្តមានព្យញ្ជនៈធនិតនៅក្នុងពាក្យពហុព្យាង្គអាចប្រាប់អំពីប្រភពពាក្យបានថា ពាក្យនោះភាគច្រើនជាពាក្យកម្ចី។

ចំនួនព្យញ្ជនៈបន្តឹល្បាយសរុប នៅក្នុងភាសាខ្មែរមានចំនួន ៤១ គូ។ ភាសាថៃមានចំនួន៣គូ។ ឃើញថាភាសាខ្មែរមានចំនួនព្យញ្ជនៈបន្តឹល្បាយផ្តើមដោយព្យញ្ជនៈធនិតច្រើនជាងភាសាថៃ។ ប្រការនេះជាហេតុនាំឲ្យថៃដែលរៀនភាសាខ្មែរមានការលំបាកបញ្ចេញសំឡេងពាក្យខ្មែរដែលមានបន្តឹល្បាយទាំងនេះ ។ បញ្ហាស្រដៀងគ្នានេះដែរ គឺ ភាសាខ្មែរមិនមានបន្តឹល្បាយ phr thr khr ដែលបន្តឹល្បាយទាំងនេះមានវត្តមានក្នុងភាសាថៃ។ អវត្តមានបន្តឹល្បាយទាំងនេះ នាំឲ្យខ្មែរដែលរៀនភាសាថៃមានការពិបាកបញ្ចេញសំឡេងពាក្យថៃដែលមានបន្តឹល្បាយខាងលើ។ ប្រសិនបើគេមិនបានទទួលការហ្វឹកហាត់ត្រឹមត្រូវ អ្នករៀនខ្មែរភាគច្រើននឹងបន្តឹសូរល្បាយ phr thr khr ជា pr tr kr ។ ហេតុនេះទាមទារឲ្យអ្នកសិក្សាក៏ដូចជាអ្នកបង្រៀនត្រូវយល់អំពីបញ្ហានេះ និងហាត់ហ្វឹកប្រកបដោយវិធីសាស្ត្រត្រឹមត្រូវ។

ក្នុងបរិបទជាព្យញ្ជនៈចុងព្យាង្គ ព្យញ្ជនៈធនិតបានប្រែមកជាព្យញ្ជនៈសិថិលទាំងអស់ ទោះក្នុងក្បួនសំណេរ គេតែងសង្កេតឃើញមានប្រើព្យញ្ជនៈទាំងនេះជាព្យញ្ជនៈចុងព្យាង្គក៏ដោយ។ ពាក្យភាគច្រើនដែលប្រើព្យញ្ជនៈធនិតជាព្យញ្ជនៈចុងព្យាង្គ ជាពាក្យកម្ចី ពិសេសកម្ចីពីភាសាបាឡីសំស្ក្រឹត។

# គន្ថនិទ្ទេស

ព្រុំ ម៉ល់. មូលដ្ឋាននៃសូរវិទ្យា សទ្ទតាវិទ្យា វិជ្ជាសន្ទាន. ភ្នំពេញ : រាជបណ្ឌិតសភាកម្ពុជា, ២០០៣.

ពុទ្ធសាសនបណ្ឌិត្យ. វចនានុក្រមភាសាខ្មែរ ភាគ១ និង ភាគ២ បោះពុម្ពគ្រាទី ៥. ភ្នំពេញ : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧.

คณะกรรมการกลุ่มผลิตชุดรายวิชาภาษาไทย 3. <u>เอกสารการสอนชุดวิชาภาษาไทย</u> 3 หน่วยที่ 1-6. นนทบุรี มหาวิทยาลัยสุโขทัยธรรมาธิราช. 2548. (228-230)

วีณา วงศ์ศรีเผือก และคณะ. <u>ภาษาไทย ป.2.</u> กรุงเทพฯ: บริษัทอักษรเจริญทัศน์. 2551.

สุริยา รัตนกุล. นานาภาษาในเอเชียอาคเนย์ ภาคที่ 1. กรุงเทพฯ: ศูนย์วิจัยวัฒนธรรมเอเชียอาคเนย์ มหาวิทยาลัยมหิดล, 2531.

สุริยา รัตนกุล. นานาภาษาในเอเชียอาคเนย์ : ภาษาตระกูลไท. กรุงเทพฯ : สหธรรมิก, 2548.

Carr, Philip. <u>Phonology</u>. London: The Macmillan Press Ltd., 1993.

Henderson, Eugnie J.H., “The main features of Cambodian Pronunciation”, in <u>Bulletin of School of Oriental and African Studies 14</u> (p. 149-174), 1952.

Huffman, Franklin E. <u>An Outline of Cambodian Grammar</u>. Doctor’s Thesis. Cornell University, 1967.

Jacob, Judith M. <u>Introduction to Cambodian</u>. London: Oxford University Press, 1968.

Karnchana Nacaskul. <u>An Phasa Khmen</u> [Textbook] (in Thai). Bangkok: Chulalongkorn University Press, 198?.

Kœus, Ieu. <u>La langue Cambodgienne: un essai d' etude raisonnée</u> (in Khmer). Phnom Penh: Buddhist Institute, 1967.

Martini, François. “Aperçu phonologique du cambodien”. Bulletin de la Société Linguistique de Paris 42 (p. 112-132), 1942-1945

Moal, Prum. <u>Khmer Structural Grammar</u> (in Khmer). Phnom Penh: Royal Academy of Cambodia, 2003b.

Odden, David. <u>Introducing Phonology</u>. Cambridge: Cambridge University Press, 2005.

# ទ្រឹស្តីអន្តរកម្មនិយមនិងការអនុវត្តនៅក្នុងក្របខណ្ឌ នៃការស្រាវជ្រាវនិក្ខេបបទ

ឃឹម វិច្ឆិកា

## មូលន័យសង្ខេប


Abstract

**L'interactionnisme et son application dans le cadre de la recherche linguistique**

Depuis longtemps, la recherche concernant la langue khmère est basée sur la grammaire traditionnelle. Cependant, depuis la fin du XX$^{e}$ siècle et le début du XXI$^{ème}$ siècle, le mouvement de la recherche scientifique rigoureuse sur la langue khmère, mené par des chercheurs cambodgiens, avance de manière remarquable. On peut, en particulier souligner une intéressante découverte théorique due à M. CHAN Samnoble, l'« Interactionnisme».

Cette théorie est née de l'analyse primordiale de la langue khmère. Cette théorie peut être appliquée à l'étude d'autres langues. Aujourd'hui, on voit apparaître des thèses produites par des étudiants Chinois, Vietnamiens, Japonais et Thaïlandais) sous la direction de créateur de l'Interactionnisme.

L'interactionnisme introduit l'idée selon laquelle «*le sens d'une unité de la langue (phonème, sons, mots, morphème, phrase etc.) est le résultat de l'interaction mutuelle entre cette unité de la langue et son co-texte dans un contexte ponctuel. L'unité de la langue et le co-texte sont les catalyseurs sémantiques, et le contexte est le régulateur du sens* ».

Certains ont fait une confusion entre l'Interactionnisme et la mise en relation. Ces deux processus sont tout à fait différents : la mise en relation n'est que la volonté absolue de la personne qui utilise la langue. Il n'y a pas de relation absolue entre l'unité de la langue et son co-texte, on (.) met juste deux ou plusieurs composants ensemble, sans tenir compte de la liaison syntaxique et sémantique ; par exemple la mise en relation entre ស្បែក (peau) et ជើង(jambe) donne deux possibilités ស្បែកជើង (peau-jambe) et*ជើងស្បែក (jambe-peau).Tandis que l'Interactionnisme se caractérise par la relation mutuelle syntaxique et sémantique : entre l'unité de langue et son co-texte, entre chaque composant et le composant syntagmatique et vice versa ; par exemple l'Interactionnisme entre ស្បែក (peau) et ជើង(jambe) et vice versa, donne ស្បែកជើង (peau-jambe) qui a deux sens possibles, l'un étant la peau couvrant la jambe , l'autre sens étant la chaussure.

En appliquant l'Interactionnisme à l'unité de langue កម្ម (kamma) faisant partie de notre thèse intitulée « **procédure khmère dans la création des mots du Khmer contemporain**», on a fait l'hypothèse ci-dessous :

កម្ម (kamma) est un composant dépendant syntaxique et a une valeur de suffixe

កម្ម (kamma) est un mot indépendant.

## ១- ក្របខណ្ឌទ្រឹស្តី

តាំងពីដើមរៀងមក ចំពោះការសិក្សាពីភាសាខ្មែរ យើងច្រើនតែផ្អែកលើវេយ្យាករណ៍ប្រពៃណី។ លុះមកដល់ចុងសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១ ចលនានៃការសិក្សាស្រាវជ្រាវទៅលើភាសាខ្មែរដោយជនជាតិខ្មែរបានបោះជំហានចូលក្នុងដំណាក់កាលជឿនលឿនតាមបែបវិទ្យាសាស្ត្រ ហើយបាននាំមកនូវរបកគំហើញលើភាសាខ្មែរដោយបានបង្កើតជាទ្រឹស្តីថ្មីមួយដែលស្ថាបនិកកំណត់ហៅថា ទ្រឹស្តីអន្តរកម្មនិយម។

ទ្រឹស្តីនេះកើតចេញពីការវិភាគទៅលើភាសាខ្មែរជាបឋម ហើយទាញជាគោលការណ៍អនុវត្តលើផ្នែកន័យនីយកម្មមុននឹងក្លាយទៅជាទ្រឹស្តីដែលមានសកលភាពនិងវិសាលភាពអនុវត្តលើផ្នែក ផ្សេងៗទៀតនៃភាសា ជាអាទិ៍លើផ្នែកវេយ្យាករណ៍ សម្ព័ន្ធ... រហូតដល់អាចយកទៅអនុវត្តលើភាសានានាក្នុងលោកទៀតផង។ យើងឃើញមានសារណានៃនិស្សិតចិន និងសារណារបស់និស្សិតវៀតណាម ជប៉ុន ថៃ ដែលស្ថិតក្រោមការដឹកនាំរបស់ស្ថាបនិកទ្រឹស្តីនេះជាសក្ខីភាពបញ្ជាក់ស្រាប់។

អន្តរកម្មនិយមគឺជាទ្រឹស្តីមួយក្នុងការវិភាគភាសានិងត្រូវបានបង្កើតឡើងដោយបណ្ឌិត ច័ន្ទ សំណព្វ នៅឆ្នាំ២០០០ ដោយផ្តើមចេញពីការសិក្សាពីន័យនៃឯកតាភាសាខ្មែរ។ ដោយមាន លក្ខណៈជាសាកល ហើយឆ្លើយតបទៅនឹងការអនុវត្តជាក់ស្តែងក្នុងការវិភាគភាសាខ្មែរនោះ ទ្រឹស្តី អន្តរកម្មនិយមត្រូវបានស្ថាបនិកក៏ដូចជាអ្នកសិក្សាអក្សរសាស្ត្រនិងភាសាវិទ្យាយកមកអនុវត្តយ៉ាងទូលំទូលាយនៅពេលគេវិភាគភាសាខ្មែរក្នុងគ្រប់ទិដ្ឋភាពទាំងអស់។

អន្តរកម្មនិយមបានចែងថា៖ *«ន័យរបស់ឯកតាភាសាមួយ(រូបសព្ទ ពាក្យ សំណុំពាក្យ ឃ្លា វាទរូប កថាខណ្ឌ។ល។)កើតឡើងតាមរយៈអន្តរកម្មរវាងឯកតាភាសានោះជាមួយសហបទរបស់វានៅក្នុងបរិបទមួយកំណត់ច្បាស់លាស់។ ឯកតាភាសានិងសហបទជាចលករនៃន័យ រីឯបរិបទជានិយ័តករនៃន័យ»។*[៧០]

---

[៧០] បណ្ឌិត ច័ន្ទ សំណព្វ ទ្រឹស្តីអន្តរកម្មនិយម ឯកសារបង្រៀនថ្នាក់បណ្ឌិតជំនាន់ទី៣ នៃរាជបណ្ឌិត្យសភាកម្ពុជា ២០១៣

*«ធាតុដែលជាសហបទឬបរិបទជាធាតុដែលត្រូវកំណត់ឡើងក្នុងយន្តការនៃការស្ថាបនាន័យនៃឯកតាភាសា ហើយគ្មានធាតុណាមួយដែលមានបុរេលក្ខណៈជាសហបទ ឬជាបរិបទមុនយន្តការនេះឡើយ។ ក្នុងក្របខណ្ឌនៃទ្រឹស្តីនេះ អន្តរកម្មជាចលនាសកម្មទ្វេទិសរវាងធាតុនិងធាតុនៃសំណុំពាក្យមួយ និងរវាងធាតុនីមួយៗទៅនឹងសំណុំទាំងមូលផង។»*[៧១]

ចលនាសកម្មទ្វេទិសមិនមែនជាការដាក់ឱ្យមានទំនាក់ទំនងទៅវិញទៅមករវាងធាតុមួយនិងធាតុមួយទេ តែជាចលនាសកម្មមួយដែលស្តែងឡើងតាមរយៈលក្ខណៈសម្ព័ន្ធនិងវិសាលកម្មនៃធាតុនិងសំណុំពាក្យនៅក្នុងយន្តការនៃការស្ថាបនាន័យនៃឯកតាភាសាមួយ។ យើងអាចរំលេចពីភាពខុសគ្នារវាងការដាក់ឱ្យមានទំនាក់ទំនងគ្នារវាងធាតុនិងធាតុ និងចលនាសកម្មទ្វេទិសនៃទ្រឹស្តីអន្តរកម្មនិយមតាមរយៈគំនូសតាងដូចខាងក្រោម៖

## ក- ទំនាក់ទំនងរវាងធាតុនិងធាតុ




*រូបគំនូសតាងទី១ ការដាក់ឱ្យមានទំនាក់ទំនងរវាងធាតុនិងធាតុ*

នៅក្នុងសង្គម បុរសម្នាក់រៀបការជាមួយស្ត្រីម្នាក់ ឬបុរសម្នាក់រស់នៅជាមួយនឹងស្ត្រីម្នាក់ ដោយមិនមានការរួមភេទដែលឈានទៅដល់ការបង្កើតកូន គឺជាការដាក់ឱ្យមានទំនាក់ទំនងរវាងបុរសម្នាក់នោះនិងស្ត្រីម្នាក់នោះតែប៉ុណ្ណោះ។

នៅក្នុងភាសា ការដាក់ឱ្យមានទំនាក់ទំនងរវាងធាតុមួយនិងធាតុមួយទៀតស្តែងឡើងតាម រយៈឧទាហរណ៍ដូចខាងក្រោម៖

**ក្នុងកម្រិតពាក្យនិងពាក្យ** ការដាក់ឱ្យមានទំនាក់ទំនងរវាង *ស្បែក* និង *ជើង* នាំឱ្យគេបាន *ស្បែកជើង* និង **ជើងស្បែក* ដែលការដាក់ឱ្យមានទំនាក់ទំនងនេះអនុលោមទៅតាមឆន្ទៈរបស់មនុស្សទៅតាមបំណងប្រាថ្នាក្នុងការ សន្ទនា។

**ក្នុងកម្រិតកន្សោមពាក្យនិងកន្សោមពាក្យ** យើងពិនិត្យមើលឧទាហរណ៍ខាងក្រោម៖

(ក) ថ្ងៃនេះ ខ្ញុំបានឈប់សម្រាក។

(ខ) ខ្ញុំបានឈប់សម្រាក ថ្ងៃនេះ។

ល្បះ(ក)និង(ខ)ត្រឹមត្រូវនិងមានន័យដូចគ្នា ទោះបីជាទីតាំងរបស់កន្សោមពាក្យ *ថ្ងៃនេះ* មិនស្ថិតនៅក្នុងទីតាំងដូចគ្នាក៏ដោយ ព្រោះថា កន្សោមពាក្យ *ថ្ងៃនេះ* និង កន្សោមពាក្យ *ខ្ញុំបានឈប់សម្រាក*

[៧១] សេចក្តីពន្យល់របស់សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ក្នុងពេលដឹកនាំនិក្ខេបបទថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៤

មិនបានចងសម្ព័ន្ធគ្នាទេ វាគ្រាន់តែជាការដាក់ឱ្យមានទំនាក់ទំនងផ្នែកសម្ព័ន្ធនៃកន្សោមពីរផ្សេងគ្នា និងអនុលោមទៅតាមឆន្ទៈរបស់មនុស្សក្នុងការសន្ទនាតែប៉ុណ្ណោះ។




## ខ- ចលនាសកម្មទ្វេទិស




*រូបតំនូសតាងទី២ ចលនាសកម្មទ្វេទិសនៃទ្រឹស្ដីអន្តរកម្មនិយម*

នៅពេលដែលមានធាតុពីរចូលរួមអន្តរកម្ម យន្តការនៃការស្ថាបនាន័យបានមកពីចលនាសកម្មទ្វេទិសពោលគឺ ចលនាសកម្មនៃធាតុនិងធាតុ ចលនាសកម្មនៃធាតុនីមួយៗទៅនឹងសំណុំពាក្យ និងចលនាសកម្មរវាងសំណុំពាក្យទៅនឹងធាតុនីមួយៗវិញ។ បរិបទជានិយ័តករនៃន័យ ពោលគឺជាធាតុដែលធ្វើឱ្យមានលំនឹងផ្នែកន័យនៃសំណុំពាក្យដែលបានចារឹកនៅក្នុងក្របខណ្ឌនៃការប្រើប្រាស់មួយ។

នៅក្នុងកត្តាជីវសាស្ត្រ ស្ត្រីម្នាក់រៀបការជាមួយនឹងបុរសម្នាក់មិនអាចស្តែងចេញជាអន្តរកម្មទេ ការនេះគ្រាន់តែជាការដាក់ឱ្យមានទំនាក់ទំនងរវាងស្ត្រីនិងបុរសតែប៉ុណ្ណោះ។ អន្តរកម្មរវាងស្ត្រីនិងបុរសស្តែងឡើងនៅក្នុងការរួមភេទដែលនាំទៅដល់ការបង្កើតកូន។ ដូច្នេះ កូនមិនមែនជារបស់បុរសតែម្នាក់ឯង ឬជារបស់ស្ត្រីតែម្នាក់ឯងទេ តែកូនកើតឡើងតាមរយៈអន្តរកម្ម(ការរួមភេទ)រវាងស្ត្រីនិងបុរស។

នៅក្នុងគីមីវិទ្យា ការដាក់ឱ្យមានទំនាក់ទំនងរវាងឧស្ម័នអុកស៊ីសែន($O_2$)និងឧស្ម័នអ៊ីដ្រូសែន($H_2$) បង្កើតបានជាល្បាយឧស្ម័នអុកស៊ីសែន($O_2$)និងឧស្ម័នអ៊ីដ្រូសែន($H_2$)។ ចំណែកឯ អន្តរកម្មរវាងអុកស៊ីសែន($O_2$)និងឧស្ម័នអ៊ីដ្រូសែន($H_2$) ស្តែងឡើងនៅក្នុងប្រតិកម្មរវាងឧស្ម័នអុកស៊ីសែន($O_2$)និងឧស្ម័នអ៊ីដ្រូសែន($H_2$) នៅពេលមានផ្កាភ្លើងដើម្បីបង្កើតបានជាទឹក។

នៅក្នុងភាសា អន្តរកម្មរវាង *ស្បែក* និង *ជើង* មិនអាចបង្កើតឱ្យបានជា *ស្បែកជើង* ផង និង * *ជើងស្បែក* ផង ដូចការដាក់ឱ្យមានទំនាក់ទំនងរវាង *ស្បែក* និង *ជើង* ទេ ព្រោះថា អន្តរកម្មរវាង *ស្បែក*

និង *ជើង* ដែលបានចងសម្ព័ន្ធគ្នាតាមរយៈចលនាសកម្មទ្វេទិសបង្កើតបានតែសំណុំពាក្យ *ស្បែកជើង* តែប៉ុណ្ណោះ។ តាមរយៈចលនាសកម្មទ្វេទិសនេះ ន័យរបស់សំណុំពាក្យ *ស្បែកជើង* អាចមានន័យពីរគឺស្បែកជាប់នឹងជើង ផង និងទ្រនាប់ជើងសម្រាប់ពាក់ផង ហើយតាមរយៈបរិបទ លំនឹងផ្នែកន័យនៃសំណុំពាក្យ *ស្បែកជើង* បានចារឹកនៅក្នុងក្របខណ្ឌនៃការប្រើប្រាស់មួយ។

នៅក្នុងការវិភាគវេយ្យាករណ៍ ន័យរបស់ផ្នត់ដែក *[-ន-]* មិនមែនសម្រាប់សម្គាល់តែនាមករដូចដែលវេយ្យាករណ៍ប្រពៃណីបានបង្ហាញនោះទេ។ តាមទ្រឹស្តីអន្តរកម្មនិយម ន័យរបស់ផ្នត់ដែក *[-ន-]* ស្តែងឡើងតាមរយៈអន្តរកម្មរវាងផ្នត់ដែក *[-ន-]* ជាមួយនឹងសហបទរបស់វា(ជាតុដែលជាពាក្យឫស) នៅក្នុងបរិបទជាក់លាក់ណាមួយ ពោលគឺចលនាសកម្មទ្វេទិសរវាងផ្នត់ដែក *[-ន-]* និងពាក្យឫស៖ ចលនាសកម្មរវាងផ្នត់ដែក *[-ន-]* និងពាក្យឫស ចលនាសកម្មរវាងផ្នត់ដែក *[-ន-]* និងសំណុំពាក្យ និងចលនាសកម្មរវាងសំណុំពាក្យទៅនឹងផ្នត់ដែក*[-ន-]*និងពាក្យឫស។

ដូច្នេះ តាមរយៈសេចក្តីពន្យល់និងគំនូសតាងខាងលើ យើងឃើញពីភាពខុសប្លែកគ្នាដាច់ស្រលះរវាង *ការដាក់ឱ្យមានទំនាក់ទំនង* និង *អន្តរកម្មដែលជាចលនាសកម្មទ្វេទិស*។ ភាពខុសប្លែកគ្នានេះស្តែងឡើងក្នុងកម្រិតនៃការចងសម្ព័ន្ធរវាងធាតុនិងធាតុក្នុងយន្តការនៃការស្ថាបនាន័យ។

## ២- ការវិភាគពីយន្តការនៃការស្ថាបនាន័យរបស់ធាតុ *កម្ម*

ក្រោយពីបានរំលឹកពីទិដ្ឋភាពទូទៅនៃទ្រឹស្តីអន្តរកម្មនិយមដែលបានមកពីការអនុវត្តទៅលើផ្នែកផ្សេងៗនៃភាសានិងអក្សរសាស្ត្រខ្មែររួចមក យើងខ្ញុំនឹងរំលេចតាមរយៈឧទាហរណ៍មួយចំនួនស្តីពីការអនុវត្តផ្ទាល់ទៅលើការសិក្សាវិភាគផ្នែកមួយនៃប្រធានបទនៃនិក្ខេបបទរបស់យើងខ្ញុំស្តីពី«ខ្មែរកម្មក្នុងយន្តការនៃការបង្កើតពាក្យនៅក្នុងភាសាខ្មែរទំនើប»។ នៅក្នុងការបង្កើតពាក្យនិងយន្តការនៃការស្ថាបនាន័យរបស់ធាតុ *កម្ម នីយកម្ម ឧបនីយកម្ម* និង*ភាវូបនីយកម្ម* ស្តែងឡើងតាមរយៈអន្តរកម្មរវាងធាតុទាំងនោះជាមួយនឹងធាតុដែលជាសហបទរបស់វានៅក្នុងបរិបទជាក់លាក់ណាមួយ។ ន័យដែលស្ថាបនាឡើងមិនមែនជារបស់ធាតុ *កម្ម នីយកម្ម ឧបនីយកម្ម* ឬ*ភាវូបនីយកម្ម* តែឯកឯង ឬជារបស់ធាតុដែលជាសហបទរបស់វាទេ ប៉ុន្តែន័យដែលស្តែងចេញបានមកពីអន្តរកម្មរវាងធាតុនីមួយៗជាមួយនឹងធាតុដែលជាសហបទរបស់វា ពោលគឺចលនាសកម្មទ្វេទិស៖ ចលនាសកម្មរវាងធាតុ *កម្ម នីយកម្ម ឧបនីយកម្ម* ឬ*ភាវូបនីយកម្ម* ជាមួយនឹងធាតុដែលជាសហបទរបស់វា ចលនាសកម្មរវាងធាតុ *កម្ម នីយកម្ម ឧបនីយកម្ម* ឬ *ភាវូបនីយកម្ម* ជាមួយនឹងសំណុំពាក្យទាំងមូល ចលនាសកម្មរវាងសំណុំពាក្យទៅនឹងធាតុ *កម្ម នីយកម្ម ឧបនីយកម្ម* ឬ*ភាវូបនីយកម្ម* ហើយបរិបទជានិយ័តករដែលធ្វើឱ្យន័យមាន លំនឹង។

យន្តការនៃការស្ថាបនាន័យតាមរយៈអន្តរកម្មរវាង *X* និង *កម្ម* ស្តែងឡើងតាមឧទាហរណ៍មួយចំនួនដូចខាងក្រោម៖

ករណី X = ពល នាំឱ្យអន្តរកម្មរវាងសហបទ *ពល* និងឯកតាភាសា *កម្ម* បង្កើតបានសំណុំពាក្យ *ពលកម្ម* ដែលមានន័យថា ការប្រអំពើធ្វើដោយកម្លាំង។ ក្នុងក្របខណ្ឌនេះ សហបទ *ពល* ជារូបសព្ទដែលមានស្វ័យភាពនិងឯករាជ្យភាពផ្នែកសម្ព័ន្ធ មានន័យថា កម្លាំង។ ចំណែកឯកតាភាសា *កម្ម* ជាបច្ឆិមបទដែលគ្មានស្វ័យភាពនិងឯករាជ្យភាពផ្នែកសម្ព័ន្ធ មានន័យថា អំពើឬទង្វើ។ នៅក្នុងសំណុំពាក្យ *ពលកម្ម* ជាតុ *ពល* ជាទម្រន់ន័យគ្រឹះ រីឯ ជាតុ *កម្ម* មិនមែនជាទម្រន់ន័យគ្រឹះទេ។ ដូច្នេះ សំណុំពាក្យ *ពលកម្ម* បានផ្តល់តួនាទីឱ្យ *ពល* ជាជាតុស្នូល *កម្ម* ជាជាតុបន្សំ។ *ពលកម្ម* បង្កើតឡើងតាមវិធី បន្សំស្ថិតក្នុងទម្រង់ស.ប (ស្នូល-បន្សំ)។

ករណី X = ស្បែក នាំឱ្យអន្តរកម្មរវាងសហបទ *ស្បែក* និងឯកតាភាសា *កម្ម* បង្កើតបានសំណុំពាក្យ *ស្បែកកម្ម* ដែលមានន័យថា មនុស្សដែលរងកម្ម។ នៅក្នុងក្របខណ្ឌនេះ សហបទ *ស្បែក* ជាវចនសព្ទដែលមានស្វ័យភាពនិងឯករាជ្យភាពផ្នែកសម្ព័ន្ធ។ *ស្បែក* មានន័យថា អាការៈមួយប្រភេទរុំព័ទ្ធពីខាងក្រៅសាច់សរីរកាយមនុស្សឬសត្វពួកខ្លះ។ ចំណែកឯកតាភាសា *កម្ម* ជាវចនសព្ទដែលមានស្វ័យភាពនិងឯករាជ្យភាពផ្នែកសម្ព័ន្ធដែរ។ *កម្ម* ជាវចនសព្ទដែលមានន័យថា អំពើអាក្រក់ដែលជាបាបតាមផ្តន្ទាគ្រប់ពេលវេលាលើបុគ្គលណាម្នាក់។ នៅក្នុងសំណុំពាក្យ *ស្បែកកម្ម* ជាតុ *ស្បែក* មិនមែនជាទម្រន់ន័យគ្រឹះទេ ហើយ ជាតុ *កម្ម* ក៏មិនមែនជាទម្រន់ន័យគ្រឹះដែរ។ ក្នុងករណីនេះ ស្បែកកម្ម បានផ្តល់ តួនាទីឱ្យ *ស្បែក* មិនមែនជាជាតុស្នូល ហើយ *កម្ម* ក៏មិនមែនជាជាតុស្នូលដែរ។ ដូច្នេះ ស្បែកកម្ម បង្កើតឡើងតាមវិធីបន្សំស្ថិតក្នុងទម្រង់បង្គុំ។

## ៣- សេចក្តីសន្និដ្ឋាន

តាមរយៈទ្រឹស្តីអន្តរកម្មនិយមដែលយើងយកមកធ្វើជាប្រទីបក្នុងការសិក្សាវិភាគលើប្រធានបទនេះ យើងអាចសន្និដ្ឋានបានថា ន័យដែលស្តែងចេញមកមិនមែនបានមកតែពីជាតុ *កម្ម* តែឯកឯង ឬពី *សហបទ* របស់វាតែឯកឯងនោះទេ។ យន្តការនៃការបង្កើតពាក្យនិងស្ថាបនាន័យ បានមកពីអន្តរកម្មរវាងជាតុ *កម្ម* ជាមួយនឹងជាតុដែលជាសហបទរបស់វា ពោលគឺចលនាសកម្មទ្វេទិសៈ

- ចលនាសកម្មរវាងជាតុ *កម្ម* ជាមួយនឹងជាតុដែលជាសហបទរបស់វា ចលនាសកម្មរវាងសហបទរបស់ជាតុ *កម្ម* ជាមួយនឹងជាតុ *កម្ម*
- ចលនាសកម្មរវាងជាតុ *កម្ម* ជាមួយនឹងសំណុំពាក្យទាំងមូល ចលនាសកម្មរវាងសហបទរបស់ជាតុ *កម្ម* ទៅនឹងសំណុំពាក្យទាំងមូល និង ចលនាសកម្មរវាងសំណុំពាក្យទៅនឹងជាតុ *កម្ម* និងសហបទរបស់ *កម្ម*។ បរិបទជានិយ័តករដែលធ្វើឱ្យន័យមានលំនឹង។

ដូច្នេះ តាមរយៈអន្តរកម្មរវាងឯកតាភាសា *កម្ម* និង សហបទរបស់វា យើងទាញចេញជាសម្មតិកម្មពីរគឺ

- *កម្ម* ជាធាតុមិនឯករាជ្យនិងគ្មានស្វ័យភាពផ្នែកសម្ព័ន្ធ ដែលមានតួនាទីជាបច្ចិមបទ
- *កម្ម* ជាវចនសព្ទ ដែលមានស្វ័យភាពនិងឯករាជ្យភាពផ្នែកសម្ព័ន្ធ។

## គន្ថនិទ្ទេស


- កេង វ៉ាន់សាក់៖ *មូលភាពនៃការបង្កើតពាក្យថ្មី* ភ្នំពេញ ១៩៦៤
- ច័ន្ទ សំណព្វ៖ *បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ* រាជបណ្ឌិត្យសភាកម្ពុជា ២០១០
- ច័ន្ទ សំណព្វ៖ *សំណេរនិងអក្ខរាវិរុទ្ធខ្មែរ* រាជបណ្ឌិត្យសភាកម្ពុជា ២០០៨
- ឡុង សៀម៖ *អំពីភាសាវិទ្យា និង ភាសាខ្មែរ* មហាវិទ្យាល័យបុរាណវិទ្យា ២០០០
- អៀវ កើស៖ *ភាសាខ្មែរ* បណ្ណាគារ មិត្តសេរី ភ្នំពេញ ១៩៦៧
- នៅ ស៊ុន៖ *ភាសាខ្មែរក្នុងចំណោមភាសាអ៊ីសូឡង់និងភាសាមិនមែនអ៊ីសូឡង់* នៅក្នុង Sorn Samnang (Ed.) ខេមរវិទ្យា volume II ១៩៩៩
- ព្រុំ ម៉ល់៖ *អំពីលក្ខណៈវិនិច្ឆ័យរូបនិយម* នៅក្នុងទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា លេខ ០៣ ឧសភា ២០០២
- ព្រុំ ម៉ល់៖ *លទ្ធភាពបង្កើតពាក្យនិងការបង្កើតពាក្យក្នុងភាសាខ្មែរ* នៅក្នុងទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា លេខ ០២ មិថុនា ២០០១
- ជួន ណាត៖ *វចនានុក្រមខ្មែរ (ភាគ១-២)* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧

៥០- តិប យក់ និង ថាវ គន្ធ៖ *វចនានុក្រម បារាំង-ខ្មែរ (ភាគ១-២)* បណ្ណាគារ ប៊ុត នាង ភ្នំពេញ ១៩៦២

- វិទ្យាស្ថានភាសាជាតិ៖ *វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ* ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ភ្នំពេញ ២០០៥
- ហ៊ាន សុខុម៖ *សទ្ទានុក្រមបច្ចេកស័ព្ទទំនើប* សម្ព័ន្ធនិស្សិតខ្មែរពីបរទេស «លីដេខ្មែរ» ភ្នំពេញ ១៩៩៨
- Benveniste Émile, ***Problèmes de linguistique générale***, Gallimard 1966;
- Chan Samnoble, "Contribution à l'étude de mɔ:k en khmer", dans : ***FAITS DE LANGUES,*** Les Cahiers numéro 1, OPHRYS, 2009;
- Chan Samnoble : ***Identifié et variations des unités de langue : étude d'une série d'unités lexico-grammaticales en khmer contemporain***, thèse de doctorat de sciences du language, Université de Paris X-Nanterre, 2002;
- Chan Samnoble : ***Systématique des emplois de təi en khmer contemporain***, mémoire de DEA, Université de Paris X-Nanterre, 1998;
- Ferdinand de Saussure, ***Cours de linguistique générale,*** Payot, (réédition) 1972;
- Huffman Franklin, ***Modern spoken Cambodia***, New Haven & London, Yale University Press, 1970;
- Khin Sok, ***La grammaire du khmer moderne***, You Feng, Paris, 1999;

- Lyons John, ***Linguistique générale***, Librairie Larousse, 1970;
- Martinet André, ***La linguistique synchronique***, Presses Universitaires de France, 1968;
- Maspéro Georges, ***Grammaire de la langue khmère***, École française d'Extrême-Orient, Imprimerie Nationale (Paris), 1915;
- Y.A. GORGONIYEV, ***The Khmer Language,*** Nauka, Moscow, 1966;

## Ethnic Minority Groups in Ancient Cambodia[72]

*KEO Linet*
National Language Institute, Royal Academy of Cambodia.

## 1. Introduction

This paper, as preliminary highlight, will cover a few ethnic names mentioned in Cambodian inscriptions.

## 2. Khmer People among Austroasiatic Population

There are around 160 languages in Austroasiatic (AA) family.[73] Genetically most of Austroasiatic people carry hemoglobin E (Hb E). The prevalence of hemoglobin E is "1/2 in some regions near the intersection borders of Cambodia, Thailand, and Laos. It is also prevalent in parts of the Indian subcontinent. In contrast, hemoglobin E is much less common in Vietnamese population and is almost absent among the Chinese and Japanese populations."[74] Historically the first confirmation of Hb of Khmer among other ethnic groups might be in 1940s.[75] The researchers proposed Khmer people as one of 'proto-asiatique' population. So, a population with hemoglobin E such as Khmer is malaria-drug resistant because they have inhibited in tropical Southeast Asia for thousands of years. In 2013, 62 scientists from 24 countries have related western Cambodia as a hotspot of malaria-drug resistant population[76].

---

[72] This topic is an ongoing research. Some parts of the points therein were presented at International Conference on Austoasiatic Linguistics (ICAAL) 6, 29-31 July 2015 in Siem Reap.

[73] Prof Gérard Diffloth asserts that AA phylum consist of 164 languages, cf. Gérard Diffloth, *Kuay in Cambodia: a vocabulary with historical comments,* ([Phnom Penh]: Tuk Tuk Editions, [2012]), p. 8. Note well that there is no exact number of languages within the phylum, for all AA linguists, to be agreed upon and up until now classification of families in AA phyla remains a struggling effort.

Now Munda and Mon-Khmer are proposed to be on equal branch of AA families. Munda languages have different typology from other families of AA phyla. Also there is weak supported argument for Vieto-Katuic hypothesis.

There seems a losing trust in Morris Swadesh's glottochronology and lexicostatistics in language classification and some researchers resort to other interdisciplinary approach or methodology such as computational phylogenetics. Cf. Paul Sidwell, "Austroasiatic Classification" in *The Handbook of Austroasiatic Languages,* Mathias Jenny and Paul Sidwell, ed., Vol. 1, (Leiden: Brill, 2015), p. 144-211.

[74] "Hemogloin E/Beta-Thassemin", *http://staff.washington.edu/sbtrini/Teaching%20Cases/Case%2036.pdf;* Bene-dict. P. Carnley et al. "The Prevalence and Molecular Basis of Hemoglobinopathies in Cambodia", *Hemoglobin,* 30 (4):463-470; Urade BP, "Haemoglobinopathies – HbE and HbS among the Gallong Tribe of West Siang District of Arundachal Pradesh, India", *Medical Science,* Volume 7, Number 26, April 23, 2014. See also Urade BP, "Haemoglobinopathies – HbE and HbS among the Gallong Tribe of West Siang District of Arundachal Pradesh, India", *Medical Science,* Volume 7, Number 26, April 23, 2014; Sanita Singsanan, Goonapa Fucharoen, Onekham Savongsy, Kanokwan Sanchaisuriya, and Supan Fucharoen, "Molecular character-ization and origins of Hb Constant Spring and Hb Paksé in Southeast Asian populations", *Ann Hematol* (2007) 86:665-669.

[75] E. Farinaud, "Contribution à l'étude des populations de l'Indochine méridionale française, d'après la répartition des groupes sanguins", *Bulletins et Mémoires de la Société d'anthropologie de Paris,* IX° Série. Tome 2, 1941. pp. 75-102.; Georges Olivier, Contribution à l'anthropologie des Vietnamiens méridionaux. *Bulletins et Mémoires de la Société d'anthropologie de Paris,* XII° Série, tome 1 fascicule 2, 1967. pp. 155-176. Sok Hean Sun might be the first during the 1950s who called other scientists into attention concerning Hemoglobin E of Mon-Khmer population; cf. SOK Heansun, *L'HEMOGLOBINE E AU CAMBODGE,* (Paris : École Française d'Extrême-Orient, 1958).

[76] Olivo Miotto et al. "Multiple populations artemisinin-resistant *Plasmodium falciparum* in Cambodia", *Nat Genet.* 2013 June ; 45(6): . doi:10.1038/ng.2624.

Some researchers claim that *Oriza sativa* (rice) was first domesticated thousands of years ago in south Asia and East Asia. Tropical Southeast Asia is ascertained to be homeland of Austroasiatic people, who were farmers.[77] Other archeological findings are undergoing in Southeast Asian countries[78] and some researchers have suggested countries of Southeast Asia had had their indigenous civilisations; so, there are questions to be answered and answers to be verified. [79]

## 2. General Information

Since the second 3rd century A.D. diplomatic relations between Cambodia, China, and India had been historically recorded by Chinese. K'ang T'ai, a Chinese traveler, mentioned his encounter with an Indian ambassador named "Tch'en-song" at Funan court. The 6th century History of Leang (502-556) informs us that Funan built grand ships.[80]

During the ninth century A.D., Cambodia had its border touched "along the edge of southern Yunnan". Some historians suggest Cambodia's Alavirarashtra with Sib-song Panna and Khmerrashtra with the Kun region of Keng Tung while its border in the south reached the sea, as confirmed by the twelfth or thirteen century accounts of Chou Ta-kuan and Chau Ju-kua, Cambodia.[81]

There are families in present Sib-song Panna who confirmed their ancestors were sent from Cambodia to look after elephants of Chinese King in Sib-song Panna[82].

Scholars accept that there was a series of waves of migrations of Indians to Southeast Asia. Among other theories, the migrations were mainly supported by commercial and religious causes.[83] Based on Buddhist records such as *Dipavamsa* (350 A.D.), *Mahavamsa* (475 A.D.) and other records, especially Chinese and Arabic, have confirmed "the Kalingans traded in South East Asia with commercial, cultural and religious expansions most possibly with mass migration and administrative links with motherland."[84]

---

77 Nicole Revel, *Le riz en Asie du su-est : Atlas du vocabulaire de la plante,* (Paris : Imprimerie de l'indépendent, 1988); Ly Vanna, “Rice Remains in the Prehistoric Pottery Tempers of the Shell Midden Site of Samrong Sen: Implications for Early Rice Cultivation in Central Cambodian”, *Aséanie* 9, 2002, pp. 13-34; Laurent Sagart, How many independent rice vocabularies in Asia? Paper read at *Rice and Language Symposium*, Cornell University, 22-25 September, 2011. (32 pages); Roger Blench, "Reconstructing Austroasiatic prehistory", In: M. Jenny & P. Sidwell, ed. forthcoming 2015. *Handbook of the Austroasiatic Languages.* Leiden: Brill. (Roger Blench’s article does not appear in the *Handbook of the Austroasiatic Languages,* 2005.)

78 Don Bayard, "The Roots of Indochinese Civilisation: Recent Developments in the Prehistory of Southeast Asia", *Pacific Affairs,* Vol. 53, No. 1 (Spring, 1980), pp. 89-114.

79 David Bulbeck, "A Historical Perspective on the Australian Contribution to the Practice of Archaeology in Southeast Asia", *Australian Archaeology,* No. 50, Special 50th Edition. Archaeology in the New Millennium: The Past, Present and the Future of Australian Archaeology (Jun. 2000), pp. 45-53; L. A. Schepartz, S. Miller-Antonio and D. A. Bakken, "Upland Resources and the Early Palaeolithic Occupation of Southern China, Vietnam, Laos, Thailand and Burma", *World Archaeology,* Vol. 32, No. 1. Achaeology in Southeast Asia (Jun., 2000), pp. 1-13.

80 Paul Pelliot, Le Fou-nan, *BEFEO,* Tome 3, 1903, pp. 248-303.

81 Cf. Lawrence Palmer Briggs, "The Appearance and Historical Usage of the Terms Tai, Thai, Siamese and Lao", *Journal of the American Oriental Society,* Vol. 69, No. 2 (Apr. - Jun., 1949), p. 69; http:// ethno.ihp.sinica. edu.tw/ en/southwest/main_DA-07.html, accessed 08-07-15.

82 The information confirmed during a research carried by researchers of the Royal Academy of Cambodia (RAC) in 2010 headed by Dr Sum Chhum Bun.

83 Benudhar Patra, Kalinga In South East Asia, in *Orissa Review,* November-2004, pp.9-16.

84 Bijoyini Mohanty and Indramani Jena, Kalinga, Kalinga and Klinga, in *Odisha Review,* December-2014, pp.36-42.

It is said in *Samanta Pasadika* that Asoka had sent his son and his daughter along with 8 families of Kalinga to Srilanka. And there is tradition in Java of Indonesia that Kalinga king sent 20 thousand families to this island. Out of religions, especially Brahmanism and Buddhism, from India, linguistic names such as *Talaing, Telinga, Kling, Keling* and *Kalinga* are still used by people in Burma, Indonesia and Malaysia; also Kalinga province of the Philippines, a Kalinga port in Indonesia.[85]

Archaeological finds from ancient Funan emporium confirm foreign contacts in Cambodia[86].

The following data from inscriptions and researches are not an exhausted one. Inscriptions data are supplied and supported by other researches concerning the history and present status of each ethnic group.

## 2.1. Inscriptions Information

Khmer people aside, there are evidences through Cambodian inscriptions that there were many people of different ethnic groups had lived in or come to Cambodia. They had their presence since pre-Angkorian time. Some of them might involve themselves in administrative, religious, or commercial activities.

### 2.1.1. *cina* and *cāmp*

K. 61, of Bantay Prav temple, Banteay Mean Chey Province. The inscription mentions donations of workers from *kaṃsteṅ çrī narapatīndravarmma* to the God *vraḥ kaṃrateṅ añ parameçvara*. Among the worker donated to the god there is female worker: *tai cina;* and we propose this as a Chinese. Inscription K. 263, 10th century, of Vat Prah Einkosei, Face D, Siam Reap Province, tells us about donations of King Jayavarman V in workers to the god Dvijendrapura. The workers offered to the king by a dignitary *vraḥ kaṃrateṅ añ divākarabhaṭṭa.* Among the workers there is a worker named *gvāl cāmpa.* We consider this name as a Cham. Further down the line there is description of goods destined for the god. Among that is a utensil: *ṅon cina.* This utensil (*ṅon*) was from China (*cina).*

### 2.1.2. *kliṅ*

Some Indians might had lived for a long period or permanently until they die and had their bodies buried in Cambodia. A good example is from K. 684, of Inscription of Phnom Bakheng, in Angkorian period. The inscription, which Cœdès dated not before 10th century, mentioned a prescription concerning the right bestowed on a caste of *vraḥ cāmara* (caste of fan bearer) to enjoy usufruct of *bhūmi vnur khliṅ* (*Kling burial ground/cemetery Village).*

### 2.1.3. *lahvā, kantāṅ, kliṅ, grec, pekan*

In K. 24 of 'Inscription d'Angkor Borei', Takeo Province, which G. Cœdès dated the inscription between VI-VII centuries; we would see names of many ethnic groups such as *lahvā, kantāṅ, kliṅ, grec, pekan.* The four early names are male workers, with prefix *va,* while the last is female one, *ku*. Although the condition of the inscription, almost all written

---

[85] Benudhar Patra, "Kalinga In South East Asia", *Orissa Review,* November, 2004; Benudhar Patra, "Role of Kalinga in the Process of Ancient Indian Colonization in South-East Asia", *Orissa Review,* November, 2010; Parewar Sahoo, "Kalinga's Relation with Indonesia (Circa, 1st Century B.C. to 7th Century A.D.)", *Orissa Review,* November 2007;

[86] Roland Braddell, "Arikamedu and Oc-èo", *Journal of the Malayan Branch of the Royal Asiatic Society,* Vol. 24, No. 3 (156) (October, 1951), pp. 154-157.

the names of men and women, renders us not much information about exact dates, donator, or religious foundation, we might suggest that the donor is a dignitary since at the beginning of the Face A we see *'poñ vrau'* after a ellipsis, due to fragment of the stone, and then a list of names of workers. If we suggest 'aṃnoy' (present) before 'poñ', we have 'aṃnoy vrau' (present of poñ vrau). '*Vrau*' is also an ethnic name. So the donator is a 'vrau' and there were other ethnic minority group beside Khmer workers.

**2.1.4. *rmañ***

K. 76 of Phnom Ho Phnou of Kong Pisei District, Kampong Speu Province gives attestation to the presence of Mon people called *rmañ*, who were temple workers.

**2.1.5. *siṅhalī/siṃhali***

K. 353, Prasat Kantop, Kulen district, Preah Vihear Province, dated between the reign of Jayavarman V and Rajendravarman, notifies us about people involved in demarcation of village, in 1046) in order to dedicate to the temple Çivapāda. We notice two people: *teṅ tvan siṅhalī* and *khloñ siṃhali. ṅ* and *ṃ* are variable of nasal. Of course the first word denotes female person while the second word male person.

**2.1.6. *yvan***

K. 105, of Phum Mien (Mien village), O Reang Ov district, Kandal province mentioned the donation of *khloñ vala, khloñ viṣaya* of *vnaṃ kansiṅ* to the God Bhagavatī (Sarasvati). Among workers donated there was one female named *kaṃvai* bought from a Vietnamese at Kampong Toting: *tai kaṃvai ti duñ nu prāk ta yvan kaṃvaṅ tadiṅ.*

**2.1.7. *vrau* and *maleṅ***

K. 133 of Trapeang Thma, Sambor district, Kratie province, dated by Cœdès to the 8th century, tells us about donation of temple workers by a mahānauvāha (chief pilot of ship) and Mratāñ Rudravindu to a god. Among that we would find *vā kantāṅ* (occurred three places in the inscription), *ku maleṅ,* and *vā vrau*. We propose these two workers as Chinese ethnic Kantang (Cantonese), Maleng, and Brao.

The 7th inscription of K. 78 of Phnom Baset mentions donation of workers, rice fields, and plantations.[87] The inscription also mentions one notable and his son: *[k]loñ maleṅ kon kloñ maleṅ* (Maleng Govenor [and] Maleng Govenor's children).

K. 163 of Prasat Ampil Rolum, Kompong Thom Province, a woman named *maleṅ* was among other workers presented to 3 Gods: Gotama Buddha, Maitreya, and Avalokiteçvara.

**2.1.8. *vrau, maleṅ/mayāṅ,* and *ksok***

Now we look at a pre-Angkorian inscription K. 939, of Tuol Cam in Angkor Borei, Takeo Province. Beside the brief note on the content of this inscription given by Cœdès as 'dons de K. A. Çrī Svāmi Cāturvidya à V. K. A. Çrī Tribhuvanañjaya', we should propose something here as a basis for further study since the inscription was not translated and there are some lacunae due to the condition of the stone.

[87] Fomerly this inscription was removed to Botum Pagoda and in 1990s; a piece of this inscription brought back by Prof Long Seam and his students from a canal behind Stueng Mean Chey Pagoda. It was then installed inside Royal University of Phnom Penh, Campus I. The information concerning the inscription is courtesy of Dr Chuor Keary, Director of National Language Institute of the Royal Academy of Cambodia (p.c. July 2015).

Just taking *'çrīsvāmicāturvvidya pre vrau maleṅ ksok toy gi poṣaṇā aṣṭadiça ta gi sruk bhavapura'*, we suggest the translation as ' *Çrīsvāmicāturvvidya* orders *Vrau, Maleng, and Ksok* to support Bhavapura'. Since Cœdès was not sure about '*ksok'* that could be read as *ksak* or *ksek,* we should count it out for more study. The information rendered from the inscription is corroborated by another phrase at the end of the text of the inscription: *'ge gi ta doṅ coṅ gi neh¡ kanloṅ it ta pon'* or 'people who engage in construction of the brick gopuras'. Note that in modern Khmer language, one would use *'khloṅ dvār'* to denote exterior gates and *'praḥ kanloṅ'* to 'parents'.

So *Vrau* and Maleng people might have been brought to live in Bhavapura and to engage in temple constructions.

K. 163, door jamb of the north tower of Prasat Amil Rolom, Kompong Thom province, dated around 6-7th centuries. We see two names: *vā vrau* and *ᵃme maleṅ,* whom among workers dedicated to Gotama Buddha, Maitriya, and Avalokiteçvara. Here we have ethnic names Brao and Ma Lieng.

A pre-Angkorian inscription, K. 451, of Prasat Prei Thnal (South), of Puok District, Siem Reap Province, dated 608 A. D., mentioned donation from *kuruṅ maleṅ* (Maleng City/Town). The donation was intended to God *Çrī Kedāreçvara*. The donation consisted of 58 workers, 100 plantations and 5 paddy rice fields. Although we do not know exactly how big or important this 'city", we at least could bear in mind that the city/town was an important administrative zone where many Maleng lived. Another pre-Angkorian inscription mentioned donation of *maleṅ* is K. 133 of Trampeang Thma, Sambor District, Kratie Province. G. Cœdès considered the inscription was in eighth century.

Another ethnic group in Angkorian period is *malyāṅ*. Inscription K.536, of Prasat Takeo, Siem Reap Province, with a single phrase graffito mentioned *ācāaryya malyāṅ* (Malyang preacher/teacher). Cœdès gave the date of the inscription to 11th century.

Another 11th century inscription, K. 218 of Prasat Sangkhah, in the northwest of Kralanh District, Siem Reap Province, mentioned a worker named *gho malyāṅ*. This worker is one among many offered by King Suryavarman I to the çivalinga of *çrīvāgīçvara-panditasvāmi* of *jaroy cār.*

We now have *cina* (Chinese)*, kantāṅ* (Cantonese), *kliṅ* (Indian), *grec* (Greece), *lahvā* (Lawa), *pekan* (Paganese), *Maleng/Malieng, yvan* (Vietnamese), *rmañ* (Mon), *Siṇhali/Siṃhalī* (Srilankan), *syam/syām* (Siemese/Thai), and *vrau* (Brao). These ethnic groups might have had short or long contact with Khmer people in ancient time. We need more data concerning *grec* (Greece), *kantāṅ* (Cantonese), and *pekan* (Paganese).

**3. Conclusion**

Data presented here might be a string of argument in understanding various ethnic groups who have been in contact with Khmer people in ancient time or in examining internal and external relations of Mon-Khmer or Austroasiatic peoples.

**BIBLIOGRAPHY**

Benudhar Patra, Kalinga In South East Asia, in *Orissa Review,* November-2004.

Bijoyini Mohanty and Indramani Jena, Kalinga, Kalinga and Klinga, in *Odisha Review,* December-2014.

Blench, Roger. "Reconstructing Austroasiatic prehistory", In: M. Jenny & P. Sidwell (eds.), forthcoming 2015. *Handbook of the Austroasiatic Languages.* Leiden: Brill.

Braddell, Roland. "Arikamedu and Oc-èo", *Journal of the Malayan Branch of the Royal Asiatic Society,* Vol. 24, No. 3 (156) (October, 1951.

Breazeale, Bennon. *The Integration of the Lao States into the Thai Kingdom*. PhD Dissertation, St. Antony's College, 1975.

Briggs, Lawrence Palmer. "The Appearance and Historical Usage of the Terms Tai, Thai, Siemese and Lao," *Journal of the American Oriental Society,* Vol. 69, No. 2 (Apr. - Jun., 1949), pp. 60-73.

Bulbeck, David. "A Historical Perspective on the Australian Contribution to the Practice of Archaeology in Southeast Asia", *Australian Archaeology,* No. 50, Special 50th Edition. Archaeology in the New Millennium: The Past, Present and the Future of Australian Archaeology, Jun. 2000.

Carnley, Benedict. P. et al. "The Prevalence and Molecular Basis of Hemoglobinopathies in Cambodia", *Hemoglobin,* 30 (4):463-470.

Cœdès, G. *Inscriptions du Cambodge*, Vol. I-VIII, 1937-1966.

Diffloth, Gérard. *Kuay in Cambodia: a vocabulary with historical comments.* [Phnom Penh]: Tuk Tuk Editions, [2012].

_______. "Vietnamese as a Mon-Khmer language," in *Papers From The First Annual Meeting of The Southeast Asian Linguistics Society, 1991:* 125-139.

Farinaud, E. "Contribution à l'étude des populations de l'Indochine méridionale française, d'après la répartition des groupes sanguins", *Bulletins et Mémoires de la Société d'anthropologie de Paris,* IX° Série. Tome 2, 1941. pp. 75-102.

Ferlus, Michel. Le maleng brô et le vietnamien, *MKS* 27:55-66.

______. "Langues et peuples viet-muong," *MKS* 26: 7-28;

______. "Sur l'origine géographique des langues Viet-Muong," *MKS* 18-19: 52-59;

Gage, William W. "Vietnamese in Mon-Khmer Perspective," in *Southeast Asian Linguistic Studies presented to Adre-G. Haudricourt*, Bangkok, 1985: 493-524.

"Hemogloin E/Beta-Thassemin", *http://staff.washington.edu/sbtrini/Teaching%20Cases/Case%2036.pdf.*

Keller, Charles E. "Brao-Krung phonology," *MKS* 31: 1-13.

Ly Vanna. Rice Remains in the Prehistoric Pottery Tempers of the Shell Midden Site of Samrong Sen: Implications for Early Rice Cultivation in Central Cambodian. In: *Aséanie* 9, 2002, pp.13-34.

Miotto, Olivo et al. Multiple populations artemisinin-resistant *Plasmodium falciparum* in Cambodia. *Nat Genet.* 2013 June ; 45(6): . doi:10.1038/ng.2624.

Olivier, Georges. Contribution à l'anthropologie des Vietnamiens méridionaux. *Bulletins et Mémoires de la Société d'anthropologie de Paris,* XII° Série, tome 1 fascicule 2, 1967.

Pain, Frédéric. "An Introduction to Thai Ethnonymy: Examples from Shan and Northern Thai", in *Journal of the American Oriental Society,* Vol. 128, No. 4 (Oct. - Dec., 2008), pp. 641 - 662.

Parkin, Robert. A Guide to Austroasiatic Speakers and Their Languages, *Oceanic Linguistics Special Publications,* No. 23, A Guide to Austroasiatic Speakers and Their Languages, 1991.

Pelliot, Paul. Le Fou-nan. *BEFEO,* Tome 3, 1903.

Pe Maung Tin and G. H. Luce. *The Glass Palace Chronicle of the Kings of Burma*. Rangoon: Rangoon University Press, 1960.

Revel, Nicole. *Le riz en Asie du su-est : Atlas du vocabulaire de la* plante. Paris : Imprimerie de l'indépendent, 1988.

Sagart, Laurent. How many independent rice vocabularies in Asia? Paper read at *Rice and Language Symposium*, Cornell University, 22-25 September, 2011.

Sahoo, Parewar. "Kalinga's Relation with Indonesia (Circa, 1st Century B.C. to 7th Century A.D.)", *Orissa Review,* November 2007.

Sanita Singsanan, Goonapa Fucharoen, Onekham Savongsy, Kanokwan Sanchaisuriya, and Supan Fucharoen, "Molecular character-ization and origins of Hb Constant Spring and Hb Paksé in Southeast Asian populations", *Ann Hematol*, 2007.

Schepartz, L. A., S. Miller-Antonio and D. A. Bakken, "Upland Resources and the Early Palaeolithic Occupation of Southern China, Vietnam, Laos, Thailand and Burma", *World Archaeology*, Vol. 32, No. 1. Achaeology in Southeast Asia, Jun., 2000.

Schliesinger, Joachim. *Ethnic Groups of Cambodia,* Vol.3, Bangkok: White Lotus Press, 2011.

Taw Sein Ko. *The Kalyani Inscriptions Erected at Pegu by King Dhammaceti in 1476.* Rangoon: The Superintendent, Government Printing, 1892.

Thomas, David. "A Note on the Branches of Mon-Khmer," *MKS* 6: 139-141.

Urade BP. "Haemoglobinopathies – HbE and HbS among the Gallong Tribe of West Siang District of Arundachal Pradesh, India", *Medical Science,* Volume 7, Number 26, April 23, 2014.

www.vietnam-culture.com/brau-brao-ethnic-group.aspx (accessed February 2015).

http://ethno.ihp.sinica. edu.tw/ en/southwest/main_DA-07.html (accessed July 15).

# **មុខងារកិរិយាវិសេសន៍នៅក្នុងភាសាខ្មែរ**

គុយ រិន

មន្ត្រីវិទ្យាស្ថានភាសាជាតិ

មុននឹងវិភាគពីមុខងារកិរិយាវិសេសន៍ក្នុងភាសាខ្មែរ យើងបង្ហាញពីនិយមន័យកិរិយាវិសេសន៍តាមរយៈគំនិតរបស់អ្នកនិពន្ធផ្សេងៗដូចជា ៖

- លោក Maurice Grevisse បានឱ្យនិយមន័យកិរិយាវិសេសន៍ថា «*កិរិយាវិសេន៍ជាពាក្យមិនប្រែប្រួល ដែលគេប្រើភ្ជាប់ជាមួយកិរិយាស័ព្ទ ជាមួយគុណនាម ឬ ជាមួយកិរិយាវិសេសន៍ដូចគ្នា ដើម្បីឱ្យពាក្យទាំងនោះវិសេសន៍ឡើង* »[៨៨]។

- លោក Robert et Nathan បានឱ្យនិយមន័យកិរិយាវិសេសន៍ថា «*កិរិយាវិសេសន៍ជាពាក្យ (ឬពាក្យសមាស) មិនប្រែប្រួលដែលមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឱ្យកិរិយាវិសេសន៍ដូចគ្នា និង ឱ្យឃ្លាទាំងមូល* »[៨៩]។

- លោក John Lyons បានឱ្យនិយមន័យកិរិយាវិសេសន៍ថា «*កិរិយាវិសេសន៍ គឺជាប្រភេទពាក្យដែលសម្រាប់បំពេញន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឬ ឱ្យកិរិយាវិសេសន៍ដូចគ្នា ឬក៏ ឱ្យកន្សោមកិរិយាវិសេសន៍* »[៩០]។

- លោក Greviss Goosse បានឱ្យនិយមន័យកិរិយាវិសេសន៍ថា «*កិរិយាវិសេសន៍ជាពាក្យមិនប្រែប្រួលដែលបំពេញន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឬ ឱ្យកិរិយាវិសេសន៍ដូចគ្នា* »[៩១]។

លោក Cyril Miller, Ann Thompson, Garol Ann Bergman and J.A. senn, P.c. Wren and H. Martin, Jonh E and Warriner,... បានឱ្យនិយមន័យកិរិយាវិសេសន៍ថា «*កិរិយាវិសេសន៍គឺជាពាក្យដែលអាចបញ្ជាក់ន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឬ ឱ្យកិរិយាវិសេសន៍ដូចគ្នា* »[៩២]។

---

៨៨ Maurice Grevisse, *Précis de grammaaire française,* Paris, Duculot, P.122, "L'adverbe est un mot invariable pue I'on jin à un verbe, à un adjective ou à un autre adverbe",

89 -Robert et Nathan, *Grammaire française ,* Paris, Nathan, P.55, "L'adverbe est un mot (ou locution) qui à pour role de modifier ou de presser le sene :
- d'un verbve.
- d'un adjectif.
- d'un autre adverbe.";

90 -John Lyons, *Linguistigue g*énérale, Laroussse, 1986, P.249, "L'adverbe est unc partic du discours qui sert à modifier un verbe, un adjectif, un autre adverbe ou syntagme adverbial";

91 -Greviss Goosse, *Nouvelle grammaire française,* Duculot, 1995, P.313, "L'adverbe est un mot invariable apte à sservir de complement à un verbe, à un adjectif ou à un autre advrbe";

៩២ Cyril Miller, ***A grammar of modern English for foreign students,*** Langman, 1962,P.197, Ann Thompson, ***The language Tree An English Heandbook for senior*** student **,** 1967,P.80, Ann Garol Bergman and J.A.Senn, ***Heath grammar and composition,*** D.C Heath and company, 1987,P.70 and P.C Wren and H.Martin, ***Hight school English grammar and composition,*** Third Edition, 1980,P.160,"An adverb is a word that modify a verb, an adjective or another adverb";

លោក អ៊ុយ ជួន. ប៊ូ ប៊ូ. ឌ គាម និង ជូ ថានី ពួកគាត់បានឱ្យនិយមន័យកិរិយាវិសេសន៍ថា « *កិរិយាវិសេសន៍ជាស័ព្ទដែលនាំកិរិយាឱ្យមានសេចក្ដីប្លែកជាងប្រក្រតីដើម*»[៥៣]។ ដូចជាពាក្យ : យឺត លឿន ឆាប់ កកេបកកាប...។

លោក ពូវ អ៊ុម បានឱ្យនិយមន័យកិរិយាវិសេសន៍ថា«កិរិយាវិសេសន៍ជាស័ព្ទបន្ថែមលើកិរិយាស័ព្ទ ដើម្បីឱ្យកិរិយាស័ព្ទវិសេសឡើង ឬ ប្លែកឡើងថែមទៀត កិរិយាវិសេសន៍ក៏បន្ថែមស័ព្ទឱ្យគុណនាម ឱ្យមានសេចក្ដីប្លែកឡើងផងដែរ។ ដូចជាពាក្យ : លឿន យឺត ណាស់ ភ្លាម បិតបេរ ឆាប់ តាន់តាប់ ណេះណោះ នៃលនល...» ។

ក្រសួងអប់រំ វេយ្យាករណ៍ថ្នាក់ទី៦ បានឱ្យនិយមន័យថា «*កិរិយាវិសេសន៍ ឬ គុណកិរិយា គឺ ជាពាក្យសម្រាប់សំដែងលក្ខណៈឱ្យកិរិយាស័ព្ទ គុណនាម ឬ កិរិយាវិសេសន៍* »[៥៤]។

យើងយល់ថា ការបញ្ជាក់ន័យមិនមែនជាមុខងារផ្ដាច់មុខរបស់កិរិយាវិសេសន៍ទេ ពីព្រោះពាក្យណាក៏ ដោយសុទ្ធតែបញ្ជាក់ន័យឱ្យពាក្យបង្គោល (complété)[៥៥] កាលណាគេប្រើជាពាក្យណេប (complétif) ឧ. របស់នេះល្អ*ជាងរបស់ខ្ញុំ* មានន័យច្បាស់លាស់ជាង «របស់នេះល្អ» / «ខ្ញុំទិញ*សៀវភៅ*» មានន័យច្បាស់ជាង « ខ្ញុំទិញ»។-ល-។ ម្យ៉ាងទៀត កិរិយាវិសេសន៍ជាពាក្យមួយប្រភេទគឺមិនមែនកន្សោមសេរីទេ។ ហេតុនេះ យើងសូមផ្ដល់និយមន័យឱ្យកិរិយាវិសេសន៍ ដោយបន្ថែមបន្ថយសេចក្ដីដូចតទៅ «កិរិយាវិសេសន៍ជាពាក្យ *(ពាក្យទោល ពាក្យកម្លាយ ពាក្យសមាស...) សម្រាប់ប្រើជាណេបឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឱ្យកិរិយាវិសេសន៍ដូចគ្នា ឬ ប្រើជាកម្មវង ឱ្យល្បះទាំងមូលក្នុងករណីខ្លះ*»។

ក្នុងការកំណត់និយមន័យកិរិយាវិសេសន៍ក្នុងភាសាបារាំង លោក Maurice Grevisse បានផ្អែកទៅលើទិដ្ឋភាពសម្ព័ន្ធមិនជាក់លាក់ ដោយគាត់ឱ្យនិយមន័យកិរិយាយវិសេសន៍ថា «*កិរិយាវិសេសន៍គឺជាពាក្យមិនប្រែប្រួល ដែលប្រើភ្ជាប់ជាមួយកិរិយាស័ព្ទ គុណនាម និង កិរិយាស័ព្ទវិសេសន៍ដូចគ្នា* » ដោយឥតបញ្ជាក់ថាត្រូវភ្ជាប់បែបណាទេ ហើយគាត់ក៏បានផ្អែកទៅលើផងដែរដោយគាត់បានឱ្យនិយមន័យកិរិយាវិសេសន៍ថា«*កិរិយាវិសេសន៍គឺជាពាក្យដែលបញ្ជាក់ន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម និង ឱ្យកិរិយា-វិសេសន៍ដូចគ្នា*»។

-លោក Jean Dubois បានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរូបនិយម ដោយគាត់បញ្ជាក់ថា «*កិរិយាវិសេសន៍ គឺជាពាក្យមិនប្រែប្រួល (mot Invarible) ដែលបំពេញមុខងារផ្សេងៗក្នុងសម្ព័ន្ធដែលមានលក្ខណៈជាកន្សោមនិបាត ជាប្រយោគ ជាសន្ទានឈ្នាប់*» ។

---

[៥៣] -អ៊ុយ ជួន ***វេយ្យាករណ៍ខ្មែរពិសេស*** ភ្នំពេញ បណ្ណាគារ គីម គី ឆ្នាំ១៩៥៥ ទំព័រ១២៥, ប៊ូ ប៊ូ ***វេយ្យាករណ៍ខ្មែរ*** ភ្នំពេញ ខេមរបណ្ណាគារ ឆ្នាំ១៩៥៥ ទំព័រ៦២-៦៣, ឌ គាម ***វេយ្យាករណ៍ខ្មែរជោយរូបភាព*** ភ្នំពេញ បណ្ណាគារសេង ងួនហួត ឆ្នាំ១៩៥៧ ទំព័រ១០៨-១១២ និង ជូ ថានី ក្បួនសម្ព័ន្ធសង្ខេប ភ្នំពេញ បណ្ណាគារ សេង ងួនហួត ឆ្នាំ១៩៦៧ ទំព័រ៣៨-៤០។

[៥៤] -ក្រសួងអប់រំ ***វេយ្យាករណ៍ថ្នាក់ទី៦*** ភ្នំពេញ រោងពុម្ពរណសិរ្ស ឆ្នាំ១៩៨៣ ទំព័រ៣៨។

[៥៥] -សញ្ញា "*complété-complétif*" សញ្ញាណខ្ចីពីភាសាវិទ្យានៃប្រទេសលិចដែលលោកសាស្ត្រាចារ្យ បណ្ឌិត ព្រុំ ម៉ល់ បានប្រែថា "*វងវិសេសន៍-គុណវិសេសន៍*" តែក្រោយមកគាត់បានសុំប្ដូរទៅជា" *បង្គោល-ណេប* " វិញ។

-លោក Robert et Natha ពួកគាត់បានឱ្យនិយមន័យកិរិយាវិសេសន៍ដោយផ្អែកទៅលើន័យសុទ្ធសាធ ដោយគាត់បញ្ជាក់ថា «*កិរិយាវិសេសន៍គឺជាពាក្យ ឬ ពាក្យសមាស មិនប្រែប្រួលដែលមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឱ្យកិរិយាវិសេសន៍ដូចគ្នា និង ឱ្យឃ្លាទាំងមូល*»។

-លោក John Lyons បានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកលើន័យសុទ្ធសាធ ដោយគាត់បញ្ជាក់ថា «*កិរិយាវិសេសន៍ គឺជាប្រភេទពាក្យដែលប្រើសម្រាប់បំពេញន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឱ្យកិរិយាវិសេសន៍ដូចគ្នា ឬ ឱ្យកន្សោមកិរិយាវិសេសន៍*»។

-លោក Grevisse Goosse បានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកទៅលើន័យសុទ្ធសាធ ដោយគាត់បានបញ្ជាក់ថា «*កិរិយាវិសេសន៍គឺជាពាក្យមិនប្រែប្រួល ដែលបំពេញន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឬ ឱ្យកិរិយាវិសេសន៍ដូចគ្នា*»។

-លោកស្រី Michéle Boulare et លោក Jean Louis Frérot បានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកលើន័យសុទ្ធសាធ ដោយគាត់បញ្ជាក់ថា «*កិរិយាវិសេសន៍ គឺជាពាក្យ មិនប្រែប្រួល ដែលបញ្ជាក់ន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឱ្យកិរិយាវិសេសន៍ដូចគ្នា និង ឱ្យឃ្លាទាំងមូល*»។

-លោក René Lahame, Jean Dubois,..., ពួកគាត់បានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យរូបនិយម ដោយគាត់បានបញ្ជាក់ថា «*កិរិយាវិសេសន៍ជាពាក្យមិនប្រែប្រួល (mots invariables) ដែលបំពេញមុខងារផ្សេងៗឱ្យកន្សោមនិបាត ឱ្យឃ្លា ឬ ឱ្យសន្ទានឈ្នាប់ទាំងមូល*»។

-លោក Cyril Miller, Ann Thompson, Garol Ann Berganam andJ.A Senn, P.C Wren and H.Martin, John E and Warriner..., ពួកគេបានឱ្យនិយមន័យកិរិយាវិសេសន៍ដោយផ្អែកលើន័យសុទ្ធសាធ ដោយបញ្ជាក់ថា «*កិរិយាវិសេសន៍ គឺជាពាក្យសម្រាប់បញ្ជាក់ន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម និងឱ្យកិរិយាវិសេសន៍ដូចគ្នា”*»។

-លោក L.G. Alexander បានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកទៅលើន័យសុទ្ធសាធ ដោយគាត់បានបញ្ជាក់ថា «*កិរិយាវិសេសន៍ គឺជាពាក្យដែលបញ្ជាក់ន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឱ្យកិរិយាវិសេសន៍ដូចគ្នា ឱ្យនាមស័ព្ទ ឱ្យឃ្លានិបាត និង ឱ្យឃ្លាទាំងមូល*» ។

-វចនានុក្រម Longman Dictionary of comtemporary English បានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកទៅលើន័យសុទ្ធសាធ ដោយបញ្ជាក់ថា «*កិរិយាវិសេសន៍ គឺជាពាក្យ ឬ កន្សោមពាក្យ ឬ ក្រុមពាក្យ ដែលពិពណ៌នា ឬ បន្ថែមន័យឱ្យកិរិយាស័ព្ទ ឱ្យគុណនាម ឱ្យកិរិយាវិសេសន៍ដូចគ្នា ឱ្យនាមស័ព្ទ ឱ្យឃ្លានិបាត ឬ បញ្ជាក់ន័យឱ្យឃ្លាទាំងមូល*»។

-លោក អ៊ុក វិបុល និង ក្រសួងអប់រំ វេយ្យាករណ៍ថ្នាក់ទី៦ បានកំណត់និយមន័យកិរិយាវិសេសន៍ក្នុងភាសាខ្មែរដោយផ្អែកលើន័យ ដោយបញ្ជាក់ថា «*កិរិយាវិសេសន៍គឺជាស័ព្ទបន្ថែមលើកិរិយាស័ព្ទ លើគុណនាម ឬ កិរិយាវិសេសន៍ដូចគ្នាឱ្យមានន័យប្លែកឡើង ឬ វិសេសថែមទៀត*»។

-លោក ឃិន សុខ បានកំណត់និយមន័យកកិរិយាវិសេសន៍ខ្មែរដោយផ្អែកទៅលើន័យដែរ ដោយលោកបានបញ្ជាក់ថា *«កិរិយាវិសេសន៍គឺជាពាក្យ ឬ កន្សោមពាក្យ ដែលប្រើសម្រាប់បញ្ជាក់ឱ្យកិរិយាស័ព្ទ ឱ្យគុណនាម និង ឱ្យកិរិយាវិសេសន៍ដូចគ្នា។ (...) កិរិយាវិសេសន៍ក៏អាចបញ្ជាក់ន័យឱ្យឃ្លាទាំងមូលផងដែរ»*។

ការកំណត់និយមន័យកិរិយាវិសេសន៍ទាំងប៉ុន្មានខាងលើ សុទ្ធសឹងតែផ្អែកលើន័យទាំងអស់ លើកលែងតែលោក Dubois និង René lagane, Jean Dubois..., ដែលបានកំណត់និយមន័យកិរិយាវិសេសន៍ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរូបនិយម។ ឯលោក Grevisse វិញគាត់បានប្រើលក្ខណៈវិនិច្ឆ័យរូបនិយមតិចតួចណាស់ហាក់ដូចជាដោយចៃដន្យ។ តទៅនេះ យើងនឹងធ្វើការសាកល្បងប្រើលក្ខណៈវិនិច្ឆ័យរូបនិយម ដើម្បីបំផុសលក្ខណៈរបស់កិរិយាវិសេសន៍នៃភាសាខ្មែរ។

**២-លក្ខណៈសម្ព័ន្ធនៃកិរិយាវិសេសន៍** :

មុននឹងស្វែងយល់ពីចរិតលក្ខណៈនៃកិរិយាវិសេសន៍នៃភាសាខ្មែរឱ្យបានស៊ីជម្រៅ តាមលទ្ធភាពអាចទៅ រួច យើងគប្បីពិនិត្យលក្ខណៈសម្ព័ន្ធរបស់ពាក្យប្រភេទនេះត្រួសៗសិន ហើយយើងគប្បីបញ្ជាក់ផងទៀតថា "យើងចាត់ទុកថា ជាកិរិយាវិសេសន៍តែពាក្យពិតប្រាកដ (ពាក្យទោល ពាក្យកម្លាយ ពាក្យសមាស។ល។) : យើងមិនបានចាត់ទុកកន្សោមសេរី ដែលមានមុខងារជាកម្មទេសកាល ថាជាកិរិយាវិសេសន៍ទេ"។

តទៅនេះ យើងសាកល្បងសិក្សាពីមុខងារសម្ព័ន្ធនៃកិរិយាវិសេសន៍ ដោយផ្អែកលើតេស្តដែលជាវិធីមួយនៃ វេយ្យាករណ៍ទម្រង់និយម (grammaire generative et trasformationnelle)។

ឧទាហរណ៍ :

(១.ក)-«យាយនួននិយាយ*ខ្សាវៗ*តទៅទៀត...» (នូ ហាច ផ្កាស្រពោន ទំព័រ១៣)។

(១.ខ)-«ចង្កៀងប្រេងកាតមួយមានពន្លឺ*ញ័រព្រើតៗ*នៅបំភ្លឺផ្ទះល្វែងចិកប៊ុនថា...»(នូ ហាច ផ្កាស្រពោន ទំព័រ២២)។

(១.គ)-«ពេលដែលស្រស់ដួល*ស្រងាប់ស្រងិល*តាធុនកេះចាបសើច*ញញឹមព្រាយ*...»(យ៉ាវ សំផុន ចិត្តម្តាយ ទំព័រ២០)។

(១.ឃ)-«...ដងព្រៃស្ងាត់ឈឹងលឺសម្លេងចង្រិតដែក*យំរ៉ែចៗ*...» (យ៉ាវ សំផុន ចិត្តម្តាយ ទំព័រ៨៥ ឆ្នាំ១៩៨១)។

(១.ង)-«...បន្តិចគាត់ក្រោកនិយាយ*ផ្ទាដៃជើងវាំ*តម្នាក់ឯង» (គ្រូបង្រៀនស្រុកស្រែ ទំព័រ១៣)។

(១.ច)-«...ហើយខួរស្មារបស់ខ្ញុំនេះនៅតែដើរ*តក្រុក*...»(សុទ្ធ ប៉ូលិន អ្នកផ្សងព្រេងអាពាត់អាវាយ ទំព័រ៩២)។

(១.ឆ)-«...ប្រជារាស្ត្រភ័យតក់ស្លុតនាំគ្នាពរកូនជញ្ជូនចៅរត់*រពោយ*» (សែម សូរសិក្សាអក្សរសិល្ប៍ខ្មែរ រឿងក្រុងសុភមិត្រ ទំព័រ៤)។

(១.ជ)-«គ្មានទុទេសីឆ្លើយ*ដោយអង់អាច*...» (ស្រីហិតោបទេស ទំព័រ៦៣)។

**តេស្តសាកល្បងទី១** :

បើយើងដកពាក្យ «*ខ្សាវៗ*» ចេញពីល្បះ(១.ក) ដកពាក្យ«*ព្រឺតៗ*»ចេញពីល្បះ(១.ខ) ដកពាក្យ«*ស្រងាប់ស្រងិល*» ចេញពីល្បះ(១.គ) ដកពាក្យ«*ប្រែតៗ*»ចេញពីល្បះ(១.ឃ) ដកពាក្យ«*ផ្ទាដៃជើង*» ចេញពីល្បះ(១.ង) ដកពាក្យ«*តត្រុក*»ចេញពីល្បះ(១.ច) ដកពាក្យ«*រពោយ*»ចេញពីល្បះ(១.ឆ) និង ដកពាក្យ«*ដោយអង់អាច*» ចេញពីល្បះ(១.ជ) យើងនៅសល់ខ្សែសម្ដីតាមលំដាប់ដូចតទៅ ៖

(២.ក)-«យាយនួននិយាយតទៅទៀត...»។

(២.ខ)-«ចង្កៀងប្រេងកាតមួយមានពន្លឺញ័រនៅបំភ្លឺផ្ទះល្វែងចិកប៊ុនថា...»។

(២.គ)-«ពេលដែលស្រស់ដួល តាធុនកេះចាបសើចញញឹមពព្រាយ...»។

(២.ឃ)-«...ដងព្រៃស្វាត់ឈឹងលឺសំលេងចង្រិតដែកយំ ...»។

(២.ង)-«...បន្តិចគាត់ក្រោកនិយាយតែម្នាក់ឯង»។

(២.ច)-«...ហើយខ្ទួរស្វារបស់ខ្ញុំនេះនៅតែដើរ...»។

(២.ឆ)-«...ប្រជារាស្ត្រភ័យតក់ស្លុតនាំគ្នាពរកូនជញ្ជូនចៅរត់»។

(២.ជ)-«ត្មាតទុទេសីឆ្លើយថា...»។

យើងឃើញថា ខ្សែសម្ដីដែលទទួលបានខាងលើនេះ សុទ្ធតែជាល្បះត្រឹមត្រូវតាមប្រព័ន្ធភាសាខ្មែរ។ លទ្ធផលនេះបង្ហាញថា ការដកពាក្យ«*ខ្សាវៗ ព្រឺតៗ ស្រងាប់ស្រងិល ប្រែតៗ ផ្ទាដៃជើង តត្រុក រពោយ ដោយអង់អាច*» ចេញពីល្បះក៏មិនធ្វើឱ្យខូចរចនាសម្ព័ន្ធនៃល្បះក្នុងភាសាខ្មែរឡើយ។

**តេស្តសាកល្បងទី២ :**

បើយើងប្ដូរទីតាំងនៃពាក្យ«*ខ្សាវៗ*» មកខាងឆ្វេងកិរិយាស័ព្ទ*និយាយ*នៅក្នុងល្បះ(១.ក) ប្ដូរទីតាំងនៃពាក្យ «*ព្រឺតៗ*» មកខាងឆ្វេងគុណនាម*ញ័រ* នៅក្នុងល្បះ(១.ខ) ប្ដូរទីតាំងនៃពាក្យ «*ស្រងាប់ស្រងិល*» មកខាងឆ្វេងកិរិយាស័ព្ទ*ដួល*នៅក្នុងល្បះ(១.គ) ប្ដូរទីតាំងនៃពាក្យ«*ប្រែតៗ*» មកខាងឆ្វេងកិរិយាស័ព្ទ*យំ*នៅក្នុងល្បះ(១.ឃ) ប្ដូរទីតាំងនៃពាក្យ«*ផ្ទាដៃជើង*» មកខាងឆ្វេងកិរិយាស័ព្ទ*ក្រោកនិយាយ* នៅក្នុងល្បះ(១.ង) ប្ដូរទីតាំងនៃពាក្យ «*តត្រុក*» មកខាងឆ្វេងកិរិយាស័ព្ទ*ដើរ*នៅក្នុងល្បះ(១.ច) ប្ដូរទីតាំងនៃពាក្យ«*រពោយ*» មកខាងឆ្វេងកិរិយាស័ព្ទ*រត់*នៅក្នុងល្បះ (១.ឆ) ប្ដូរទីតាំងនៃពាក្យ«*ដោយអង់អាច*» មកខាងឆ្វេងកិរិយាស័ព្ទ*ឆ្លើយ*នៅក្នុងល្បះ(១.ជ) យើងនឹងទទួលបានខ្សែសម្ដីដូចខាងក្រោម :

(២.ក)-*«យាយនួន*ខ្សាវៗ*និយាយតទៅទៀត...»។

(២.ខ)-*«ចង្កៀងប្រេងកាតមយយមានពន្លឺ*ព្រឺតៗ*ញ័រ នៅបំភ្លឺផ្ទះល្វែងចិកប៊ុនថា...»។

(២.គ)-*«ពេលដែលស្រស់*ស្រងាប់សងិល* ដួល តាធុនកេះចាបសើចញញឹមពព្រាយ...»។

(២.ឃ)-*«...ដងព្រៃស្វាត់ឈឹងលឺសំលេងចង្រិតដែក*ប្រែតៗ*យំ ...»។

(២.ង)-*«...បន្តិចគាត់*ផ្ទាដៃជើង*ក្រោកនិយាយតែម្នាក់ឯង»។

(២.ច)-*«...ហើយខ្ទួរស្វារបស់ខ្ញុំនេះនៅតែ*តត្រុក*ដើរ...»។

(២.ឆ)-*«...ប្រជារាស្ត្រភ័យតក់ស្លុតនាំគ្នាពរកូនជញ្ជូនចៅ*រពោយ*រត់ »។

(២.ជ)- *«ត្មាតទុទេសី*ដោយអង់អាច*ឆ្លើយ...»។

ខ្សែសម្ដីដែលទទួលបានខាងលើនេះ ពុំអាចចាត់ទុកជាល្បះត្រឹមត្រូវតាមប្រព័ន្ធនៃភាសាខ្មែរឡើយ ព្រោះការប្ដូរទីតាំងពាក្យមួយចំនួននៅក្នុងកន្សោមកិរិយា ដូចការសាកល្បងនេះ បានធ្វើឱ្យប្រាស់ចាករចនាសម្ព័ន្ធរបស់ភាសាខ្មែរ ដែលគោរពតាមលំដាប់ (“ពាក្យបង្គោល-ពាក្យរណប” “complétif” )។

លទ្ធផលនៃការធ្វើតេស្តសាកល្បងទាំងពីរខាងលើបង្ហាញថា ពាក្យ«*ខ្សាវៗ ព្រើតៗ ស្រងាប់ស្រងិល ប្រែតៗ ផ្ទាដៃជើង តត្រុក រពាយ ដោយអង់អាច*» បានបង្ហាញថា៖

(១)-អាចដកចេញពីល្បះដោយឥតធ្វើឱ្យខូចរចនាសម្ព័ន្ធនៃក្បួនវេយ្យាករណ៍ឡើយ។

(២)-មិនអាចប្ដូរកន្លែងពីខាងស្ដាំពាក្យបង្គោលមកខាងឆ្វេងបានឡើយ។

## ៣-មុខងារកិរិយាវិសេសន៍ ៖

តាមការសង្កេតពីមុខងារកិរិយាវិសេសន៍បញ្ជាក់ថា កិរិយាវិសេសន៍មានមុខងារជារណប«complétif» របស់កិរិយាស័ព្ទ គុណនាម និងកិរិយាវិសេសន៍ដូចគ្នា។ យើងសូមបញ្ជាក់ថា «ពាក្យរណប» សំគាល់ពាក្យទាំងប៉ុន្មានដែលរណបគេ : ក្នុងកន្សោម «ផ្ទះល្អ ផ្ទះបាយ ដើរលឿន លឿនណាស់» ពាក្យ “ល្អ បាយ លឿន ណាស់» ជាពាក្យរណប។

### ៣.១-មុខងាជារណប «complétif» ឱ្យកិរិយាវិសេសន៍

កិរិយាវិសេសន៍មានមុខងារជារណបឱ្យកិរិយាស័ព្ទដែលមានទីតាំងនៅក្នុងសម្ព័ន្ធ គឺនៅពីខាងស្ដាំកិរិយាស័ព្ទកាលណាគេបញ្ជាក់សេចក្ដីក្នុងការនិយាយស្ដី។

ឧទាហរណ៍ ៖

- «ស្ដេចអណ្ដើកដែលស្ដេចក្អែកបានអញ្ជើញដែរ ក៏ខំវារ*កខ្វេសកខ្វាស*នឹងគេដែរ...» (ប្រជុំរឿងព្រេងខ្មែរ ភាគ៧ ទំព័រ៤៧)។
- «ត្រដេវិចឈ្មោលឆ្លើយតម*ដោយអួតអាង*ថា...» (ស្រីហិតោបទេស ភាគ២ ទំព័រ៧៥)។
- «ខាងពួកចោរមានគប់ភ្លើងភ្លឺ*សន្ធោសន្ធៅ* នៅពេញព្រៃ...» (ញ៉ុក ថែម កូលាបប៉ៃលិន ទំព័រ៤៦)។
- «មេចាបលោត*តើតៗ*ក្បាលផ្ងៀងផ្ងង...» (យ៉ាវ សំផុន ចិត្តម្ដាយ ទំព័រ៣៩)។
- «ពូស្វាយរត់*ត្រហេបត្រហប*ទាំងថ្ងៃត្រង់ឡើងទៅហៅយាយតានិយាយប្រាប់...» (អ៊ឹម ប៊ុក គូលីកំណែន ទំព័រ៣៣)។
- «ខ្មោចទាំងនោះនាំគ្នារត់*ព្រោងព្រាត*អស់ទៅ...» ប្រជុំរឿងព្រេងខ្មែរ ភាគ២ ទំព័រ១១)។
- «...អ្នកខ្លះទៀតក៏មានសេចក្ដីភិតភ័យ ហើយនិយាយបូញមាត់បូញកថា...» (តែ ផុន រឿងអាជ័យប្រាជ្ញ ទំព័រ២២។

### ៣.២-មុខងារជារណប (complétif) ឱ្យគុណនាម

ដោយផ្អែកទៅលក្ខណៈរូប-សម្ព័ន្ធ កិរិយាវិសេសន៍មានមុខងារជារណបសម្រាប់គុណនាម។ នៅក្នុងសម្ព័ន្ធវាមានទីតាំងនៅពីខាងស្ដាំគុណនាមដែលជាពាក្យបង្គោល (complété) នោះ។

ឧទាហរណ៍ :

- «...រៀនផ្លាស់និស្ស័យទន់*រវេតរវៃ*របស់យើងចោល» (ស្រីហិតោបទេស ភាគ៣ ទំព័រ.ខ.)។

- «...បណ្តាលឱ្យអ្នកកៀសខ្លួនភ័យ*ស្លន់ស្លោ*តក់ធ្លេធ្លាចុះឡើង» (ភូមិតិរិច្ឆាន ទំព័រ៨៤)។
- «គាមណីខឹង*ពន់ពេក...*» ប្រជុំរឿងព្រេងខ្មែរ ភាគ៣ ទំព័រ៥៤)។
- «...មានអ្នកភ្លេងរូបរាងស្អាតល្អ*ណាស់*ច្រៀងក៏ពិរោះ...» (ប្រជុំរឿងព្រេងខ្មែរ ភាគ៧ ទំព័រ៧៦)។
- «ទន្សាយចាំ*យូរពេក*មិនឃើញអណ្តើកចេញមកវិញ...» (ប្រជុំរឿងព្រេងខ្មែរ ភាគ៧ ទំព័រ៩០)។
- «រូបឆោមលោមពណ៌ល្អ*អនេក...* » (ស្រីហិតោបទេស ភាគ២ ទំព័រ៤៧)។

### ៣.៣-មុខងារជាពាក្យណេប (complétif) កិរិយាវិសេសន៍

តាមការសង្កេតទៅលើរូប-សម្ព័ន្ធរបស់កិរិយាវិសេសន៍ យើងឃើញថា កិរិយាវិសេសន៍មានមុខងារជាពាក្យណេបឱ្យកិរិយាវិសេសន៍ដូចគ្នា ដែលជាពាក្យបង្គោល។ ពាក្យណេបមានទីតាំងនៅខាងស្តាំពាក្យបង្គោលនៅក្នុងសម្ព័ន្ធ។

ឧទាហរណ៍ :

- «...ខណៈនោះ អ្នកជ្រលក់ភ្ញាក់ស្លន់ស្លោ*ក្រញាង*ឡើងដោយសម្រែកខ្លាំង...» (ស្រីហិតោបទេស ភាគ៣ ទំព័រ១៤)។
- «...អញមិនចង់និយាយបូបាច់*ច្រើនពេក*ទេ...» (ស្រីហិតោបទេស ភាគ២ ទំព័រ៥២)។
- »លោកសង្ឃសង្កេតឃើញទាយកទាយិកាសប្បាយរីករាយសើចញញឹមញញែម*ក្រប្លមាត់ក្រប្លចក* គ្រប់ៗគ្នា» (ប្រជុំរឿងព្រេងខ្មែរ ភាគ៧ ទំព័រ៩៧)។
- «...ហើយលូនលោតលេងកញ្ជក់កញ្ជែង*ដោយសប្បាយរីករាយ*"»(ស្រីហិតោបទេស ភាគ៣ ទំព័រ ៤៧)។
- «...នឹងជាចំណីសត្វទាំងឡាយ វាធីរាត់រាយ*ខ្ចាត់ខ្ចាយ*ទៅ...» (ញ៉ុក ថែម មហាវេស្សន្តជាតក ទំព័រ ១១៥)។
- «...ឯតាជូជកខំរត់ខ្ទាញ់*សស្លើតសស្លក់កិតភ័យ*ហើយស្រែកថា...» (ញ៉ុក ថែម មហាវេស្សន្ត ជាតក ទំព័រ២៤៣)។
- «ស្ត្រីផ្កាមាសសូម្បីនរជនមានថ្វីមាត់ ក៏មានចិត្តខ្លបខ្លាចត្រិនត្រុន*ទីមទាម*» (ស្រីហិតោបទេស ភាគ២ ទំព័រ២៥)។

### ៣.៤-ការសង្កេតពិចារណា

តាមការសង្កេតអំពីមុខងាររបស់កិរិយាវិសេសន៍តាមលក្ខណៈសម្ព័ន្ធ យើងឃើញថា ស្ទើរតែមុខងារទាំងអស់របស់កិរិយាវិសេសន៍មានមុខងារជាកម្មទេសកាល។ កិរិយាវិសេសន៍តិចតួចណាស់មានមុខងារផ្សេងទៀត។

#### ៣.៤.១-មុខងារជាកម្មទេសកាលប្រាប់បំណែបឱ្យកិរិយាសព្ទ

ឧទាហរណ៍ :

- «...ហើយលូនលោតលេងកញ្ជក់កញ្ជែង*ដោយសប្បាយរីករាយ*» (ស្រីហិតោបទេស ទំព័រ៤៧)។
- «សីហៈនិយាយ*ដោយក្លាហាន...*» (ស្រីហិតោបទេស ទំព័រ៤៧)។
- «...បន្តិចគាត់ក្រោកឈរនិយាយ*ឆ្កាដៃជើង*តែម្នាក់ឯង» (គ្រូបង្រៀនស្រុកស្រែ ទំព័រ១៣)។

- «ពេលដែលស្រស់ដួល*ស្រងាប់ស្រងិល* តាធុនកេះចាបញញឹមព្រាយ» (យ៉ាវ សំផុន ចិត្តម្ដាយ ទំព័រ២០)។
- «ឱ! យើងនឹងភ្លេចនិយាយ*ច្បាស់លាស់...*» (រឹម គីន សូផាត ទំព័រ៦)។

**៣.៤.២-មុខងារជាកម្មទេសកាលប្រាប់កាលឱ្យកិរិយាសព្ទ**

ឧទាហរណ៍ :

- «*ម្សិលមិញ* ភ្លៀងធ្លាក់មួយមេធំ» (ភាសាខ្មែរថ្នាក់ទី១២ ទំព័រ១៣៨)។
- «អូនតុំ អ្នកប៊ុតមកបបួលបងទៅភ្នំពេញ*ស្អែក*”» (ភូមិតិរិច្ឆាន ទំព័រ១៦)។
- «នែអានេះ! ម៉េចក៏ឈប់ស៊ីក្លូគ្លីភ្លើអញ្ជឹងតិចអញបុកងាប់*ឥឡូវ...*» (ព្រះអាទិត្យថ្មីរះលើដែនដីចាស់ ទំព័រ១៤)។

ដោយផ្អែកលើការវិភាគពីតួនាទីរបស់កិរិយាវិសេសន៍នៅក្នុងល្បះខាងលើ យើងសង្កេតឃើញថា កិរិយាវិសេសន៍ មានមុខងារជារណបឱ្យកិរិយាសព្ទ គុណនាម និង កិរិយាវិសេសន៍ ពេលគឺមានមុខងាររណបឱ្យកិរិយាសព្ទមានទីតាំងនៅខាងស្ដាំកិរិយាសព្ទ មានមុខងាររណបឱ្យគុណនាមមានទីតាំងនៅខាងស្ដាំគុណនាមនិងមានមុខងាររណបឱ្យកិរិយាវិសេសន៍មានទីតាំងនៅខាងស្ដាំកិរិយាវិសេសន៍បង្គោល។

**គន្ថនិទ្ទេស**


១.កេង វ៉ាន់សាក់ *មូលភាពនៃការបង្កើតពាក្យថ្មី* រោងពុម្ពទេព ភ្នំពេញ ១៩៦៤។

២.ក្រសួងអប់រំ *“វេយ្យាករណ៍ថ្នាក់ទី៦”* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣ (ទំព័រ៣៨-៤០)។

៣.ក្រសួងអប់រំ *“វេយ្យាករណ៍ថ្នាក់ទី៥”* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣។

៤.ក្រសួងអប់រំ *“វេយ្យាករណ៍ថ្នាក់ទី៧”* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣។

៥.ក្រសួងអប់រំ *“វេយ្យាករណ៍ថ្នាក់ទី៦”* ភ្នំពេញ រោងពុម្ពរណសិរ្ស ១៩៨៣។

៦.ព្រុំ ម៉ល់ *“លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យ ក្នុងភាសាខ្មែរ”* នៅក្នុងទស្សនាវដ្ដីវិទ្យាស្ថានភាសជាតិ នៃរាជបណ្ឌិតសភាកម្ពុជា ឆ្នាំទី២ លេខ២ ភ្នំពេញ ឆ្នាំ២០០១ (ទំព័រ៥៦-៨១)។

៧. ព្រុំ ម៉ល់ *“អំពីលក្ខណៈវិនិច្ឆ័យរូបនិយម”* នៅក្នុងទស្សនាវដ្ដីវិទ្យាស្ថានភាសជាតិ នៃរាជបណ្ឌិត-សភាកម្ពុជា ឆ្នាំទី៣ លេខ៣ ភ្នំពេញ ឆ្នាំ២០០២ (ទំព័រ៣៧-៥២)។

៨.ឡុង សៀម *“ការស្រាវជ្រាវទំនាក់ទំនងនិងកំណាកំណើតវាក្យស័ព្ទតាមបម្រើបម្រាស់ផ្ទត់នីយកម្មនៅក្នុងភាសាខ្មែរបុរាណ”* នៅក្នុងទស្សនាវដ្ដី វិទ្យាស្ថានភាសជាតិ នៃរាជបណ្ឌិតសភាកម្ពុជា ឆ្នាំ២០០២ (ទំព័រ ៨៩-៩៩)។

៩.អៀវ កើស *“ភាសាខ្មែរ* បណ្ណាគារមិត្តសេរី ភ្នំពេញ ១៩៦៧។

១០. Borsley D., *Syntactic Theaory,* London-New York, Eward Arnold, 1991;

១១. Chomsky Noam, *Language and Language learning,* Oxford University Press, 1971;

១២. Dubois jean et Giacomo Mathée…, *Dictionnaire de linguistiqe,* Larousse, 1973, P.1920;

# សាស្ត្រា វាំង ជួន

## **ពង្សាវតារស្តេចខ្មែរ ខ្សែ៥**

## **បទឆា**

កាលឡើយកាលនោះ យើងថ្លែងចំពោះតាមសាវតារ
លង់លុះព្រះពុទ្ធសាសនា រយវស្សាសករាជបាន។
កាលនោះមានអង្គព្រះមហាក្សត្រ សេពសោយសម្បត្តិថ្កល់ថ្កើងថ្កាន
ក្នុងក្រុងឥន្ទិបត្តរន្ធរាជស្ថាន ក្សត្រក្សាន្តក្លាហានរិទ្ធីរង្គ។
ទ្រង់ព្រះប្រាជ្ញាថ្វាឆ្លៀវឆ្លាត ឈ្មោះហៅព្រះបាទអាទិត្យវង្ស
មានព្រះអំណាចទ្រើសទ្រនុង ហើយទ្រង់ទសពិធរាជធម្មា។
ហើយមានចតុរង្គអង្គសេណី មាត្យមុខមន្ត្រីគ្រប់ភ្នាក់ងារ
កវីបណ្ឌិតព្រាហ្មណ៍ព្រឹទ្ធ ឡើងគាល់រាជាជាប្រក្រតី។
មានទាំងទេត្វីជំប្រាំអង្គ ព្រះភក្ត្រផូរផង់ស្រស់ប្រិមប្រិយ
ហាក់ទេពធីតានូវសួគ៌ស្រី កបកល្យាណីគ្រប់លក្ខិណា។
មានទាំងសៅដៃស្រីស្រឹង្គារ ស្នំស្និទ្ធបរិពារសែនសហស្សា
ភក្ត្រផង់ត្រចង់ដូចតារា សម្រាប់ក្សត្រាចមចក្រី។
គង់ប្រាសាទស្អាតស្អំសំសត្ត ប្រាំពីររួតថ្នាក់ខ្ពស់ត្រឈៃ
ត្រឈឹងពណ្ណរាយសាយរស្មី កំពូលស្រៀវស្រីស្រោងស្រួចស្រស់។
មើលឃើញចិញ្ចែងស្វែងចិញ្ចាច ត្រជិចត្រដាចត្រដោមដុង
ត្រដែតត្រដូចត្រដឹងស្កុង ពីដីដល់ចុងរលុងស្រឡ។
ត្រីសូលក្បាច់ក្បូរពពាលនាគ ភ្លឺព្រោងព្រាយព្រាកព្រាតពព្រិល
ពិទូរពិទាយលាយទឹករិល ដាំត្បូងឥន្ទនិលនៃបលើព្រំ។
ទែនទីរៀបរយគ្រុឌគ្រប់ល្វែង ជួរហូរនាគចែងតែងល្បំ
មុខដាច់ត្រឡែងកែងមុខព្រហ្ម ខ្ពស់ធំត្រដួចបង្អួចទ្វារ។
បន្ទាយប្រាំពីរជាន់ជុំព័ទ្ធ ទាហានរង្គាត់វេនផ្លាស់គ្នា
រោងទង់កំផែងខ្វែងផ្លូវធ្លា រោងលាគោតោអូតហង្សា។
មានរោងរទេះសេះដំរី មានរោងមន្ត្រីជំនុំការ
មានជីកជាគូរជុំសីមា មានចន្ទឆាយាសាលាឃ្លាំង។

ខ្វាងទ្វារទាំងបួនសឹងមុខព្រំ ដាក់កាំភ្លើងធំគ្រប់ទ្វាររាំង
មានទូកសំពៅព្រះទីនាំង មានទាំងស្រះរង់បោក្ខរណី។
តាមផ្លូវតាមថ្នល់សឹងមានផ្សារ មនុស្សម្នាត្រៀបត្រាច្រើនឈូឆរ
លក់គ្រប់ទំនិញសឹងល្អៗ កសិករអស់ឈ្នួញចូលជួញព្រៃ។
មនុស្សក្នុងបូរីសឹងសានសុខ ខ្លះដូរលលក់ខ្លះធ្វើស្រែ
សឹងកាន់សណ្តាប់ច្បាប់ឪម៉ែ ពូជខ្មែរសឹងតែកាន់សាសនា។
ឯអង្គព្រះបាទអាទិត្យវង្ស ថ្កល់ថ្កើងឧត្តុងទ្រង់លក្ខិណា
ស្តេចមានព្រះរាជបុត្រកុមារា ប្រាំអង្គឆាយាឆោមពីសី។
ស្តេចស្តែងតែងទ្រង់ព្រះមេត្តា នឹងរាជបុត្រាពេញព្រះទ័យ
ទាំងប្រាំព្រះអង្គទ្រង់ប្រណី មេត្រីរក្សាស្ងួនពីកក្តិ។
លុះរាជឱរសកុមារា ពាសពេញរូបាដឹងក្តីជាក់
សឹងទ្រង់ឥទ្ធិឫទ្ធសិទ្ធិសក្យ កបនូវនរលក្ខហាក់សូរិយា។
ហេតុត្រកូលខត្តិយ៉ាវង្ស ប្រាំអង្គសឹងទ្រង់ប្រុសប្រាជ្ញា
ឆ្វាតឆ្ពុះគាប់ខុសសព្វកិច្ចសារ ពើពីលោកាក្នុងលោកីយ៍។
ប៉ុន្តែរាជបុត្រដែលប្អូនពៅ មួយអង្គនោះនៅក្មេងសេចក្តី
ដ្បិតជាកុមារតូចឡើយនៃ បិតាមេត្រីស្នេហ៍ចិន្តា។
មានកាលមួយថ្ងៃនោះប្រាំពង្ស ព្រះអាទិត្យវង្សទ្រង់ចេស្តា
ចេញចុងរាជរោងឱ្យសេនា គង់គាល់ក្សត្រាដូចសព្វថ្ងៃ។

**ស្មើរាយ**

ដល់ស្រេចស្តេចគង់លើបល្ល័ង្ក គ្រែទេនទីនាំងរត្នចរណៃ
អាស្នាសម្រាប់រាជក្សត្រថ្លៃ ក្រាលក្រោមក្រាសគ្រែចៀមពូកព្រំ។
ក្រោមរាជកិមានស្វេតឆត្រ ភ្នីផ្នែកច្រវ៉ាត់លើបន្ទំ
កម្រាលញាត្តិវង្សនាម៉ឺនធំ ក្រាលសុទ្ធតែព្រំនឹងចៀមរី។
ជួបជុំចតុរង្គអង្គសេនា ខុនហ្មឺនឧកញ៉ាមុខមន្ត្រី
បរោហិតបណ្ឌិតព្រាហ្មណ៍កវី គង់គាល់ចក្រីច្រើនតាន់តាប់។
នូវពួកស្រីស្នំនារីនាង អកយាយភីលៀងស្រីកំណាន់
គង់គាល់រៀងរាល់សឹងដោយខណ្ឌ ច្រើនច្រៀតខ្ជាប់ខ្ជាន់ឥតចន្លោះ។

មូលនឹងបុត្រានឹងបុត្រី អគ្គមហេសីស្រីស្រៀបស្រស់
រាជវង្សពូជពង្សផងទាំងអស់ គាល់រៀងរបោះតាមបក្តា។
ថ្កល់ថ្កើងជាត្តិពូជពង្សា ថ្កើងយសថ្កើងសក្តិថ្កើងសៅរតារ
ថ្កើងអគ្គក្សត្រាចមចក្រី។
ទើបអគ្គព្រះបាទអាទិត្យវង្ស ក្សត្រក្សាន្តគិតក្នុងព្រះហឫទ័យ
ថាដ្បិតឥន្ទិបត្តបូរី ស្រុកអញនេះនៃទូលាយធំ។
ឥឡូវកូនអញក៏មានច្រើន ប្រុសហើយវៃខ្វៃនសួនសក្តិសម
ដូច្នេះឱ្យចេញទៅឈរព្រំ ទ្វារស្រុកនិគម៤ខាងក្រៅ។
ទ្រង់ព្រះតម្រាស់ត្រាស់ពុំលង់ ព្រះអាទិត្យវង្សក្សត្រចមចៅ
មានព្រះតម្រាស់ត្រាស់ឮរ៉ៅ ព្រះសូរក្រឱជំនុំថា។
មើលហកអស់មុខមន្ត្រី បរោហិតកវីនូវសេនា
ដ្បិតអញគិតចង់ឱ្យបុត្រា ទៅទប់សីមាព្រំទាំង៤។
អញគិតដូច្នេះត្រូវឬខុស ចូលជួយពិគ្រោះឱ្យមាំមួន
ដ្បិតអញមានកូនធំសមសួន ហើយនៅជុំខ្លួនព្រះរាជវាំង។
ឥឡូវប្រទេសយើងនេះធំ ចំហក្រៅព្រំគ្មានរបាំង
បើឱ្យកូនយើងទៅឈរវាំង ឃើញមានកម្លាំងហើយឧត្តម។
គ្រានោះចតុរង្គអគ្គសេនា ស្តាប់ព្រះឱង្ការហើយប្រណម្យ
ជំនុំគ្នាទៅឃើញថាសម ដូចក្សត្រឧត្តមក្នុចចិន្តា។

**និយាយរាយ**

ជំនុំព្រមគ្នាស្រេចពុំលុង ព្រះអាទិត្យវង្សចមចក្ខរ៉ា
បន្ទូលប្រើព្រះរាជបុត្រា ជាច្បងនោះណាឱ្យទៅឈរ។
ព្រំស្រុកឯខាងទិសបូព៌ា ហើយទើបរាជាក្សត្រភូធរ
ប្រើបុត្របន្ទាប់ច្បងទៅឈរ ខាងទិសឧត្តរដោយចំណែក។
ហើយប្រើរាជបុត្រាកណ្តាល ឱ្យចេញត្រអាលទៅដោយឡែក
ឈរទិសខាងលិចតែឯងឯក បិតាស្តេចចែកដោយទិសា។
ហើយត្រាស់តម្រាស់ប្រើបង្គាប់ ឱ្យបុត្របន្ទាប់កណ្តាលណា
ទៅឈរខាងត្បូងព្រំសីមា ទល់នឹងបព្វតាជិតសមុទ្រ។

កាលឡើយកាលនោះ ក្សត្រក្សាន្តទ្រង់យសថ្លៃវិសុទ្ធ
ស្តេចចែកចុងស្រុកដែលបំផុត ឱ្យបុត្រទាំងបួនចេញទៅឈរ។
សល់តែកុមារបុត្រពៅ ដ្បិតតូចឱ្យនៅក្នុងនគរ
ជាមួយនឹងក្សត្រថ្លៃភូធរ មូលនឹងព្រះវរពជីនី។
ហើយត្រាស់ប្រើហោមើលពេលា រកឫក្សដោគជ័យជាជ័យសិទ្ធី
ហោរានគរគួរមើលនាទី ទើបទូលភូមីតាមដោយយល់។

**និយាយរាយ**

ហើយត្រាស់បង្គាប់អស់ចតុរង្គ ឱ្យប្រៀបឱ្យប្រុងរៀងរៀបពល
នឹងហែរាជបុត្របួននិមល ទៅឈរប្រទល់ដែនស្រុកក្រៅ។
ទ្រង់ព្រះបង្គាប់ស្រេចពុំលុង ព្រះអាទិត្យវង្សក្សត្រចមចៅ
នាំព្រះមហេសីស្រីឆោមឆ្លៅ យាងស្ងៅចូលទៃនទីសេយនា។

**ស្មើ**

គ្រានោះចតុរង្គអង្គសេនីយ៍ មាត្យមុខមន្ត្រីគ្រប់កាយា
ចេញពីរាជរោងព្រោងយាត្រា ទៅស្ថានអាត្មាពុំរង់។
រៀបអស់រទេះសេះដំរី ពលពាលសេនីយ៍ប្រាំបីពាន់
តូរ្យតន្ត្រីភ្លេងលេងឮលាន់ រៀបរួចគ្រប់គ្រាន់ចាំរាជា។

**និយាយ**

លុះព្រឹកបំព្រាងភ្លឺស្វាងច្បាស់ សូរ្យសែងរែងរះពីបូព៌ា
កាលណោះស្តេចពាលបួនអង្គា តើនចាកនិទ្រាពុំរង់។
ចេញស្រប់ព្រះភក្ត្រស្រេចបុត្រា សោយទិព្វអាហារហើយពុំលង់
ទ្រង់ស្រង់គន្ធរសស្រស់យល់យុង ស្រេចស្តេចបួនទ្រង់គ្រឿងគ្រប់អង្គ។

**បទទ្រង់គ្រឿង**

ស្តេចពាលទាំងបួនទ្រង់ព្រះពស្ត្រ ខោសោមកាស់ស្រស់បញ្ចង់
ណាធិបជាយក្រែងតែងទ្រង់សង់ រាំវង្សបួនអង្គទ្រង់ភូសា។
ទ្រង់ទម្រង់ដាំត្បូងមណី ខ្វះត្បូងពិជីពេជ្ររចនា
ហើយទ្រង់មកុដរត្នសុវណ្ណា ទាំងបួនក្សត្រាសំរិទ្ធី។
ទ្រង់ស្រេចទើបស្តេចពាលបុត្រា ទាំងបួនកាយាសមសោភី

ឡើងគាល់ជិនកទូវជិនី	យាងចាកចេញពីទីសេយនា។

**ស្មើរាយ**

ដល់ស្រេចទើបស្តេចបួនព្រះអង្គ	ឱនកាយបង្គំព្រះបិតា
នូវព្រះជិនីប្រាំកាយា	ស្រេចបួនបុត្រាគង់គាល់ហ្វៅ។
ជួបជុំចតុរង្គអង្គសេនីយ៍	មាត្យមុខមន្ត្រីច្រើនខ្នួលខ្មៅ
រៀងរាល់គង់គាល់ក្សត្រចមចៅ	នៅក្រៅរាជរោងព្រះដំណាក់។
កាលឡើយកាលនោះ	បិតាទ្រង់យសខ្ពង់ខ្ពស់សក្តិ
នៅរាជិនីប្រាំវលក្ខណ៍	រាក់ទាក់ក្រិតក្រមតាមវេណី។
ដ្បិតថាចេញទៅឈរសីមា	បើនឹងចាត់ចែងតែងរាជការ
ឱ្យមានមេត្តារាស្ត្រប្រជា	ដ្បិតចូវទុកចិត្តស្មើនេត្រា។
ទើបចូវប្រើបាបួនអង្គា	ឱ្យចេញទៅឈរទាំងបួនទ្វារ
ព្រំដែនភាពតាមសណ្តាប់	កុំឱ្យធ្វើបាបរាស្ត្រប្រជា។
លក់ព្នៃវាយវាឱ្យខុសច្បាប់	ប្រើជីងរដូវស្រូវស្រែស្រាប់
ឱ្យត្រូវសណ្តាប់ច្បាប់បូរាណ	ឯអង្គស្តេចពាលបួនបុត្រា។
ក្រាបរាបសិរិសាប្រុងប្រួញប្រាណ	ប្រណម្យស្តែងស្តាប់ច្បាប់អាវតាន
ក្សត្រក្សាន្តចង់ចាំក្នុងចិន្តា។

**និយាយ**

លុះបានពិពេលាឫក្សខុនរុង	ព្រះអាទិត្យវង្សទ្រង់ចេស្តា
នូវរាជទេវីប្រាំកាយា	នូវរាជវង្សាព្រាហ្មណ៍ករី។
ថ្វាយពរថ្វាយជ័យថ្វាយតេជៈ	ចេញទៅឱ្យឈ្នះទុក្ខសោកភ័យ
ឱ្យកបនិងគុណកែវទាំងបី	មានបុណ្យបារមីឫទ្ធិចេស្តា។
ឱ្យអ្នកទាំងបួនចេញទៅឈរ	ព្រំព្រះនគរចុងសីមា
ឱ្យឈ្នះសត្រូវគ្រប់ទិសា	អាយុសោតណាឱ្យវែងឆ្ងាយ។
ថ្វាយពរថ្វាយជ័យរួចស្រាប់ស្រេច	កាលនោះទើបស្តេចពាលតោមឆាយ
ឱនព្រះសិរិសាហត្ថាកាយ	ថ្វាតថ្វាយបង្គំក្រាបលុតលា។
គ្រប់ទាំងប្រាំមួយក្សត្រចមពង្ស	ពេលាខុនរុងបានដោគជា
ស្តែងស្តេចទាំងបួនព្រះអង្គា	លេលាតម្រង់មុខព្រះលាន។

### ស្មើរាយ

ដល់ស្រេចស្តេចផែលឡើងទីនាំង អស្សតរកម្ទាំងរាជអស្សពាណ៍យាន
តន្ត្រីប្រគំសព្ទសូរស៊ាន ពួកពលទាហានហែចេញវៃ។

### ជើតឈឹងបទន្ទបាល

ស្តេចពាលបួនអង្គពង្សខត្តិយា បររាជអស្សាសេះមនោម័យ
ទក្សិណានគរបានជុំបី យសថ្កើងបារមីថ្កើងសក្តា។
ស្រេចទើបបរបែកទាំងបួនអង្គ ផ្តោះភក្រ្តតម្រង់ត្រង់ទិសា
ទាំងបួនដោយខ្លួនដូចបិតា ចែកចុងសីមាឱ្យទៅឈរ។
ពលពាលទាហានផងទាំងឡាយ បរបែកប្រញាយតាមកូជរ
បរផ្ទោះបរផ្ទាកចាកនគរ ដូចហោះអំពរលើវេហាស៍។
អស្សតរបវរសែនហៅខ្លាំង ពលពេញកម្ទាំងលឿនមហិមា
ផាយផ្ទោងផាយផ្ទោះលើពសុធា រូហានហាក់ជាវាហើរហោះ។
នឹងមើលទៅទិសខាងបូព៌ា ពួកពលបុត្រភ្ជាបងទាំងអស់
សេះសម្បុរសែតត្រដែតផ្ទោះ ហាក់ហោះទាំងអស់ផ្ទេកផ្ទោះឆ្ងាយ។
នឹងមើលទៅទីទិសឧត្តរ សុទ្ធសឹងសេះសបរឱ្យផាយ
ផ្ទេកផ្ទោះទាំងអស់ព្រោងប្រញ៉ាយ មើលពីចម្ងាយហាក់ហើរហោះ។
មើលទៅឯលិចបុត្រកណ្តាល សុទ្ធសឹងសេះប្រាលក្រហមស្រស់
សេះផាយប្រញ៉ាយរែងរបោះ ផ្ទោងផ្ទោះទាំងអស់លឿនស្ទុងស្ទៅ។
មើលទៅទក្សិណព្រះរាជបុត្រ បន្ទាប់ទៀតសុទ្ធតែសេះខ្មៅ
សេះបោលសេះបោះផ្ទោះសំដៅ ទៅព្រំខេត្រក្រៅត្បូងទិសា។
ស្តេចពាលរាជបុត្រអង្គទាំងបួន បរបែកដោយខ្លួនផ្តោះភក្រ្តា
តម្រង់ទៅត្រង់ព្រំសីមា ដល់ស្រេចហើយណាបួនរាជា។

### ស្មើបទចាក់ខ្ចៅ

ដល់ស្រេចទើបស្តេចពាលឫទ្ធី ចុះចាកអំពីខ្នងអស្សពាណ៍
ចុះព្រមទាំងពួកពលយោធា ទៀងទើបរាជាពុំរារង់។
ទ្រង់ព្រះដំណើរយាងលេលា តម្រង់ពន្ទាថ្ងៃឧត្តុង្គ
ទាហានហែស្តេចត្រេចស្ទៅស្ទុង ឡើងគង់លើទីព្រះពន្ទា។

### ស្មើរាយ

គ្រាអើយគ្រានោះ ឯអស់នាម៉ឺនគ្រប់ភ្នាក់ងារ
ដែលនៅស្រុកក្រៅគ្រប់បួនទ្វារ សឹងតែមិនម្នាចូលគាល់ហ្មៅ។
សឹងតែភីតភ័យញ័ររន្ធត់ ខ្លះដើរខ្លះរត់មកពីក្រៅ
សស្មើតសស្លក់ភ្នែកសខ្មៅ ខ្លាចក្សត្រចោមចៅទ្រង់យកខុស។

### ទីនាំខប្រាំង

ដល់ហើយចូលគាល់ព្រះរាជា សឹងតែលូនវាដល់ច្រមុះ
បង្គំប្រណម្យស្ដេចទ្រង់យស គ្រប់ៗទាំងអស់ព្រំទ្វារបួន។

### និយាយបទយានី

កាលឡើយកាលនោះ យើងនឹងថ្លែងរសព្រោះតាមក្បួន
កាលអង្គស្ដេចពាលរាជបុត្រស្ងួន ទាំងបួនទៅឈរព្រំទ្វារស្រុក។
សឹងតែចាត់ចែងតែងរាជការ ដូចព្រះឱង្ការព្រះជិនក
មិនមានបំភ័យភ្លៃលៃលក់ រាស្ត្ររៃងសាន្តសុខឥតទុក្ខា។
ដោយតេជៈព្រះគុណមន្តបារមី ស្ដេចតែងប្រណីប្រោសមេត្តា
អស់រាស្ត្រប្រជាសុខសាន្តស- ប្បាយដ្បិតក្សត្រាមិនមានលោក។
ស្ដេចពាលសាម៉ល់រាជទាំងបួន ឈរស្រុកដោយខ្លួនមិនមានរូប
លុះដល់រដូវបានមួយខួប ទើបស្ដេចទៅជួបគាល់បិតា។
រៀងរាល់រដូវពុំដែលខាន ក្សត្រទាំងបួនប្រាណតែងយាត្រា
នានាំសួយរៃបណ្ណាការ ចូលគាល់បិតាក្នុងបូរី។

### ស្មើចូលបីបទឆា

កាលឡើយកាលនោះ យើងថាថ្លែងរសតាមសេចក្ដី
ទុកស្នេះស្ដេចពាលប្អូនទាំងបី ស្រដីតែស្ដេចបងបង្អស់។
ដែលគង់នៅទីទិសបូព៌ា ទ្រង់ព្រះនាមាព្រះថោងស្មោះ
កំពុងកម្លាំងពេញកំលោះ ស្រៀបស្រស់កគ្រូផង់ទ្រង់ឫទ្ធា។
ប៉ុន្តែពីដើមយើងមិនថា ដ្បិតរាជបុត្រាប្រាំអង្គា
សឹងតែគ្មានឈ្មោះគ្មាននាមា ក្នុងក្បួនរាជាពង្សាវតារ។
មានតែឈ្មោះព្រះថោងឯងឯក ឈរព្រំចំណែកបូព៌ទិសា

ហេតុនោះទើបយើងមិនចរចា ពីកាលកុមារនៅនគរ។

**រាយ**

មានកាលសម័យឆ្នាំមួយណា ព្រះថោងក្សត្រារាជភូធរ
ចង់នាំសួយរំដួមអម្ពរ ចូលគាល់ព្រះវររាជបិតា។
ទ្រង់ព្រះតម្រាស់ស្រេចពុំលង់ កាលនោះទើបទ្រង់ព្រះទេសា
ចេញចាកអំពីទីសេយនា ភក្រ្តាតម្រង់ចុងពោងជ័យ។

**ស្មើរាយ**

ដល់ស្រេចស្តេចគង់លើអាស្នា ជួបជុំសេនាមុខមន្ត្រី
គង់គាល់សាម៉ល់រាជធិបតី ដូចកាលប្រក្រតីរៀងមកណា។
កាលនោះព្រះរាជចមពង្ស សាម៉ល់ឫទ្ធិរុងទ្រង់សក្តា
មានព្រះតម្រាស់ត្រាស់ទៅថា អើយឃុនអក្ខរ៉ាផងទាំងឡាយ។
ចូលឯងសរសេររាជសារ ប្រថាប់បោះត្រាធាប់ខ្វល់ខ្វាយ
ប្រាប់ទៅចៅមឿងនិងចៅហ្វាយ ស្រុកផងទាំងឡាយឱ្យគិតការ។
ឱ្យគ្រប់ជនបទដែននិគម ស្រុកតូចស្រុកធំខ្វែងបួរបឹង
ដ្បិតអញចូលក្រុងក្នុងខែហ្នឹង ប្រាប់ឱ្យគេដឹងគ្រប់គ្រាមា។
ឱ្យនាំសួយរំបេណ្ណាការ តិចច្រើនក្តីណាកុំយូរយារ
ដ្បិតអញនឹងចូលទៅគាព លេលាបង្គំគាល់បិតា។
គ្រានោះអាឡាក់ផងទាំងឡាយ សឹងតែប្រញាយតែងឱង្ការ
រួចស្រេចទើបបោះព្រះសីង្ហារ ប្រាប់ទៅឧកញ៉ានឹងព្រះពញា។

**និយាយរាយ**

គ្រាអើយគ្រានោះ ឯអស់នាហ្មឺនផងនានា
ដែលនៅឈរស្រុកគ្រាមា ខាងទិសបូព៌ាព្រំសីមា។
លុះឃើញចុតហ្មាយព្រះរាជា សឹងតែម្ទីម្នាគ្រប់អាត្មា
នាំអស់សួយរំបេណ្ណាការ មកថ្វាយក្សត្រាច្រើនក្រាស់ក្រៃ។

**និយាយរាយ**

កាលឡើយកាលនោះ ព្រះថោងទ្រង់យសរាជក្សត្រថ្លៃ

បានយល់សួយរៃច្រើនក្រាស់ក្រៃ　　មកថ្វាយក្សត្រថ្ងៃគ្រប់គ្រាមា។
គ្រប់ដែននិគមព្រំសីមា　　ទៀងទើបក្សត្រាប្រើយោធា
រើយអស់នាហ្មឺនគ្រប់ភ្នាក់ងារ　　ចូលឯងម្មីម្នាធាប់ខ្វល់ខ្វាយ។
ទៅរៀបរទេះសេះដំរី　　ពលពាលសេនីយ៍ផងទាំងឡាយ
អង្គអញនឹងនាំអស់តង្វាយ　　ទៅថ្វាយបង្គំគាល់បិតា។
គ្រានោះនាហ្មឺនគ្រប់ភ្នាក់ងារ　　បង្គំលុតលាព្រះក្សត្រា
ទៅថ្វាស់រទេះសេះគជសារ　　កែនយកអាត្មារស្ត្រប្រជា។

**និយាយ**

លុះកែនបានស្រេចទើបមន្ត្រី　　នាំសេះដំរីពលលេលា
មករៀបចាំក្សត្រថ្ងៃរាជា　　នៅនាព្រះលានមុខរាជវាំង។
ហើយឱ្យជញ្ជូនបណ្ណាការ　　ផ្ទុកលើគជសារនឹងអូតខ្លាំង
ខ្លះរៀបដំរីព្រះទីនាំង　　មន្ត្រីត្រៃស័ង្ខចាំក្សត្រា។

**ក្រៅខេន**

លុះបានពេលាជ័យមង្គល　　ទើបរាជសាម៉ល់ចាកអាស្នា
ទ្រង់គ្រឿងរុងរឿងអស់កាយា　　នាំស្នំស្នេហាយាត្រាវៃ។

**ស្មើរាយ**

ដល់ស្រេចទើបស្តេចឡើងទីនាំង　　គជាកម្លាំងឥតនិរភ័យ
កញ្ចោងរាយផ្កាយទិព្វមាសមៃ　　ហែក្សត្រជៀស្មជ័យចាកពិមាន។

**ញ៉ាដើន**

បើកបរដំរីព្រះទីនាំង　　តន្ត្រីត្រៃស័ង្ខសព្ទសូរស៊ាន
មន្ត្រីសេនាពលទាហាន　　ហែស្តេចលលានចាកចេញចរ។

**ដើតរាយ**

ស្តេចត្រាច់លុះដល់ក្រុងឥន្ទិបត្ត　　បូរីរម្យរត្នរាជបវរ
ស្តេចឱ្យបញ្ឈប់ពលនិករ　　ជិតទ្វារនគរក្រៅសីមា។

**បទនា**

កាលឡើយកាលនោះ　　យើងនឹងថ្លែងរសចែងចរចា
អំពីសាម៉ល់រាជក្សត្រា　　ទាំងបីកាយាដែលឈរព្រំ។
សឹងតែងនាំសួយបណ្ណាការ　　មកថ្វាយបិតាដែលជាធំ

ដែលគង់ឥន្ទិបត្តរត្នរាជរម្យ មកជុំសាម៉ល់រាជទាំងបួន។
ក្នុងក្រុងនគរឥន្ទិបត្ត ប៉ុន្តែបុត្រក្សត្របោះដោយខ្លួន
មិនទាន់ឡើងគាល់បានជួបជួន បោះគ្រប់ទាំងបួនទ្វារវាំងក្រៅ។
ស្តេចឱ្យជញ្ជូនទ្រព្យទាំងឡាយ ដែលនាំមកថ្វាយព្រះចមចៅ
ខ្លះរែកខ្លះសែងច្រើនខ្នួលខ្មៅ ទៅដាក់នូវក្រៅព្រះដំណាក់។

**និយាយរាយ**

លុះថ្ងៃរសៀលបានបីម៉ោង កាលនោះព្រះថោងក្សត្រទ្រង់លក្ខណ៍
ទ្រង់គន្ធរសស្រស់ស្រប់កក្រ្គ ស្រេចទើបចមចក្រទ្រង់អម្ពរ។

**បទទ្រទ់គ្រឿង**

ក្សត្រាស្តេចទ្រង់ស្រោមព្រះបាទ ចចាប់យ៉ាងស្អាតហើយទ្រង់ខោ
ស្នាប់ភ្លៅប៉ាក់ធ្លាក់ចាក់ជីបជរ ស្រេចទើបកូជរទ្រង់ព្រះពស្ត្រ។
ហើយទ្រង់កូសាស្រេចចមពង្ស ទ្រង់ព្រះទម្រង់ត្បូងភ្នំធ្នុះ
ទ្រង់ព្រះសង្វារពេជ្រព្រោងប្រុះ ហើយទើបទ្រង់យសសៀតមាលា។
ហើយទ្រង់ណាគិបទិព្វជាយក្រែង ទ្រង់ស្រេចស្តេចស្តែងនាំបរិពារ
សេនាទាហានហែរាជា លេលាឡើងគាល់ព្រះបិតា។

**ស្មើរាប**

ស្តេចយាងលុះដល់ចុងរាជរោង កាលនោះព្រះថោងរាជបុត្រា
គង់ចាំព្រះជិនកឧត្តឡា មិនទាន់យាត្រាចេញពីក្នុង។
ជួបជុំតែអស់មុខមន្ត្រី ព្រាហ្មណ៍ព្រឹទ្ធករីនូវរាជវង្ស
អង្គុយត្រៀបត្រាចាំគាល់ក្រុង ព្រះអាទិត្យវង្សក្សត្របិតា។

**បទយានី**

ថ្ងៃងពីសាម៉ល់រាជទាំងបី តែងនាំសួយរៃបណ្ណាការ
លុះដល់ម៉ោងបីទើបក្សត្រា ឡើងគាល់បិតាដូចសព្វដង។

**ស្មើរាយ**

ស្តេចយាងលុះដល់ចុងរាជរោង ជួបនឹងព្រះថោងព្រះរៀមច្បង
បីអង្គបង្គំរៀមរាបរង រួសរាយសាសងសព្វសេចក្តី។

**និយាយបទនា**

កាលឡើយកាលនោះ ព្រះជិនកទ្រង់យសខ្ពស់សក្តា

ស្ដេចគង់ក្នុងទីទែនសេយនា    ក្សត្រាពុំស្រួលក្នុងអង្គា។
ពុំបានចេញក្នុងពេងគំនាល់    ឱ្យនាហ្មឺនគាល់ដូចសព្វគ្រា
អផ្សុកក្នុងអង្គព្រះរាជា    ហេតុតែពេគាបៀតបៀនកាយ។
លុះស្ដេចបានជ្រាបជាបិតា    ទាំងបួនកាយាមកពីឆ្ងាយ
នាំព្រះរាជសារស្ងួយតង្វាយ    មកថ្វាយបង្គំចាំគាល់នៅ។

**រាយ**

ទើបស្ដេចបានព្រះរាជឱង្ការ    ប្រើរាជកុមារបុត្រាពៅ
ដែលគង់ជាមួយនឹងហ្វូងចូវ    ឱ្យទៅទទួលព្រះរាជសារ។
បន្ទូលថាហៃកូនពុំផា    ចូលអ្នកលេលាចរយាត្រា
ចេញទៅទទួលព្រះរាជសារ    គឺព្រះរៀមបាចាំនៅក្រៅ។
កាលឡើយកាលនោះ    ឯអង្គឱរសរាជឆោមឆៅ
បានស្ដាប់ព្រះសូរចូវចមចៅ    ប្រើឱ្យចេញក្រៅទទួលសារ។
ក្រាបលាបិតាស្រេចពុំលង់    ចាកចេញពីក្នុងយាងយាត្រា
ហើយទ្រង់តម្រិះក្នុងចិន្ដា    គិតថាជម្មតាជាមហាក្សត្រ។
បើចេញទទួលព្រះរាជសារ    ស្ងួយបណ្ណាការទ្រព្យសម្បត្តិ
គួរតែគង់ក្រោមស្វេតឆត្រ    គិតស្រេចបុត្រក្សត្រយាងយាត្រា។

**ភ្លេង**

ដល់ស្រេចអនុជពៅឆោមយុង    យាងបង់ឡើងគង់លើអាសនា
គ្រែទែនបល្ល័ង្ករត្នសូវណ្ណា    ដំណែលបិតាស្ដេចតែងគង់។

**លារាយ**

កាលឡើយកាលនោះ    ឯអង្គព្រះរៀមបួនចមពង្ស
ឡើងគង់លើទែនរាជអាស្នា។    ក្រោមរាជពិមានស្វេតឆត្រ
ព្រះរៀមគិតកាត់ក្នុងចិន្ដា    ស្មានជាព្រះវររាជបិតា។
បង្វែរសីមារាជរត្នរម្យ    ឱ្យទៅអនុជពៅសោយរាជ្យ។
ព្រះរៀមបួនខ្លាចថ្វាយបង្គំ។    ខ្មាស់អស់នាហ្មឺនផងតូចធំ
ក្នុងទ្រូងស្មើរយំធំក្ដៅផ្សា    ប៉ុន្ដែខំអត់ទប់ព្រះទ័យ។
ធ្វើជាវាហីហើយក្សត្រា    ទូលព្រះអនុជថ្វាយរាជសារ

សួយរៃបណ្ណាការទាំងឡាយ។

**និយាយ**

ឯអង្គអនុជសឹងស្រាកស្រួល រួសរាយទទួលអស់តង្វាយ
ពុំជ្រាបព្រះរៀមទាំងប្អូនកាយ ខ្វល់ខ្វាយអន់អាក់តូចព្រះទ័យ។
ឯប្អូនព្រះរៀមរាជសាម៉ល់ ពុំជ្រាបកិច្ចកល់សព្វសេចក្ដី
រីងរឹតមួម៉ៅក្ដៅព្រះទ័យ ស្ដេចប្អូនឃាងវៃចាកពាជវាំង។
ឯអស់បរិពារពលសេនីយ៍ សឹងក្រោកទីទៃទៅព្រាតព្រោង
តាមហែសាម៉ល់រាជព្រះថោង តម្រង់ទៅពេងពន្ធាក្រៅ។

**ភ្លេងវ៉ៃទរាយ**

ដល់ស្រេចសម្ដេចរៀមរាជា ទាំងប្អូនអង្គាគិតក្ដាត់ក្ដៅ
ខ្ញាល់នឹងអនុជរីងមួម៉ៅ ឈប់នៅនាក្រៅទ្វារនគរ។
ជំនុំគិតគ្នាថាឥឡូវ បិតាហួងចូវចមកូធរ
ប្រើយើងទាំងប្អូនឱ្យទៅឈរ ក្រៅពីនគរស្រុកចុងកាត់។
លោកលើកកូនពៅឱ្យវាធំ ឱ្យសោយរាជរម្យស្វេតឆត្រ
ក្នុងក្រុងនគរឥន្ទិបត្ត សេពសោយសម្បត្តិស្នងជៀស្នជ័យ។
ឯយើងជាបងគេត្រលាំង ឱ្យនៅឈរវាំងឯព្រំព្រៃ
គ្រាន់ជាសាម៉ល់នាំសួយរៃ មកថ្វាយគេនៃដែលជាប្អូន។
បំណាច់កើតជាស្ដេចដូចគេ ម្ដេចឡើយទទេអាសាសូន្យ
លោកស្អប់ថាឯងមិនមែនកូន លោកលើកឯប្អូនឱ្យជាធំ។
ដូច្នេះកុំអត់ឱ្យវាធ្លាប់ យើងទៅធ្វើទ័ពទាំងប្អូនព្រំ
យើងលើកមកកិនយករាជរម្យ ឱ្យវារលំទាន់ថ្មីៗ។

**និយាយរាយ**

គិតស្រេចប្អូនស្ដេចរាជសាម៉ល់ បង្គាប់អស់ពលពួកសេនីយ៍
ឱ្យរៀបរទេះសេះដំរី ស្រេចទើបចក្រីប្អូនក្សត្រា។
ផែលឡើងគង់លើខ្នងមនោម័យ បំបែកទីទៃគ្រប់ទិសា
តម្រង់ទៅត្រង់ស្ថានអាត្មា ពួកពលសេនាហែចេញខ្មី។

**ដើតឈឹងស្មើរាយ**

ដល់ស្រេចព្រះថោងរាជចមចក្រ យាងឡើងដំណាក់ទើបចក្រី
បង្គាប់ប្រើអស់មុខមន្ត្រី ឱ្យកែនសេនីយ៍ពលទាំងឡាយ។
ត្រាស់ប្រើអាឡាក់តែងអក្ខរា បោះព្រះសង្ការព្រះចុតហ្មាយ
ប្រាប់ទៅចៅមឿងគ្រប់ជិតឆ្ងាយ នូវអស់ចៅហ្វាយខេត្រតូចធំ។
ឱ្យកែនអស់ពលរាស្ត្រប្រជា គ្រប់ស្រុកគ្រាមាមឿងមានិគម
ចំណែកទិសបូព៌ខេត្រខណ្ឌព្រំ ស្រុកតូចស្រុកធំកុំឱ្យសល់។
សឹងមានអាជ្ញានាំចុតហ្មាយ ចេញទៅប្រញ៉ាប់លុះបានដល់
ចៅមឿងចៅហ្វាយស្រុករចល់ ទៅកែនអស់ពលរាស្ត្រប្រជា។

**និយាយរាយ**

លុះកែនបានពលច្រើនខ្ទាន់ខ្ទាប់ រួសរាន់ប្រញាប់គ្រប់គ្រាមា
ដាក់មេដាក់នាយដោយមុខងារ នាំពលលេលាចូលពេងជ័យ។
ភ្ជុំគ្នានៅនាមុខរាជវាំង ពលសឹងសម្រាំងពុំមានខ្សោយ
ប្រាំសែនប្រាំម៉ឺនប្រាំបួនរយ បើរាប់ជាខ្សោយបានប្រាំលាន។
សឹងកាន់សស្ត្រាគ្រឿងអាវុធ សឹងមោះសឹងមុតចិត្តទាហាន
ហ៊ោហាវខ្ញៀវខ្ញាសព្ទសូរស៊ាន នៅមុខព្រះលានទីរាជវាំង។
សឹងចេះអាគមមន្តសិល្បសាស្ត្រ នីព័ទ្ធគង់ប្រាស់មហារនាំង
ប៉ែតទានសាទានថតថយលាំង សំកោកសំកាំងបំបាំងកាយ។
បន្ទប់បង្អាក់បញ្ចៀសគ្រប់ មហាស្រឡប់មហាស្រឡាយ
មានកូនសង្កត់គង់កុយខ្នាយ មានព្រះកំចាយជួតសិរិសា។
បីលានសឹងតែពលថ្មើរជើង កាន់ខែលកាំភ្លើងដាវវែងខ្វី
មួយលានសឹងតែជិះដំរី មួយលានទៀតខ្មីជិះពាជី។

**គ្រៅខេន**

លុះពេញពន្ទឹចំម៉ោងបី បានឫក្សដោគជ័យសំរិទ្ធី
កាលនោះព្រះថោងរាជភូមី ស្រង់ព្រះវារីរួចចោមពង្សា។

**ទ្រង់គ្រឿង**

ស្ដេចទ្រង់ចន្ទចួងគ្រឿងគន្ធរស រួចទ្រង់ព្រះពស្ត្រស្រេចពុំលង់
ទ្រង់ព្រះភូសាសង្វារវង្ស ចិញ្ចៀនទម្រង់ទ្រង់ហើយនៃ។

ទ្រង់ព្រះមកុដកែវសោភ័ណ ទ្រង់ធ្នូកៅទណ្ឌសៀតខ័នជ័យ
ប្រធិបជាយក្រែងទ្រង់ប្រពៃ សៀតផ្កាមារតីស្រេចលេលា។

**ស្មើរាយ**

ដល់ស្រេចព្រះថោងរាជក្សត្រា ឡើងគង់ទីនាំងគជេន្ទ្រា
មន្ត្រីសេនីយ៍ជិះអស្សពាណ៍ រៀបរាយរៀងគ្នាអមកូជរ។
បើកបាំងក្ងស់ក្ងំស្វេតឆត្រ ភ្លេងលេងស្រងាត់ត្រែស័ង្ខស្គរ
តាំងហ៊ោកក្រើកឰឡ្នខ្ទរ ស្រឡប់អម្ពរមេឃខ្មៅជាំ។
តាំងហ៊ោបីដងយកជ័យរួច មេកងទ័ពស្រួចឡើងលលាំ
ទ័ពណូនលើកតាមទៅទន្ទាំ ទូងស្គរគ្រាំៗឰខ្ទាំងក្តាត់។
លើកទ័ពចេញពីទិសបូព៌ា ព្រះថោងរាជាព្រះរៀមក្សត្រ
ប៉ុនប៉ងដណ្តើមរាជសម្បត្តិ ក្រុងឥន្ទ្រិបត្តរម្យរត្តា។

**ដើតរាយ**

យើងស្ទេះទុកទ័ពស្តេចព្រះថោង នឹងថ្លែងទំនងពីក្សត្រា
ដែលឈរខេត្តខណ្ឌពាន់សីមា ឧត្តរទិសាវិញទៀតខ្មី។
កាលស្តេចចេញពីក្រុងឥន្ទ្រិបត្ត ដល់ហើយមហាក្សត្រមន្ត្រី
ឱ្យកែនអស់កងពលសេនីយ៍ នូវសេះដំរីករជាទ័ព។

**ចៃទចា**

គ្រានោះមន្ត្រីផងទាំងឡាយ ចេញទៅប្រញាយដូចបង្គាប់
កែនបានទាំងអស់គណនាពាប់ ពលផងបានជាប់ជាងប្រាំលាន។
ប្រមូលគ្រប់ខេត្រមឿងនិគម ស្រុកតូចស្រុកធំជុំសព្វស៊ាន
នៅនាទ្វារវាំងមុខព្រះលាន ហើយមានរទេះសេះគជា។

**និយាយ**

លុះថ្ងៃរសៀលហួសកាទៃ បានឫក្សជោគជ័យបានពេលា
កាលនោះសាម៉ល់រាជឫទ្ធា ស្រង់ព្រះគង្គារួចក្សត្រា។
សេពសោយព្រះស្ងោយរសវិជ្ជា ស្រេចទ្រង់គន្ធារសសព្វសារ៉ា
ស្រេចស្តេចទ្រង់គ្រឿរឿងរចនា ទ្រង់ធ្នូខ័នថ្វាយាងចេញវៃ។

**ស្មើរាយ**

ដល់ស្រេចសម្តេចព្រះចក្រី ឡើងគង់ដំរីគជេន្ទ្រជ័យ
បើកបាំងព្រះក្ងស់ខ្ពស់ត្រៃឈៃ ថ្កើងបុណ្យបារមីនៃក្សត្រា។
តាំងហ៊ោបីដងញ័រប្រថពី ទូងស្គរភេរីពលខ្សៀវខ្សា
ស្រើបស្រុះក្រញែងវែងឫទ្ធក្លា ទូរទឹមទិសាមេឃស្រទំ។

**ក្រៅខេន**

ហើយស្តេចលើកទ័ពចេញទៅវៃ សឹងជិះមនោម័យបរមំព្រំ
បង្កួកស្នែងសេះពួរធំ ទើបលើកទ័ពធំចេញជាក្រោយ។
ស្តេចលើកទ័ពពីទិសឧត្តរ ពលព្រិននិករទៅរជយ
ប៉ុនប៉ងបំណងយកពជ្យសោយ កុំឱ្យជំនាអនុជពៅ។

**ដើតបទរាយ**

ស្តេចលើកទ័ពពីទិសខាងជើង ដំណើរនេះយើងទុក្ខស្ទះសិន
នឹងថ្ងៃងពីស្តេចខាងលិចកូវ កាលស្តេចវិលទៅទីមណ្ឌល។
ដល់ស្រេចទើបស្តេចប្រើសេនា ឱ្យចរយាត្រាទៅកែនពលសេនីយ៍
ក្រាបលាក្សត្រនិមល ចេញកែនអស់ពលគ្រប់គ្រាមា។

**ចែចចា**

លុះដល់កែនពលគ្រប់ខេត្រខណ្ឌ ដាក់មេឱ្យកាន់ហើយភ្ជាក់ងារ
នាំអស់ពួកពលវិលលេលា មកជុំនូវនាមុខរាជវាំង។
សឹងតែកាន់គ្រឿងគ្រប់អង្គា ចេះមន្តវិជ្ជាពូកែខ្លាំង
សឹងតែប្រសព្វធ្លាប់ចូលច្បាំង រើសតែសម្រាំងបានប្រាំលាន។
ហើយរៀបរទេះសេះដំរី អូតលាក្របីក៏សឹងមាន
ត្រៃស័ង្ខតាំងសារសព្វសូរស៊ាន នៅមុខព្រះលានចាំក្សត្រា។

**និយាយ**

លុះដល់ថ្ងៃរះផុតចុងព្រៃ បានឫក្សជោគជ័យជាន់ធាយា
កាលនោះសាម៉ល់រាជក្សត្រា ចេញចាកសេយនាស្រង់គង្គា។

**ឡូចសុខ**

ស្រង់ស្រេចសាម៉ល់រាជក្សត្រា សោយទិព្វអាហាររសវិជ្ជា

សោយស្រេចពុំលង់ទ្រង់គន្ធា ស្រេចទើបពជាទ្រង់អម្ពរ។

**បទទ្រង់គ្រឿង**

ទ្រង់ស្រោមព្រះបាទស្អាតពុំលង់ ហើយទើបចមពង្សស្តេចទ្រង់ខោ
ស្អាប់ភ្លៅប៉ាក់ធ្លាក់ចាក់ជីបជរ ហើយទើបក្លួងទ្រង់ពស្ត្រា។
ហើយទ្រង់ណាធិបទិព្វជាយត្រែង ហើយទើបស្តេចស្តែងទ្រង់ក្លសា
ពាក់ពេជ្រទម្រង់ទ្រង់សង្វារ ទ្រង់ធ្នូខ័នថ្វាយាត្រាវៃ។

**ស្មើរាយ**

ដល់ស្រេចស្តេចគង់ទីនាំង គជាកម្ទាំងខ្លាំងនិរភ័យ
បាំងក្លស់ស្រោងស្រស់ខ្ពស់ត្រឈៃ តាំងហ៊ោយកជ័យបីដងរួច។

**ក្រៅខេន**

ហើយឱ្យគោះគង់ទូងស្គរធំ តន្ត្រីរងំឮក្រលួច
ទង់ជ័យដិះសេះបរលឿនព្រួច ទើបទ័ពស្រួចលើកចេញទៅលលាំ។
ទ័ពណ្ហូនឯក្រោយផ្គុំស្នែងកែស កាំភ្លើងកែឆែះបាញ់ឮគ្រាំង
ទើបលើកទ័ពធំទៅទន្ទាំ មេឃមីស្រទំដាលច្រវ៉ាត់។
ស្តេចលើកទ័ពទៅពីខាងលិច បំណងនឹងត្រាច់ក្រុងឥន្ទិបត្ត
ដណើមយកពជ្យស្វេតឆត្រ ពលពាសច្រើនក្តាត់លើកចេញទៅ។

**ដើតចូលរាយ**

ឥឡូវយើងឃាត់ទ័ពនេះទុក លើកចេញតតុកតាមដោយផ្លូវ
យើងថ្លែងពីស្តេចមួយទៀតក្លូវ ដែលស្តេចគង់នៅទិសទក្សិណា។
កាលស្តេចវិលពីថ្វាយពជសារ តដល់ស្រេចក្សត្រាពជធិព្វជីន
គិតករជាទ័ពលើកទៅកិន យកឥន្ទិបត្តរម្យរត្នា។
ស្តេចត្រាស់តម្រាស់ប្រើសេនា សេនីយ៍ឧកញ៉ាហ្មឺនព្រះពញា
ឱ្យទៅកែនកងរាស្ត្រប្រជា គ្រប់ស្រុកគ្រាមាផង់ទាំងឡាយ។

**ចៃចចា**

គ្រានោះសេនាមុខមន្ត្រី លាព្រះចក្រីទៅប្រញាយ
កែនគ្រប់ជនបទស្រុកជិតឆ្ងាយ បានបីលានថ្វាយនឹងប្រាំសែន។
ជ្បិតស្រុកខាងត្បូងទល់នឹងភ្នំ ប្រាំងសមុទ្រព្រំប្រទល់ដែន

ហេតុនោះនាហ្មឺនទៅរកកែន បានតែប្រាំសែននិងបីលាន។
មន្ត្រីកែនពលគ្រប់និគម ហួសប្រាជ្ញខ្នងភ្នំដោយកោះកៀន
បានស្រេចទើបនាំពលទាហាន ជុំនៅព្រះលានមុខរាជវាំង។
មានខ្មែរក្ដួយផងព្នងសំរែ ហើយមានចិនសែចិនកន្ដាំង
ដែលចូលមកនៅដោយមាត់ច្រាំង កែនយកទៅច្បាំងមិនមានសល់។
សឹងតែកាន់គ្រឿងគ្រប់អាវុធ សឹងមោះសឹងមុតចិត្តកំហល់
ហើយចេះប្រសព្វគ្រប់កិច្ចកល់ ប្រទះទ័ពដល់ហ៊ានចូលចាប់។
ហើយរៀបរទេះសេះដំរី មានតូរ្យតន្ត្រីគ្រប់ប្រដាប់
បាញ់ច្រង់អូសដាក់ជើងគល់ស្រាប់ ពលពាលអឹងអាប់រៀបប្រាណប្រុង។

**និយាយ**

លង់លុះបានឫក្សដោគជ័យជា ឆាយាពេលាតាមខុនរុង
កាលនោះសាម៉ល់រាជចមពង្ស យាងចេញពីក្នុងស្រង់គង្គា។

**ឡូងសុង**

ស្រង់ស្រេចស្ដេចស្ដេចសោយអាហារ សោយស្រេចក្សត្រាទ្រង់គន្ធា
ក្រចេះចួងចន្ទន៍គ្រឿងមាលា ស្រេចទើបរាជាផ្លាស់គ្រឿងទ្រង់។

**បទទ្រង់គ្រឿង**

ស្ដេចទ្រង់ព្រះពស្ត្រព្រះភូសា កងកន់ហត្ថាសង្វារវង្ស
ពាក់ពេជ្រចិញ្ចៀនព្រះទម្រង់ ហើយទ្រង់មកុដសុទ្ធសុវណ្ណា។
ហើយទ្រង់ណាធិបជាយក្រែង សុភាក់កន្សែងព្រះកនិដ្ឋា
ទ្រង់ក្រើសៀតស៊កព្រះខ័នថ្វា ព្រះការទាំងសងសៀតក្ដាំងផា។
ហើយស្ដេចទ្រង់ពាក់សុពណ៌បាទ ទ្រង់ស្រោមសាក្ខាតស្អាតសោភា
ព្រះកកាន់សរធ្នូជ័យយា លេលាចាកប្រាំង្គយាងចេញវៃ។

**ស្មើរាយ**

ដល់ស្រេចស្ដេចស្ដេងឡើងទីនាំង គង់គជកម្លាំងខ្លាំងនិរភ័យ
កញ្ចែងរាយផ្កាយទិព្វមាសមៃ ទាំងក្ងស់ត្រឈៃបីចិញ្ចែង។
សព្ទស្គរតូរ្យតន្ត្រីរងមំ ស្គរជំប្រគំផ្ទុំត្រែស្នែង
តាំងហ៊ោបីដងយកជ័យស្ដេង ផងឹតបែកផ្សេងសព្វទិសា។

**ក្រាវខេន**

ហើយបាញ់កាំភ្លើងបីឡោស៊ីន ទ័ពស្ដេចលើកមុនទៅខៀវខ្វា
ទ័ពណ្ហូនសាម៉ល់រាជក្សត្រា លើកចាំសេនាទៅតាមក្រោយ។

**ដើតបទតូចបាល**

ស្ដេចទាំងបួនទិសរាជសាម៉ល់ លើកទ័ពរចល់ទៅរាំងជ័យ
សឹងតែខាំងៗមិនមានខ្សោយ ចង់បានរាជសោយទាំងបួនអង្គ។
សួរសព្ទកក្រើកព្រៃព្រឹក្សា លើកចោមសីមាចូលតម្រង់
រូតរះមិនបានឈប់បង្អង់ ត្រេចត្រង់លុះទៀបទៅកាព។

**បទរាយ**

គ្រាអើយគ្រានោះ យើងនឹងថ្លែងរួសរាស្ត្រប្រជា
ដែលនៅនគរនានាំគ្នា ចូលក្នុងអទ្វាររកបាញ់សត្វ។
លុះបានឃើញទ័ពពួកពលពាល ពាសពេញទាំងវាលច្រើនពេកក្តាត់
ឃើញទាំងសាម៉ល់រាជបុត្រក្សត្រ លើកកាត់តម្រង់មកបូរី។
ឃើញច្បាស់ភ័យណាស់ញ័ររន្ធត់ បបួលគ្នារត់ទៅផ្ទះខ្មី
ប្រពន្ធទៅផ្ទះមើលទៅឃើញប្ដី រត់ចូលមកនៃស្រែកសួរថា។
គេយើយអើគេឯងរត់ថ្វី ឯងឆ្កួតទេរឺរត់ឆ្ងែឆ្ងា
ប្ដីឮប្រពន្ធសួរច្នោះណា ជេរថាមេស្វាមិនស្គាល់ផាប់។
វាថាអញឆ្កួតរត់មកថ្វី អញរត់នេះនៃព្រោះឃើញទ័ព
លើកមកច្រើនណាស់អញបានរាប់ ទាំងអស់បានជាប់ជាងប្រាំបួនលាន។
ប្រពន្ធឮប្ដីស្ដីដូច្នោះ ភ័យណាស់ញ័រពោះព្រលឹងគ្មាន
ស្រែកហៅកូនចៅឮសូរស៊ាន ផ្អើលទាំងអ្នករៀនអ្នកផ្សាផ្សេ។
ឮកងរំពងក្នុងបូរី ទាំងប្រុសទាំងស្រីផ្អើលឆោឡោ
ផ្អើលទាំងអ្នកល្បែងលេងបៀរប៉ោ ទូទាំងនគរឥន្ទិបត្ត។

**និយាយព្យ៉ាដឹន**

ថ្ងៃងពីនាហ្មឹនដែលជាធំ ដឹងការសុខមជាបុត្រក្សត្រ
ទាំងបួនលើកទ័ពចូលមកថ្វាត់ ដណ្ដើមសម្បត្តិរម្យរត្នា។
សឹងតែភ័យឥតគិតគ្នីគ្នា ស្រេចទើបមីម្នាចរយាត្រា

ឡើងក្រាបបង្គំទូលកិច្ចការ ក្សត្រជាបិតាចរជៀសជ័យ។

**និយាយ**

ដល់ស្រេចសម្តេចចៅហ្វាយធំ ក្រាបថ្វាយបង្គំទើបទូលរៃ
ក្រាបទូលសូមទ្រង់ជ្រាបព្រះទ័យ ឥឡូវនេះនៃរាជបុត្រា។
ទាំងបួនព្រះអង្គដែលនៅគង់ ឈរព្រំក្រៃក្រុងចុងសីមា
ឥឡូវកែនកងពលសេនា លើកចរយាត្រាចូលមកជិត។
លើកចូលមកគ្រប់បួនទិសា ពលពាលសេនាខ្មៅងងឹត
